**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des sciences Économique

Royal University Of Law and Economic

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយផ្ទាល់មាត់

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែ មេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: **កញ្ញា ផល្លី ៉ានី**

**កញ្ញា ឆឹត មល្លិកា**

ណែនាំដោយ

**លោកស្រី សំណាង ផលដេត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី **២៤**

ឆ្នាំចូលសិក្សា **២០២០**

ឆ្នាំសរសេរសារណា **២០២៤**

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ ផល្លី រ៉ានី និងនាងខ្ញុំ ឆឹត មល្លិកា ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី២៤ ឆ្នាំសិក្សា ២០២០- ២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមគោរពគារវកិច្ចកតញ្ញូតាធម៌

## គោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ

លោកឪពុក **លាត ផល្លី** និងអ្នកម្តាយ **តេក ណារិន** និងលោកឪពុក **ឆឹត ហាក់** និងអ្នកម្តាយ **ហ៊ី ស្រី** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សាកូនដោយក្តីមេត្តា ករុណា និងផ្តល់ក្តីស្រលាញ់ដល់រូបកូន ព្រមទាំងអប់រំទូន្មានប្រៀនប្រដៅរូបកូនតាំងពីតូចរហូតដល់ធំពេញវ័យ ដើម្បីឲ្យរូបកូនដើរផ្លូវល្អ សុចរិតទៀងត្រង់ជៀសវាងអំពើណាដែលសង្គមស្អប់ខ្ពើម ហើយរូបលោកទាំងទ្វេរបានលះបង់ទាំងកម្លាំងកាយចិត្ត និងថវិកា ដើម្បីទំនុកបម្រុងរួមទាំងជំរុញទឹកចិត្តកូនឲ្យមានស្មារតី និងឱកាសក្នុងការទទួលបានការសិក្សាអប់រំតាំងពីថ្នាក់បឋមសិក្សា រហូតដល់ការបញ្ចប់បរិញ្ញាបត្រនេះ។ គុណូបការៈរបស់លោកទាំងទ្វេរ ថ្លៃថ្លាពុំអាចកាត់ថ្លៃបានឡើយ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះលោកស្រី **សំណាង ផលដេត** ជាសាស្ត្រាចារ្យណែនាំសារណាដែលបានចំណាយពេលវេលាផ្ទាល់ខ្លួនដ៏មានតម្លៃដើម្បីផ្តល់ជាឱវាទក្នុងការត្រួសត្រាយផ្លូវជាពិសេសជំរុញទឹកចិត្តក្នុងការចងក្រងសារណាឲ្យបានបញ្ចប់ទាន់ពេលវេលា។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងលោក លោកស្រីសាស្ត្រាចារ្យ ដែលបានដឹកនាំបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីផ្តល់ចំណេះដឹងដល់រូបខ្ញុំទាំងពីរទុកជាមូលដ្ឋានពុទ្ធិផ្នែកច្បាប់ ដើម្បីជាស្ពានសម្រាប់ឆ្លងទៅកាន់ការប្រកបវិជ្ជាជីវៈផ្នែកច្បាប់នៅថ្ងៃអនាគត។

ជាកិច្ចបញ្ចប់ នាងខ្ញុំទាំងពីរសូមលើកដៃបួងសួងដល់វត្ថុស័ក្តិសិទ្ធិ សូមលោកតាមជួយថែរក្សាលោកអ្នកមានគុណទាំងពីរ ឯកឧត្តមសាកលវិទ្យាធិកា សាកលវិទ្យាធិការរង លោក លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងមិត្តរួមជំនាន់ទាំងអស់ឲ្យជួបតែ សេចក្តីសុខ សុខភាពល្អ និងជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សាមួយនេះត្រូវបានចងក្រង និងសម្រេចឡើងដោយមានការសាមគ្គីភាពរួមទាំងសហការណ៍យ៉ាងមោះមុតពីនាងខ្ញុំទាំងពីរ ផ្គួបផ្សំជាមួយនឹងការជួយជ្រោមជ្រែងពីសំណាក់ លោកស្រីសាស្ត្រាចារ្យ **សំណាង ផលដេត** ជាសាស្ត្រាចារ្យដឹកនាំសារណានៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

បន្ទាប់ពីបានឆ្លងកាត់ការសិក្សានៅថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ឆមាសទី១ នូវមុខវិជ្ជានីតិវិធីរដ្ឋប្បវេណីធ្វើឲ្យនាងខ្ញុំទាំងពីរនាក់ មានចំណាប់អារម្មណ៍ទៅលើ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងខ្លាំង។ ហេតុដូចនេះហើយ ទើបនាងខ្ញុំទាំងពីរនាក់សម្រេចចិត្តលើកយកប្រធានបទ "នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល" នេះមកធ្វើជាប្រធានបទ សម្រាប់សរសេរជាសារណាដើម្បីបញ្ចប់ការសិក្សា ព្រោះយល់ឃើញថានីតិវិធីនេះ ជានីតិវិធីមួយដ៏សំខាន់ដែលជួយសម្រួលដល់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់យ៉ាងច្រើន ដើម្បីលើកកម្ពស់ក៏ដូចជាសម្រួលដល់ការជម្រះក្តីប្រកបដោយភាពសុចរិត និងយុត្តិធម៌។

យើងខ្ញុំសង្ឃឹមថាសារណាដែលក្រុមនាងខ្ញុំបានចងក្រងឡើងនេះ នឹងអាចក្លាយជាឯកសារមួយដើម្បីជួយបំពេញបន្ថែមនូវទ្រឹស្តីផ្នែកច្បាប់ដល់មិត្តអ្នកអាន ក៏ដូចជាសម្រាប់សិស្សនិស្សិតជំនាន់ក្រោយក្នុងការស្រាវជ្រាវបន្តដើម្បីជាប្រយោជន៍ដែលអាចយកទៅសិក្សារៀនសូត្រទៅថ្ងៃអនាគត។ ឯកសារមួយនេះមិនទាន់ល្អឥតខ្ចោះនៅឡើយនោះទេ ដែលអាចមាននូវចំណុចខ្វះខាតមួយចំនួនពាក់ព័ន្ធនឹងខ្លឹមសារ និងអក្ខរាវិរុទ្ធ ដូចនេះនាងខ្ញុំទាំងពីររូបសូមការអធ្យាស្រ័យពីសំណាក់មិត្តអ្នកអាន ព្រមទាំងគោរពទទួលស្វាគមន៍ដោយស្មោះនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនា និងកែលម្អរ។

ជាកិច្ចបញ្ចប់នាងខ្ញុំទាំងពីររូប សូមផ្ញើរស្នាដៃមួយនេះជូនដល់មិត្តអ្នកអានសូមរីករាយជាមួយនឹងការអានរបស់ខ្លួន និងសូមជូនពរឲ្យជួបតែពុទ្ធពរទាំង៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

១.១.អត្ថន័យនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ៤

១.១.១. គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ៤

១.១.២. គោលការណ៍ជាមូលដ្ឋានសំខាន់ៗនៅក្នុងនីតិវិធីរដ្ឋប្បវេណី ........ ៥

១.២.ភាពចាំបាច់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ៨

១.២.១.ការកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ៨

១.២.២.ការកោះហៅ និងដាក់ឯកសារត្រៀម ........ ៩

**ជំពូកទី២**

**ការចាប់ផ្ដើមនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**

២.១.ការសាកល្បងធ្វើការផ្សះផ្សា ........ ១៤

២.១.១. ការធ្វើសេចក្ដីថ្លែងការណ៍ ........ ១៤

២.១.២.ការដឹកនាំរៀបចំ និងកំណត់ ........ ១៦

២.២. សកម្មភាពនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ១៩

២.២.១. ការដាក់មធ្យោបាយតទល់ ឬការពារ ........ ១៩

២.២.២. ការបន្ថែម ឬការផ្លាស់ប្ដូរកម្មវត្ថុនៃបណ្ដឹង ........ ២១

២.២.៣. សកម្មភាពបណ្ដឹងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ២២

២.២.៤. ការបំបែក ឬការបញ្ចូលរឿងក្ដី ........ ២៩

២.៣.ការធ្វើកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ២៩

២.៣.១.ចំណុចដែលត្រូវសរសេរ ........ ២៩

២.៣.២.កិច្ចការដាក់បញ្ជូន ........ ៣០

## ជំពូកទី ៣

## ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល


៣.១. ការបញ្ជាក់អំពីអង្គហេតុដែលត្រូវបំភ្លឺ.....៣២

៣.១.១. ការបញ្ជាក់របស់តុលាការ និងភាគី.....៣២

៣.១.២. ការមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មី.....៣៣

៣.២.អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល.....៣៣

៣.២.១. ការកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផល.....៣៣

៣.២.២. ករណីលើកលែង.....៣៤

៣.២.៣. ការមិនសុខចិត្តលើកំណត់ហេតុ.....៣៤

**សេចក្តីសន្និដ្ឋាន**.....៣៥

**អនុសាសន៍**.....៣៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីតារាងឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១

- ពាក្យបណ្ដឹង
- ដីកាសម្រេចឲ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ
- ដីកាសម្រេចបង្គាប់ឲ្យបង់ពន្ធដាក់ពាក្យបណ្ដឹងតប
- ដីកាកោះ

## ឧបសម្ព័ន្ធទី២

- ពាក្យបណ្ដឹងតប
- ពាក្យសុំធ្វើជាអ្នកតំណាងដោយអាណត្តិ
- ឯកសារចម្លើយ
- ឯកសារត្រៀមលើកទី១ របស់ដើមចោទ
- សេចក្ដីថ្លែងការណ៍តប
- ពាក្យសុំផ្ទេរសមត្ថកិច្ចសាលាជម្រះក្ដី
- ពាក្យសុំពន្យាពេលចូលរួមនីតិវិធី «នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល»
- កំណត់ហេតុសះជា
- កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

## ឧបសម្ព័ន្ធទី៣

- ពាក្យសុំបញ្ចូលភស្តុតាង
- កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២
- លិខិតអញ្ជើញមេធាវី
- ដីកាកោះ

# សេចក្តីផ្តើម

## ១.លំនាំបញ្ហាស្រាវជ្រាវ

នាសម័យបុព្វកាល គ្រប់ប្រទេសទាំងអស់នៅលើសកលលោកត្រូវបានគ្រប់គ្រងដោយស្តេចផែនដី រាល់សិទ្ធិសេរីភាពរបស់ប្រជារាស្ត្រត្រូវបានកំណត់ព្រំដែនដោយអំណាចរបស់ស្តេច។ ស្តេច ត្រូវបានប្រជារាស្ត្រគោរពកោតខ្លាចដោយចាត់ទុកថា អំណាចស្តេចត្រូវបានផ្តល់ឲ្យដោយអាទិទេព ហើយពាក្យសំដីរបស់ស្តេចគឺប្រៀបដូចជាពាក្យសំដីអាទិទេព ដោយច្បាប់ត្រូវបានអនុម័តឡើងទៅតាមពាក្យសំដីរបស់ស្តេច ហើយប្រជារាស្ត្រត្រូវតែគោរពតាមដោយខានពុំបាន។ នាសម័យនោះ ប្រជារាស្ត្រមិនមែនជាប្រធាននៃច្បាប់ទេតែជាកម្មវត្ថុនៃច្បាប់ ដោយស្តេចមានអំណាចផ្តាច់ការ ប្រជារាស្ត្រមិនមានសេរីភាពនោះឡើយមានតែកាតព្វកិច្ចចំពោះស្តេច។ ស្តេច ដើរតួគ្រប់យ៉ាងទាំងការដឹកនាំរដ្ឋ ការធ្វើសឹកសង្គ្រាមការពារទឹកដី និងពង្រីកទឹកដីព្រមទាំងជាចៅក្រមកាត់ក្តីថែមទៀតផង មិនមានការបែងចែកស្ថាប័នដឹកនាំរដ្ឋឡើយ។ ដោយយល់ឃើញថា ការដឹកនាំបែបនេះបង្កទុក្ខទោសដល់ប្រជារាស្ត្រ ហើយធ្វើឲ្យប្រទេសជាតិគ្មានសណ្តាប់ធ្នាប់ ទើបមានក្រុមទស្សនៈវិទូបានពិចារណារួមទាំងបង្កើតទ្រឹស្តីដែលមានឥទ្ធិពលយ៉ាងខ្លាំង ដែលអាចនាំឲ្យមានការរើបម្រាស់ពីការដឹកនាំផ្តាច់ការ។ ទស្សនៈវិទូរជនជាតិបារាំង លោក ហ្សង់ ហ្សាក់រូសូ ( ១៧១២-១៧៧៨ ) បានបង្កើតនូវទ្រឹស្តីសង្គមមួយសម្រាប់ជាទស្សនៈក្នុងការគ្រប់គ្រងសង្គមតាមរយៈកិច្ចសន្យាសង្គម។ យោងតាមទស្សនៈរបស់លោកយល់ឃើញថា មនុស្សរស់នៅតាមបែបធម្មជាតិរៀងៗខ្លួន គឺជាមូលហេតុនៃការបង្កទំនាស់ឡើង ដូច្នេះមនុស្សត្រូវលះបង់សិទ្ធិទាំងឡាយរបស់ខ្លួនទៅអោយសង្គម ហើយទទួលការបញ្ញាស៊ីវិលមកវិញ ពោលគឺគោរពច្បាប់ដែលបង្កើតចេញពីឆន្ទៈទូទៅរបស់សង្គម ដើម្បីបញ្ចប់វិវាទ ឬទំនាស់ ត្រូវបង្កើតកិច្ចសន្យាស៊ីវិលមួយ។ ប្រទេសកម្ពុជា ក៏ជាប្រទេសមួយដែលកាន់នូវរបបរាជានិយមផងដែរកាលពីអតីតកាល ក៏ប៉ុន្តែត្រូវបានកែប្រែដោយអាណានិគមនិយមបារាំង ដោយបារាំងបានបង្ខំសម្តេចព្រះបាទនរោត្តមសីហនុ ឲ្យឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យមួយដែលក្នុងនោះមានន័យថាព្រះមហាក្សត្រសោយរាជ្យតែមិនកាន់អំណាច។ កម្ពុជាក៏បានចងក្រងនូវច្បាប់មួយចំនួនរួមមាន ក្រមទោសភរិយា ច្បាប់ពាណិជ្ជកម្ម ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ និងក្រមព្រហ្មទណ្ឌជាដើម។ ប្រព័ន្ធតុលាការ ក៏បានបង្កើតឡើងបន្ទាប់ពីបារាំងបានដាក់អាណានិគមមកលើប្រទេសកម្ពុជា ដោយបារាំងបានរៀបចំរចនាសម្ព័ន្ធ និងដឹកនាំគ្រប់គ្រងស្ថាប័នតុលាការបែងចែកជាពីរដាច់ពីគ្នាគឺ តុលាការជំនុំជម្រះក្តីមនុស្សក្នុងស្រុក និងតុលាការសហតុភាព។ ជាអកុសល ប្រទេសកម្ពុជាបានធ្លាក់ចូលគ្រោះមហន្តរាយដ៏ធំធេង គឺសម័យកម្ពុជាប្រជាធិបតេយ្យ ដោយសម័យនោះត្រូវបានលុបបំបាត់អស់នូវគ្រប់វិស័យ ដែលរដ្ឋាភិបាលចាស់បន្សល់ទុកឲ្យរួមទាំងវិស័យច្បាប់ និងប្រព័ន្ធតុលាការផងដែរ។ ក្រោយការរំដោះក្នុងថ្ងៃ ៧ ខែ មករា ឆ្នាំ១៩៧៩ កម្ពុជាបានចាប់ផ្តើមពីចំណុចសូន្យ ដោយធ្វើការអភិវឌ្ឍខ្លួនពីបាតដៃទទេ ហើយប្រព័ន្ធយុត្តាធិការក៏បានពង្រឹងឡើងផងដែរ ក្រោម

ជំនួយរបស់បណ្តាប្រទេសនានារួមមាន បារាំង អាល្លឺម៉ង់ និងជប៉ុនជាដើម។ ក្នុងឆ្នាំ២០០៦ អង្គការប្រទេសជប៉ុន ដែលហៅកាត់ថា JICA បានជួយក្នុងការចងក្រងក្រមនីតិវិធីរដ្ឋប្បវេណី ដែលក្នុងនោះបានចែងជា៩គន្ថី និង៥៨៨ មាត្រា។

ជាការពិតណាស់បណ្តឹងរដ្ឋប្បវេណីជាបណ្តឹងមួយ ដែលដឹកនាំសកម្មភាពដោយអំណាចតុលាការនៃរដ្ឋមួយ ដែលរដ្ឋនោះប្រគល់នូវសិទ្ធិអំណាចក្នុងការវិនិច្ឆ័យ និងសម្រេចក្តីជូនទៅតុលាការ ដោយសិទ្ធិអំណាចនេះមានអានុភាពឡើងដោយសារសាលក្រម ឬសាលដីកា។ ជាទូទៅនៅពេលដែលមានវិវាទកើតឡើងនៅក្នុងរឿងក្តីរដ្ឋប្បវេណី គឺភាគីអាចមានសិទ្ធិនៅក្នុងការផ្សះផ្សាគ្នាបាន ដោយតុលាការគ្មានសិទ្ធិជ្រៀតជ្រែកនៅក្នុងរឿងកជននោះទេ ប៉ុន្តែតុលាការអាចដោះស្រាយវិវាទនោះបាន បើសិនជាមានភាគីខាងណាមួយបានដាក់ពាក្យបណ្តឹង។ បន្ទាប់ពីទទួលបាននូវពាក្យបណ្តឹងនោះហើយ តុលាការត្រូវពិនិត្យលើពាក្យបណ្តឹងនោះអំពីភាពត្រឹមត្រូវ និងភាពមិនត្រឹមត្រូវនៅក្នុងពាក្យបណ្តឹងនោះ បើសិនជាពាក្យបណ្តឹងនោះមាននូវចំណុចខ្វះខាត តុលាការត្រូវជូនដំណឹងឲ្យមានការកែប្រែ តែបើពាក្យបណ្តឹងនោះត្រឹមត្រូវតាមច្បាប់ហើយតុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដោយឆ្លងកាត់នូវនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីធានាឲ្យការកាត់ក្តីនោះប្រកបដោយសុចរិត តម្លាភាព និងយុត្តិធម៌ជូនភាគី។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ គឺជានីតិវិធីដែលចាំបាច់មួយដែលផ្តល់ភាពងាយស្រួលក្នុងនីតិវិធីបន្តទៅទៀត។ នីតិវិធីនេះ ធ្វើឡើងដើម្បីជួយសម្រួលដល់ការរៀបចំនូវសេចក្តីអះអាងរបស់ភាគី និងធ្វើការកំណត់នូវចំណុចវិវាទ និងធ្វើការរៀបចំនូវភស្តុតាងដែលពាក់ព័ន្ធនឹងចំណុចវិវាទ ដែលត្រូវពិនិត្យ និងវិនិច្ឆ័យនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីជំរុញនីតិវិធីឲ្យមានភាពឆាប់រហ័ស គ្មានភាពស្មុគស្មាញ និងមានភាពយុត្តិធម៌។ ចំពោះរឿងក្តីចំនួនទឹកប្រាក់តិច ដែលមានគោលបំណងដោះស្រាយវិវាទឲ្យបានឆាប់រហ័សដោយនីតិវិធីសង្ខេប តុលាការអាចកំណត់កាលបរិច្ឆេទដើម្បីធ្វើនីតិវិធីទាញហេតុផលផ្ទាល់មាត់តែម្តង ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន។

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងធ្វើការផ្សះផ្សាជាដំបូងសិន លើកលែងតែក្នុងករណីដែលយល់ឃើញថាមិនសមរម្យ ដូចជាក្នុងករណីដែលសិទ្ធិ និងកាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្តឹង គឺជាប្រភេទសិទ្ធិ និងកាតព្វកិច្ចដែលមិនអាចចាត់ចែងបានដោយគ្រាន់តែផ្អែកលើការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះទេ។ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់នេះ តួអង្គដែលសំខាន់នៅក្នុងការដឹកនាំនីតិវិធី ដើម្បីដោះស្រាយវិវាទជូនភាគីនោះគឺតុលាការ។ តុលាការត្រូវគោរពនូវគោលការណ៍សំខាន់ៗ ដូចជា គោលការណ៍ចំពោះមុខ គោលការណ៍យុត្តិធម៌ និងឆាប់រហ័ស គោលការណ៍អសាធារណៈ គោលការណ៍សិទ្ធិចាត់ចែងរបស់ភាគី និងគោលការណ៍នៃការប្រើប្រាស់សិទ្ធិបំភ្លឺជាដើម។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

តើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាអ្វី? តើការចាប់ផ្ដើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការបញ្ចប់នីតិវិធីនេះ មានដំណើរការយ៉ាងដូចម្ដេច?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនូវប្រធានបទសារណាមួយនេះគឺ ក្នុងគោលបំណងដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍នូវវិស័យច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងសម្រាប់បង្កើនធនធានពុទ្ធិលើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ដែលជានីតិវិធីមួយដ៏សំខាន់ដើម្បីធានាឲ្យនីតិវិធីទាញហេតុផល ប្រព្រឹត្តិឡើងប្រកបដោយសុក្រឹត្យភាព និងរហ័សដល់មិត្តអ្នកអានគ្រប់រូបដើម្បីចូលរួមចំណែកក៏សាងធនធានមនុស្សលើវិស័យផ្នែកច្បាប់ ក៏ដូចជាដើម្បីទុកជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយធ្វើការស្រាវជ្រាវ ព្រមទាំងយល់ដឹងពីបច្ចុប្បន្នភាពនៃការវិវឌ្ឍន៍វិស័យច្បាប់នៅកម្ពុជា។

## ៤.សារៈសំខាន់ក្នុងការជ្រើសរើសប្រធានបទ

សារណានេះ សរសេរឡើងដើម្បីបង្ហាញជូនដល់អ្នកសិក្សាគ្រប់មជ្ឈដ្ឋានក្នុងការស្វែងយល់ឲ្យបានស៊ីជម្រៅទៅលើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏ដូចជាទុកជាឯកសារសម្រាប់មិត្តនិស្សិតក្នុងការស្រាវជ្រាវ។

## ៥.វិសាលភាពក្នុងការស្រាវជ្រាវ

ដើម្បីសម្រេចបាននូវការស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំបានធ្វើការសិក្សានូវឯកសារដែលមានលក្ខណៈផ្ដោតទៅលើទ្រឹស្ដីច្បាប់ រួមមាន រដ្ឋធម្មនុញ្ញ ក្រមនីតិវិធីរដ្ឋប្បវេណី សៀវភៅសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ នីតិវិធីបណ្ដឹង សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ៦. រចនាសម្ព័ន្ធការស្រាវជ្រាវ

ការស្រាវជ្រាវស្ដីពី “**នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**” នេះនាងខ្ញុំទាំងពីររូបបានបែងចែកជា ៣ ជំពូកធំៗគឺ ៖

ជំពូកទី ១ សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ជំពូកទី ២ ការចាប់ផ្ដើមនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ជំពូកទី ៣ ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ខ្លឹមសារនៃជំពូកនីមួយៗខាងលើនេះ និងបង្ហាញជូនលម្អិតទាំងស្រុងក្នុងសារណាបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំដូចខាងក្រោម។

# ជំពូកទី១
# សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

# ជំពូកទី១
# សញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីរដ្ឋប្បវេណី ជានីតិវិធីដោះស្រាយវិវាទរឿងក្តីរដ្ឋប្បវេណីដើម្បីការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន។ តុលាការដែលមានសមត្ថកិច្ចរបស់ គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្តឹង វិនិច្ឆ័យ ហើយចេញសាលក្រម ឬសាលដីកាបាន។[1] តាមរយៈនីតិវិធីនៃការជំនុំជម្រះលើកទី១ គឺផ្តោតសំខាន់លើ៖ នីតិវិធីនៃបណ្តឹង គឺនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលផ្ទាល់មាត់។ ដោយឡែកការបកស្រាយខាងក្រោមនេះ មានការពណ៌នាអំពីចំណុចមួយចំនួន គឺអត្ថន័យ (១.១) និងភាពចាំបាច់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់(១.២)។

## ១.១.អត្ថន័យនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជានីតិវិធីនៃការជំនុំជម្រះលើកទី១ ដែលភាគីជាដើមចោទធ្វើការដាក់ពាក្យបណ្តឹងដើម្បីធ្វើការទាមទារ ហើយសមត្ថកិច្ចតុលាការត្រូវធ្វើការពិនិត្យ វិនិច្ឆ័យ ពិភាក្សា និងជំនុំជម្រះ។ ភាគីនីមួយៗតែងតែតវ៉ាចំពោះការលើកឡើងនូវអង្គហេតុទាំងអស់របស់ភាគីម្ខាងទៀត ហើយតែងតែព្យាយាមដាក់ភស្តុតាងទាំងឡាយណាដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ខ្លួន។ ប៉ុន្តែការធ្វើបែបនេះនាំឲ្យការជម្រះក្តីមានការស្មុគស្មាញ ចំណាយពេលវេលាយូរ និងពិបាកក្នុងការស្វែងរកការពិត ហេតុនេះក្រមនីតិវិធីរដ្ឋប្បវេណីបញ្ញត្តិជាចាំបាច់ឲ្យមាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីនៃការត្រៀមរៀបចំសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ដើម្បីលើកកម្ពស់ និងសម្រួលដល់ការជម្រះក្តីនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់។[2]

### ១.១.១. គោលបំណងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្រមនីតិវិធីរដ្ឋប្បវេណី ចែងថានៅមុនការជម្រះក្តីដោយការទាញហេតុផលផ្ទាល់មាត់ ត្រូវរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីយល់មិនស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឲ្យបានល្អិតល្អន់។[3]

ដូច្នេះតុលាការត្រូវប្រើប្រាស់សិទ្ធិបំភ្លឺជាអាទិ៍ ដើម្បីរៀបចំសេចក្តីអះអាងរបស់ភាគីបំភ្លឺចំណុចវិវាទ និងរៀបចំភស្តុតាងសំខាន់។[4]

---

[1] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៧ (ពីពេលនេះតទៅហៅថា ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦)។

[2] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងច្បាប់ក្រមនីតិវិធីរដ្ឋប្បវេណី ,២០០៨, សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង, ៧៤, ភ្នំពេញ ៖ ក្រសួងយុត្តិធម៌ (ពីពេលនេះតទៅហៅថា សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ នីតិវិធីបណ្តឹង ឆ្នាំ២០០៨)។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា១០៣។

[4] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៩០ កថាខណ្ឌទី១។

ការអះអាង ជាសេចក្តីថ្លែងការណ៍ មិនមែនជាការឆ្លើយតបនឹងសេចក្តីថ្លែងការណ៍របស់ភាគីម្ខាងទៀត ហើយរៀបរាប់ពីអង្គហេតុឯករាជ្យ ឬមតិយោបល់តាមផ្លូវច្បាប់។[5] រីឯចំណុចវិវាទ ជាចំណុចនៃទំនាស់ដែលត្រូវបំភ្លឺដើម្បីចេញសាលក្រម ដែលអាចជាចំណុចវិវាទលើអង្គហេតុ ឬ អង្គច្បាប់។[6] ចំណែកឯភស្តុតាង គឺជាតឹកតាងជាលាយលក្ខណ៍អក្សរ ឬមិនមែនជាលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងចំណុចវិវាទ រវាងភាគីដែលជាមូលដ្ឋាននៃការសម្រេចសេចក្តីរបស់តុលាការ។[7]

ហេតុនេះទើបក្រមនីតិវិធីរដ្ឋប្បវេណីចែងអំពីនីតិវិធី មុននឹងកាជម្រះក្តីដោយការទាញហេតុផលផ្ទាល់មាត់ត្រូវរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីសម្រួល និងលើកកម្ពស់ដល់ការជម្រះក្តី។

### ១.១.២. គោលការណ៍ជាមូលដ្ឋានសំខាន់ៗនៅក្នុងនីតិវិធីរដ្ឋប្បវេណី

គោលការណ៍ជាមូលដ្ឋាន គឺជាគោលគំនិតឆន្ទៈនយោបាយសាធារណៈរបស់រដ្ឋ ដែលមានលក្ខណៈចាប់បង្ខំ ចង្អុលបង្ហាញ និងសម្រេចតាមប្រព័ន្ធនៃបណ្តាញបទបញ្ញត្តិនៃនីតិវិធី និងស្តែងឡើងនូវលក្ខណៈនៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយផ្តើមចេញពីទស្សនៈឆន្ទៈរបស់រដ្ឋចំពោះស្ថានភាពសង្គមជាក់ស្តែង បណ្តាលបទដ្ឋានគតិយុត្តដែលមានតម្លៃខ្ពស់បំផុតគឺ រដ្ឋធម្មនុញ្ញ ដែលជាបទដ្ឋានជាន់ខ្ពស់បំផុតដូចជាច្បាប់ចាត់តាំងតុលាការជាអាទិ៍ ច្បាប់ពាក់ព័ន្ធដទៃទៀត គោលនយោបាយឯកជន រួមទាំងតម្រូវការ និងការទាមទាររបស់សង្គមជាតិ និងអន្តរជាតិផងដែរ។

ដោយឡែក គោលការណ៍ជាមូលដ្ឋានអាចចាត់ទុកជាគម្រោងឆ្អឹងនៃច្បាប់ ដែលទ្រទ្រង់ប្រព័ន្ធច្បាប់ទាំងមូលឲ្យមានជំហររឹងមាំ និងមានចលនារស់រវើកនៅពេលច្បាប់នោះត្រូវបានអនុវត្ត។ក្រមនីតិវិធីរដ្ឋប្បវេណីពឹងផ្អែកលើគោលការណ៍ជាមូលដ្ឋានមួយចំនួនដូចខាងក្រោម ហើយដែលជាគោលការណ៍មូលដ្ឋាននៃនីតិរដ្ឋប្រជាធិបតេយ្យផងដែរ។

#### ១.១.២.១.គោលការណ៍ឯករាជ្យភាពនៃអំណាចតុលាការ

អំណាចតុលាការ គឺជាអំណាចឯករាជ្យ តាមរយៈមាត្រា១៣២ ថ្មីចែងថា ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យភាព នៃអំណាចតុលាការ។[8] ដោយសារការដោះស្រាយបណ្តឹងរដ្ឋប្បវេណី គឺជាមុខងារមួយរបស់អង្គការតុលាការ ដែលអំណាចតុលាការគ្របដណ្តប់ទៅលើរឿក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។[9] ចៅក្រមគឺជាតួអង្គដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងតុលាការ ត្រូវអនុវត្តសិទ្ធិអំណាចរបស់ខ្លួនដោយឯករាជ្យពី

[5] អ៊ីវ ប៉ូលី "នីតិវិធីរដ្ឋប្បវេណី" (មេរៀនសង្ខេប, សាកលវិទ្យាល័យបញ្ញាសាស្ត្រ, គ្មានកាលបរិច្ឆេទ), ២៤។

[6] អ៊ីវ ប៉ូលី "នីតិវិធីរដ្ឋប្បវេណី" (មេរៀនសង្ខេប, សាកលវិទ្យាល័យបញ្ញាសាស្ត្រ, គ្មានកាលបរិច្ឆេទ២៥។

[7] អ៊ីវ ប៉ូលី "នីតិវិធីរដ្ឋប្បវេណី" (មេរៀនសង្ខេប, សាកលវិទ្យាល័យបញ្ញាសាស្ត្រ, គ្មានកាលបរិច្ឆេទ),២៥។

[8] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣, មាត្រា១៣២ ថ្មី កថាខណ្ឌទី១។

[9] រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣, មាត្រា១២៨ ថ្មី កថាខណ្ឌទី៣។

ការអន្តរាគមន៍នានា ពីសំណាក់អាជ្ញាធររដ្ឋ។ លើសពីនេះទៅទៀត ចៅក្រមត្រូវទទួលការធានានៅក្នុងមុខងាររបស់ខ្លួន គឺមិនអាចត្រូវគេដកពីមុខងារបានទេ លើកលែងតែក្នុងករណីដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយឧត្តមប្រឹក្សានៃអង្គចៅក្រមសម្រេចដាក់វិន័យ។[10] ឯករាជ្យភាពនៃអង្គការតុលាការ និងការធានានៅក្នុងមុខងាររបស់ចៅក្រមនេះ គឺជាផ្នែកមួយនៃគោលការណ៍មូលដ្ឋាននានានៃនីតិវិធីរដ្ឋប្បវេណី ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ។

### ១.១.២.២.គោលការណ៍នៃការជម្រះក្ដីតាមច្បាប់

ការជម្រះក្ដីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមជាប្រជារាស្ត្រខ្មែរតាមនីតិវិធី និងច្បាប់ជាធរមាន។[11] មានន័យថា ការជម្រះក្តីធ្វើឡើងតាមច្បាប់ដែលអនុម័តដោយរដ្ឋសភា ដែលជាតំណាងរបស់ប្រជាពលរដ្ឋកម្ពុជា ដែលជាម្ចាស់នៃប្រទេសកម្ពុជា ហើយការជម្រះក្ដីមិនត្រូវធ្វើតាមទំនើងចិត្តរបស់ចៅក្រមឡើយ។ ហេតុនេះហើយអាចបកស្រាយបានថា នីតិវិធីនៃការជម្រះក្ដី ក៏ត្រូវធ្វើតាមច្បាប់ដែរ។ ដោយសារថា គោលការណ៍នៃការជម្រះក្ដីតាមច្បាប់ត្រូវយកទៅអនុវត្តនៅក្នុងនីតិវិធីរដ្ឋប្បវេណី។ គោលការណ៍នេះក៏ត្រូវបានចាត់ទុក ថាជាគោលការណ៍មូលដ្ឋានមួយនៃនីតិវិធីរដ្ឋប្បវេណី ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញដែរ។ ហេតុនេះហើយ ទើបក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានអនុម័តឡើងតាមតម្រូវការរបស់រដ្ឋធម្មនុញ្ញ។

### ១.១.២.៣.គោលការណ៍នៃការធានាសិទ្ធិទាមទារឲ្យសាកសួរ និងសវនការ

ដោយសារថា ភាគីនៃបណ្ដឹងរដ្ឋប្បវេណី ត្រូវអនុវត្តទៅតាមសេចក្ដីសម្រេចរបស់តុលាការ ហេតុនេះហើយប្រសិនបើសេចក្ដីសម្រេចនោះមិនមានភាពត្រឹមត្រូវទេ វាអាចនឹងបំពានសិទ្ធិរបស់បុគ្គលឯកជន ដោយមិនសមហេតុផល។ ហេតុដូច្នេះហើយទើបក្រមនីតិវិធីរដ្ឋប្បវេណីផ្ដល់ការធានាដល់សិទ្ធិនីតិវិធីយ៉ាងច្រើនរបស់ភាគីនៃបណ្ដឹងរដ្ឋប្បវេណីដើម្បីឲ្យពួកគេអាចចូលរួមនៅក្នុងដំណើរការរឿងក្ដី និងអាចការពារផលប្រយោជន៍របស់ខ្លួនបាន។ សិទ្ធិដែលមានសារៈសំខាន់ជាមូលដ្ឋាន នៅក្នុងចំណោមសិទ្ធិនីតិវិធីនានាទាំងនោះអាចហៅជាសរុបបានថា«សិទ្ធិមូលដ្ឋាននៃនីតិវិធី»។ ក្នុងចំណោមសិទ្ធិមូលដ្ឋាននៃនីតិវិធីដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី សិទ្ធិនីតិវិធីដែលសំខាន់ជាងគេបំផុត គឺសិទ្ធិទាមទារឲ្យសាកសួរ។ សិទ្ធិទាមទារឲ្យសាកសួរ គឺជាសិទ្ធិទាមទារឲ្យមានការធានានូវឱកាសក្នុងការបញ្ចេញមតិយោបល់របស់ខ្លួនដែលពាក់ព័ន្ធនឹងបញ្ហាដែលត្រូវសម្រេចដោយសេចក្ដីសម្រេចរបស់តុលាការនៅក្នុងបណ្ដឹងរដ្ឋប្បវេណី និងក្នុងការឆ្លើយតបទៅនឹងមតិភាគីម្ខាងទៀតត្រូវតែ ផ្ដល់ឲ្យនៅមុនពេលសម្រេចសេចក្ដី។ ប៉ុន្តែក្នុងករណីពិសេសបន្ទាន់ ការសម្រេចសេចក្ដីអាចត្រូវបានធ្វើឡើងជាមុន ហើយក្រោយមកទើបអនុញ្ញាតឲ្យស្ដាប់មតិយោបល់របស់ភាគី ដែលបានទទួលរងនូវការខូចប្រយោជន៍ដោយសារការសម្រេចសេចក្ដីបែបនេះបាន។

---

[10]រដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣, មាត្រា១៣៣ ថ្មី។

[11]រដ្ឋធម្មនុញ្ញ ថ្ងៃ ឆ្នាំ១៩៩៣, មាត្រា១២៩ ថ្មី កថាខណ្ឌទី៣។

### ១.១.២.៤.គោលការណ៍ចំពោះមុខ

ដើម្បីធានានូវសិទ្ធិទាមទារឲ្យសាកសួរ ឲ្យមានប្រសិទ្ធិភាព ការជម្រះក្តីត្រូវតែធ្វើឡើងដោយកោះហៅភាគីទាំងសងខាងឲ្យមកបង្ហាញខ្លួននៅកាលបរិច្ឆេទតែមួយ ហើយត្រូវឲ្យភាគីប្រឈមមុខដាក់គ្នាដោយផ្ទាល់។ ប្រសិនបើអនុញ្ញាតឲ្យតុលាការអាចកោះហៅភាគីតែម្ខាង ហើយស្តាប់ការអះអាងរបស់ភាគីនោះ ដោយពុំមានវត្តមានរបស់ភាគីម្ខាងទៀត នោះអាចនឹងប៉ះពាល់ទៅដល់ទំនុកចិត្តរបស់ភាគីទៅលើយុត្តិធម៌ នៃការវិនិច្ឆ័យ។ ហេតុនេះហើយបានជាមានបញ្ញត្តិចែងថា ជាគោលការណ៍តុលាការត្រូវវិនិច្ឆ័យដោយគោរពតាមគោលការណ៍ចំពោះមុខ ពោលគឺត្រូវកោះហៅភាគីទាំងសងខាង ឲ្យភាគីទាំងសងខាងថ្លែងអំពីអំណះអំណាងរបស់ខ្លួន និងជជែកតតាំងគ្នាទៅវិញទៅមក។[12]

### ១.១.២.៥.គោលការណ៍នៃការទទួលខុសត្រូវរបស់តុលាការ និងភាគី

ក្នុងនាមជាអ្នកគ្រប់គ្រងនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវប្រឹងប្រែងធានាឲ្យបានថារឿងក្តីរដ្ឋប្បវេណីត្រូវប្រព្រឹត្តឡើងដោយភាពយុត្តិធម៌ និងឆាប់រហ័ស។ នេះជាកាតព្វកិច្ច ជាមូលដ្ឋានដ៏ចម្បងបំផុតរបស់តុលាការ។ ដោយឡែក ចំពោះភាគីវិញក្នុងខណៈដែលពួកគេត្រូវបានអនុញ្ញាតឲ្យអនុវត្តបណ្តឹងតាមឆន្ទៈរបស់ខ្លួនដើម្បីឈ្នះក្តីតែពួកគេត្រូវបានហាមឃាត់មិនឲ្យអនុវត្តបណ្តឹងដោយមិនស្មោះត្រង់ និងដោយសុចរិតចំពោះភាគីម្ខាងទៀតឡើយ។[13]សកម្មភាពបណ្តឹងដែលត្រូវបានចាត់ទុកថាមិនមានភាពស្មោះត្រង់ ត្រូវកំណត់ទៅតាមករណីជាក់ស្តែងនីមួយៗ នៅក្នុងនីតិវិធីរដ្ឋប្បវេណី មានចែងនូវបញ្ញត្តិពាក់ព័ន្ធទៅនឹងអានុភាពមិនអំណោយផលមួយចំនួន ដែលកើតចេញពីការមិនគោរពកាតព្វកិច្ច អនុវត្តសកម្មភាពបណ្តឹងដោយស្មោះត្រង់ និងសុចរិត។

### ១.១.២.៦.ភាសាដែលប្រើក្នុងតុលាការ និងសិទ្ធិរបស់ភាគីក្នុងការស្នើសុំឲ្យមានអ្នកបកប្រែ

នៅក្នុងតុលាការត្រូវប្រើភាសាខ្មែរ ជាភាសាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា ហើយភាគីដែលមិនអាចយល់ភាសាខ្មែរបាន អាចស្នើសុំអ្នកបកប្រែដែលមានលក្ខណគ្រប់គ្រាន់។ លើសពីនេះទៅទៀតបើនៅក្នុងករណីដែលភាគីមិនមានលិទ្ធភាពជួលអ្នកបកប្រែដែលមានលក្ខណៈសម្បត្តិទេ ដោយមូលហេតុថាគាត់ពុំស្គាល់អ្នកបកប្រែដែលមានលក្ខណៈសម្បត្តិជាអាទិ៍ គឺតុលាការត្រូវផ្តល់អ្នកបកប្រែដែលមានលក្ខណៈឲ្យភាគីនោះ។[14] នៅពេលដែលភាគីណាមិនអាចយល់លើភាសាខ្មែរបាន ភាគីនោះពុំអាចថ្លែងពីអំណះអំណាងរបស់ខ្លួនបាន និងពុំអាចតតាំងចំពោះការអះអាងរបស់ភាគីម្ខាងទៀតឡើយ។ ក្នុងន័យនេះ បញ្ញត្តិដែលចែងថាភាគី

[12] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា៣ កថាខណ្ឌទី២។

[13] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា៤។

[14] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា៥។

នោះអាចជួលអ្នកបកប្រែដោយខ្លួនឯង ឬបើពុំអាចទៅរួចទេតុលាការ ត្រូវផ្ដល់អ្នកបកប្រែឲ្យភាគីនោះអាចចាត់ទុកជាផ្នែកមួយនៃសិទ្ធិរបស់ភាគីក្នុងការទាមទារឲ្យសាកសួរ។

**១.១.២.៧.ការចូលរួមរបស់តំណាងអយ្យការ**

ក្នុងករណីដែលយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការថាពាក្យបណ្ដឹងត្រូវបានទទួល។ ទោះបីជា គ្មានពាក្យជូនដំណឹងដែលបានកំណត់នៅក្នុងចំណុចខាងលើនេះពីតុលាការក៏ដោយ ក៏តំណាងអយ្យការអាចចូលរួមក្នុងនីតិវិធីនៃបណ្ដឹងរដ្ឋប្បវេណី និងបញ្ចេញយោបល់បានដែរ ប្រសិនបើខ្លួនយល់ថា ចាំបាច់ត្រូវការពារប្រយោជន៍សាធារណៈ។[15] ទោះបីជាយ៉ាងណាក៏ដោយ ការចូលរួមរបស់តំណាងអយ្យការ ត្រូវបានកម្រិតត្រឹមតែរឿងក្ដីណាដែលមានភាពចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈតែប៉ុណ្ណោះ។ គួរកត់សម្គាល់ថា នៅក្នុងករណីដែលភាគីជាអនីតិជន គឺអ្នកតំណាងដែលច្បាប់បានកំណត់ ដូចជាអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាល ជាអាទិ៍ដែលត្រូវដើរតួនាទីជាអ្នកការពារសិទ្ធិក្នុងនីតិវិធីរបស់ភាគី មិនមែនតំណាងអយ្យការឡើយ។

**១.១.២.៨.គោលការណ៍ផ្សេងៗទៀតនៃការជម្រះក្ដី**

បន្ថែមពីលើគោលការណ៍នានាដែលបានរៀបរាប់ខាងលើ មានគោលការណ៍ផ្សេងៗទៀតជាច្រើនពាក់ព័ន្ធទៅនឹងការជម្រះក្ដី ដូចជាគោលការណ៍នៃការទាញហេតុផល គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី និងគោលការណ៍នៃការសម្រេចសេចក្ដីដោយផ្អែកលើភស្តុតាងជាអាទិ៍។

## ១.២.ភាពចាំបាច់នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ដើម្បីជួយសម្រួលដល់ការជម្រះក្ដីនៅក្នុងនីតិវិធីទាញហេតុផល មិនឲ្យមានភាពស្មុគស្មាញដោយការលើកអង្គហេតុផ្សេងៗដែលគ្មានសារៈសំខាន់ចំពោះរឿងក្ដី។ ម្យ៉ាងទៀតនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក៏មានសារៈប្រយោជន៍ ដើម្បីផ្ដល់សមភាព និងភាពយុត្តិធម៌ដល់ភាគីនៃវិវាទតាមរយៈ ការជួបផ្ទាល់នៅពេលតែមួយ កន្លែងតែមួយដើម្បីធ្វើការអះអាងអំពីការដាក់អង្គហេតុ និងដាក់ភស្តុតាងជូនតុលាការ។

### ១.២.១.ការកំណត់កាលបរិច្ឆេទនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ការរៀបចំពាក្យបណ្ដឹង ជាដំណាក់កាលសំខាន់សម្រាប់ភាគីដើមចោទ ពីព្រោះពាក្យបណ្ដឹង គឺជាឯកសារផ្ទុកនូវការទាមទារតាមផ្លូវបណ្ដឹងរបស់ដើមចោទ។ នៅពេលដាក់ពាក្យបណ្ដឹង តុលាការត្រូវធ្វើការជម្រះក្ដី និងចេញសាលក្រមដោយការទាញហេតុផលផ្ទាល់មាត់។ ជាគោលការណ៍ រដ្ឋត្រូវចំណាយដើម្បីធានាសិទ្ធិពឹងពាក់តុលាការរបស់បុគ្គល។ ដោយសារបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងផលប្រយោជន៍បុគ្គលឯកជន ដូចនេះ

[15]ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦,មាត្រា៦។

ភាគីត្រូវទទួលបន្ទុកនូវចំនួនណាមួយនៃចំណាយសម្រាប់កិច្ចការបណ្ដឹង។[16]ហេតុនេះភាគីដែលដាក់ពាក្យបណ្ដឹងមានកាតព្វកិច្ច បង់ប្រាក់ប្រដាប់ក្ដី ដើម្បីចូលជាថវិការដ្ឋ និងជាសោហ៊ុយក្នុងការចំណាយលើនីតិវិធី។ បន្ទាប់ពីការដាក់ពាក្យបណ្ដឹងរួចរាល់ហើយ ដើម្បីជៀសវាងនូវការយឺតយ៉ាវក្នុងការដោះស្រាយវិវាទ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក្នុងអំឡុងពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃដែលដាក់ពាក្យបណ្ដឹងត្រូវបានដាក់ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស។ ការកំណត់បែបនេះ គឺចេញអំពីការគិតគូរដែលថា ចុងចម្លើយនឹងមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំការការពារខ្លួន និង ការចាប់ផ្ដើមនីតិវិធីនឹងមិនមានភាពយឺតយ៉ាវ។[17]

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន។ ដោយយោងទៅតាមការគោរពគោលការណ៍ចំពោះមុខ (មាត្រា៣ សិទ្ធិទាមទារឲ្យសាកសួរគោលការណ៍ចំពោះមុខ កថាខណ្ឌទី២) តុលាការត្រូវធានាការបើកឱកាសឲ្យភាគីទាំងសងខាងចូលរួមក្នុងការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (ដែលហៅថា ការធ្វើជាសាធារណៈចំពោះភាគី)[18]។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន ទោះបីជាភាគីម្ខាងអវត្តមានក៏ដោយក្នុងករណីដែលតុលាការបានបញ្ជូនដីកាកោះ និងបានផ្ដល់ឱកាសឲ្យភាគីនោះបង្ហាញខ្លួនហើយ។

កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈ។ ប៉ុន្តែតុលាការត្រូវអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ឃើញថា សមរម្យចូលស្ដាប់ជាអ្នកសង្កេតការណ៍បាន។ ការអនុញ្ញាត ឬមិនអនុញ្ញាតឲ្យអ្នកសង្កេតការណ៍ចូលស្ដាប់ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ។ ដោយតុលាការ ត្រូវពិចារណាអំពីមូលហេតុនៃការស្នើសុំចូលស្ដាប់ ព្រមទាំងមតិរបស់ភាគីផងដែរ។

### ១.២.២.ការកោះហៅ និងដាក់ឯកសារត្រៀម

ដើម្បីដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលុះណាតែ នៅពេលដែលពាក្យបណ្ដឹងត្រូវបានដាក់ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងរហ័ស និងកោះហៅគូភាគីដើម្បីឲ្យភាគីទាំងសងខាងអាចចូលរួមនីតិវិធី ដែលជាការធានានូវគោលការណ៍ចំពោះមុខ។

#### ១.២.២.១.ប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធ

នៅពេលដើមចោទដាក់ពាក្យបណ្ដឹង ចាំបាច់ត្រូវបងពន្ធដាក់ពាក្យសុំដែលមានចំនួនប្រាក់ដោយគណនា

[16]គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, ២០០៩, សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៩ (ពីពេលនេះតទៅហៅថា សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៩)។

[17] សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ នីតិវិធីបណ្ដឹង ឆ្នាំ២០០៨,៧៦។

[18] សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្ដឹង ឆ្នាំ២០០៨, ៧៥។

ទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹងដែលបានកំណត់។[19] ក្នុងករណីដើមចោទមិនបង់ពន្ធពាក្យសុំ តុលាការត្រូវបង្គាប់ឲ្យបង់ដោយកំណត់ពេលសមរម្យ ប្រសិនបើដើមចោទមិនបង់តាមការកំណត់ទេតុលាការត្រូវលើកពាក្យបណ្ដឹងចោលដោយដីការសម្រេច។[20]

បន្ទាប់ពីបង់ពន្ធដាក់ពាក្យសុំ ដើមចោទក៏ត្រូវបង់ប្រាប់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ។ ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពន្ធ គឺជាប្រាក់ប្រដាប់ក្ដីតុលាការដែលភាគី ឬបុគ្គលដែលទាក់ទង់នឹងរឿងក្ដី ត្រូវបង់ប្រាក់ប្រដាប់ក្ដីជាមុនសម្រាប់ការចំណាយរបស់តុលាការដែលធ្វើសកម្មភាពនៅក្នុងនីតិវិធីបណ្ដឹងរដ្ឋប្បវេណី ដូចជាចំនួនប្រាក់ចាំបាច់សម្រាប់ការពិនិត្យភស្ដុតាង ការបញ្ជូនឯកសារ សោហ៊ុយសម្រាប់ធ្វើដំណើរ ស្នាក់នៅរបស់ចៅក្រម ក្រឡាបញ្ជី ក្នុងការពិនិត្យភស្ដុតាង ស្រាវជ្រាវអង្គហេតុ សាកសួរសាក្សីដែលប្រព្រឹត្តនៅក្រៅតុលាការ។ ចំពោះប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ តុលាការត្រូវបង្គាប់ឲ្យភាគី ឬបុគ្គលដែលទាក់ទងរឿក្ដីបង់ចំនួនប្រាក់ជាមុនសិន។[21] នៅពេលដាក់ពាក្យបណ្ដឹង ដើមចោទតែងតែត្រូវតម្រូវឲ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធមួយចំនួនជាមុនសម្រាប់ធ្វើការបញ្ជូនពាក្យបណ្ដឹង ឯកសារផ្សេងៗ ដីកាកោះ និងសោហ៊ុយផ្សេងៗទៀតដែលចាំបាច់ ហើយអាចប៉ាន់ប្រមាណបានចំនួនទឹកប្រាក់នឹងត្រូវបានកំណត់តាមសភាពជាក់ស្ដែង។ ប្រសិនបើដើមចោទពុំបានបង់នូវប្រាក់សម្រាប់បញ្ជូនពាក្យបណ្ដឹងទុកជាមុនទេ[22] តុលាការត្រូវលើកពាក្យបណ្ដឹងចោលដោយដីកាសម្រេច។ ម៉្យាងទៀតប្រសិនបើដើមចោទ មិនព្រមបង់ប្រាក់ចាំបាច់សម្រាប់ការកោះហៅភាគីឲ្យចូលឆ្លើយតាមកាលបរិច្ឆេទតាមការបង្គាប់របស់តុលាការទេ តុលាការអាចលើកបណ្ដឹងចោលដោយដីកាសម្រេចប្រសិនបើចុងចម្លើយគ្មានការតវ៉ា។[23]

### ១.២.២.២.ការកោះហៅ

ការបើកឱកាសឲ្យភាគីទាំងសងខាង ចូលរួមបង្ហាញខ្លួនក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺត្រូវបានកំណត់តាមកាលបរិច្ឆេទដែលធ្វើដោយតុលាការ។ ការកោះហៅតាមកាលបរិច្ឆេទ ដែលត្រូវធ្វើដោយបញ្ជូនដីកាកោះ ឬដោយការជូនដំណឹងអំពីកាលបរិច្ឆេទទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្ដឹងដែលពាក់ព័ន្ធ។[24] វិធីកោះហៅអាចធ្វើតាម៖

- ការជូនដំណឹងអំពីកាលបរិច្ឆេទ គឺជាវិធីដែលមានលក្ខណៈទូលាយ និងងាយស្រួលជាងនីតិវិធីនៃការបញ្ជូន។ ចំពោះការជូនដំណឹង អំពីកាលបរិច្ឆេទទៅអ្នកដែលបានបង្ហាញខ្លួននៅតុលាការចំពោះបណ្ដឹងដែលពាក់ព័ន្ធ

[19] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៥៩ កថាខណ្ឌទី១។

[20] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៧៨ កថាខណ្ឌទី១ វាយ្យខណ្ឌទី២។

[21] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៩, មាត្រា៦២។

[22] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៧៩ កថាខណ្ឌទី២។

[23] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៨២កថាខណ្ឌទី១។

[24] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២៤២។

មានន័យថាតុលាការត្រូវប្រាប់ដោយផ្ទាល់មាត់អំពីកាលបរិច្ឆេទនោះ។ ក្រៅពីនេះមាននីតិវិធីផ្សេងទៀតដែលងាយស្រួលដូចជា ធ្វើការប្រកាសតាមទូរស័ព្ទ អ៊ីម៉ែល ប្រៃសនីយ៍ តាមសំបុត្រធម្មតា តាមរយៈបុគ្គលិកនៃការិយាល័យមេធាវីជាដើម ដើម្បីឲ្យអ្នកត្រូវទទួលការបញ្ជូនបានដឹង ហើយក្នុងនោះនីតិវិធីនៃការបញ្ជូន ក៏ជាមធ្យោបាយមួយនៃការជូនដំណឹងផងដែរ។[25]

- ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹង ចំពោះភាគី និងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍។ ប៉ុន្តែនីតិវិធីនេះត្រូវធ្វើឡើងតាមច្បាប់កំណត់ ដោយត្រូវតែមានរបាយការណ៍ស្តីពីការបញ្ជូន។ ស្ថាប័នដែលធ្វើការបញ្ជូនមានមន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន និងមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន។[26]

មន្ត្រីរដ្ឋបាលទទួលកិច្ចការបញ្ជូនគឺ ក្រឡាបញ្ជី។ មុខងាររបស់មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន គឺការធ្វើឬការផ្តល់សេចក្តីបញ្ជាក់នូវឯកសារសម្រាប់ប្រើក្នុងការបញ្ជូន ហើយប្រគល់អំណាចនៃការបញ្ជូនឯកសារនោះទៅឲ្យមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ហើយបន្ទាប់មក ទទួលរបាយការណ៍នៃការបញ្ជូនពីមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូន ក្រោយការប្រតិបត្តិ ហើយធ្វើការរក្សារបាយការណ៍នោះជាមួយនឹងសំណុំរឿងជាដើម។

មន្ត្រីរដ្ឋបាលទទួលបន្ទុកប្រតិបត្តិការបញ្ជូន មានដូចជា មន្ត្រីប៉ុស្តិ៍ប្រៃសនីយ៍ អាជ្ញាសាលា ក្រឡាបញ្ជី។ មុខងាររបស់មន្ត្រីរដ្ឋបាលទទួលបន្ទុកប្រតិបត្តិការបញ្ជូន គឺការបញ្ជូនជាក់លាក់ចំពោះជនដែលត្រូវទទួល ការធ្វើរបាយការណ៍អំពីការបញ្ជូន ហើយដាក់របាយការណ៍នោះទៅតុលាការ ជាដើម។ ឯកសារដែលត្រូវបញ្ជូនគឺជាឯកសារចម្លង លើកលែងតែករណីដែលបានកំណត់ពិសេសដោយច្បាប់។[27]

### ១.២.២.៣.ការដាក់ឯកសារត្រៀម

តុលាការ ជាសមត្ថកិច្ចដែលមានសិទ្ធិអំណាចក្នុងការបង្គាប់ឲ្យភាគីធ្វើការដាក់ឯកសារត្រៀមរបស់ដើមចោទ និងចុងចម្លើយ ទៅតាមកាលបរិច្ឆេទ។ គោលបំណងនៃឯកសារនេះ គឺឲ្យតុលាការ និងភាគីម្ខាងទៀតពិចារណាឲ្យបានគ្រប់គ្រាន់អំពីខ្លឹមសារនៃសេចក្តីថ្លែងការណ៍នេះ និងត្រៀមខ្លួនចូលក្នុងកាលបរិច្ឆេទដើម្បីតតាំងប្រព្រឹត្តទៅបានរលូន។ បន្ទាប់ពីតុលាការធ្វើការពិនិត្យពាក្យបណ្តឹងអំពីភាពត្រឹមត្រូវតាមលក្ខខណ្ឌហើយតុលាការបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ និងកំណត់កាលបរិច្ឆេទចាប់ផ្តើមនីតិវិធីត្រៀមទាញហេតុផល។ ជាការឆ្លើយតបនឹងពាក្យបណ្តឹងតុលាការបង្គាប់ឲ្យចុងចម្លើយដាក់ឯកសារចម្លើយ ហើយដើមចោទដាក់ឯកសារត្រៀមលើកទី១ដើម្បីតទល់នឹងអះអាងរបស់ចុងចម្លើយវិញ។

---

[25] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៩ ,មាត្រា២៤២។

[26] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ នីតិវិធីបណ្តឹង ឆ្នាំ២០០៨,១១៨។

[27] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ នីតិវិធីបណ្តឹង ឆ្នាំ២០០៨,១១៩។

**ក.ឯកសារចម្លើយ**

បន្ទាប់ពីតុលាការបានធ្វើការពិនិត្យពាក្យបណ្តឹង ក្នុងករណីដែលពាក្យបណ្តឹងនោះមានភាពត្រឹមត្រូវតាមលក្ខខណ្ឌទម្រង់តុលាការត្រូវបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ។[28] ចុងចម្លើយ ធ្វើការដាក់ឯកសារចម្លើយតាមបង្គាប់របស់តុលាការ។ ឯកសារចម្លើយ គប្បីដាក់ទៅតុលាការមុនពេលចាប់ផ្តើមនីតិវិធីត្រៀមទាញហេតុផល ក្នុងអំឡុងពេលដែលតុលាការបានកំណត់[29] (តុលាការបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយដោយភ្ជាប់ជាមួយនឹង ដីកាសម្រេចកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង និងដីកាសម្រេចបង្គាប់ឲ្យដាក់ឯកសារចម្លើយដោយកំណត់អំឡុងពេលសមរម្យ)។ ការដាក់ឯកសារចម្លើយ មុនពេលចាប់ផ្តើមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចឲ្យតុលាការដឹងថាអង្គហេតុណាខ្លះជាអង្គហេតុមានវិវាទ ឬគ្មានវិវាទ។ ការដាក់ ឬមិនដាក់ឯកសារចម្លើយ មិនមែនជាចំណុចដាច់ខាតនោះទេ ទោះជាមានការបង្គាប់ពីតុលាការឲ្យដាក់ក៏ដោយ យ៉ាងណាមិញឯកសារចម្លើយ មានគោលបំណងធ្វើឲ្យតុលាការ និងភាគីអាចសម្រេចនូវការជម្រះក្តីមួយប្រកបដោយប្រសិទ្ធិភាពនៅក្នុងកាលបរិច្ឆេទដែលបានកំណត់ ពោលគឺតុលាការមានភាពងាយស្រួល និងឆាប់រហ័សក្នុងការរៀបចំការអះអាងរបស់ភាគី ចំណុចវិវាទ និងភស្តុតាង។[30] ចំណុចដែលត្រូវសរសេរនៅក្នុងឯកសារចម្លើយ គឺការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារនៅក្នុងពាក្យបណ្តឹង ការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និងអង្គហេតុតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង។

- ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារនៅក្នុងពាក្យបណ្តឹង នៅក្នុងចំណុចនេះ ចុងចម្លើយត្រូវធ្វើការឆ្លើយតបចំពោះការទាមទាររបស់ដើមចោទ៖

១. ក្នុងករណីចុងចម្លើយមិនទទួលស្គាល់ការទាមទាររបស់ដើមចោទទាំងស្រុង នៅក្នុងឯកសារចម្លើយត្រូវសរសេរ «ច្រានចោលការទាមទារទាំងអស់របស់ដើមចោទ»។

២. ប្រសិនបើចុងចម្លើយទទួលស្គាល់ការទាមទាររបស់ដើមចោទ នៅក្នុងឯកសារចម្លើយត្រូវសរសេរ «ទទួលស្គាល់ការទាមទាររបស់ដើមចោទ»។[31]

- ការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង ចំណុចនេះ គឺជាការឆ្លើយតបចំពោះអង្គហេតុដែលបានសរសេរនៅក្នុងពាក្យបណ្តឹង។ ការឆ្លើយតបចំពោះអង្គហេតុមានដូចខាងក្រោម៖

១.ការឆ្លើយទទួលស្គាល់អង្គហេតុ

[28] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៧៩ កថាខណ្ឌទី១

[29] អ៊ីវ ប៉ូលី និងទេព បូផល ,កម្រងមេរៀន ឆ្នាំ២០២០, (ភ្នំពេញ៖ កញ្ញា, ២០២១), ៨៣ និង៨៤។

[30] អ៊ីវ ប៉ូលី និងទេព បូផល ,កម្រងមេរៀន ឆ្នាំ២០២០, (ភ្នំពេញ៖ កញ្ញា, ២០២១), ៨៦។

[31] អ៊ីវ ប៉ូលី និងទេព បូផល ,កម្រងមេរៀន ឆ្នាំ២០២០, (ភ្នំពេញ៖ កញ្ញា, ២០២១), ៨៤។

២.ការឆ្លើយមិនទទួលស្គាល់អង្គហេតុ

៣.ការឆ្លើយមិនដឹង

៤.ការមិនឆ្លើយអ្វីទាំងអស់

- អង្គហេតុតវ៉ា គឺជាអង្គហេតុដែលស្របនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ហើយអានុភាពគតិយុត្តនៃអង្គហេតុតវ៉ា នាំឲ្យអានុភាពគតិយុត្តដែលកើតពីមូលហេតុនៃការទាមទារត្រូវបានរារាំង រលត់ និងទប់ស្កាត់។[32]ទោះបីជាចុងចម្លើយ បានអះអាងអង្គហេតុតវ៉ាដែលនាំឲ្យ សិទ្ធិទាមទាររបស់ដើមចោទត្រូវរារាំង រលត់ ឬទប់ស្កាត់ការអនុវត្តសិទ្ធិក៏ដោយ តុលាការមិនអាចជឿបានទេថា អង្គហេតុដែលចុងចម្លើយបានអះអាងជាការពិត ឬមិនពិតនោះទេ ក្នុងករណីនេះចុងចម្លើយត្រូវធ្វើការបញ្ជាក់អង្គហេតុដោយភស្តុតាង។

**ខ.ឯកសារត្រៀម**

ឯកសារត្រៀម ជាឯកសារផ្ទុកនូវចំណុចដាក់លាក់សម្រាប់ការពារការទាមទារតទល់រវាងភាគី[33] គឺជាឯកសារដែលភាគីនីមួយៗដាក់ជូនតុលាការ និងភាគីម្ខាងទៀតក្នុងគោលបំណងជូនដំណឹងអំពីចំណុចដែលខ្លួននឹងធ្វើសេចក្តីថ្លែងការណ៍នៅកាលបរិច្ឆេទបន្ទាប់។ ការដាក់ឯកសារត្រៀមនេះគឺ មានសារៈសំខាន់ដើម្បីឲ្យតុលាការអាចរៀបចំសេចក្តីអះអាងរបស់ភាគី បំភ្លឺចំណុចវិវាទ និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តី។ ចំណុចដែលត្រូវសរសេរនៅក្នុងឯកសារត្រៀម ផ្អែកតាមមាត្រា១០១ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឯកសារត្រៀម ត្រូវសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ និងការពារខ្លួនរបស់ភាគីម្ខាងទៀត។ ការសរសេរអំពីសេចក្តីថ្លែការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាងទៀត គឺជាការសរសេរអំពីការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង ឬជាការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះអង្គហេតុប្រយោលដែលភាគីម្ខាងទៀតបានអះអាង។ ចំណែកការសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួនគឺជាការសរសេរពីអង្គហេតុតវ៉ាតប (អង្គហេតុតវ៉ាតបម្តងទៀត)ជាអាទិ៍ និងភស្តុតាង ព្រមទាំងអង្គហេតុប្រយោល និងភស្តុតាង (ករណីពុំមានភស្តុតាងដោយផ្ទាល់ដើម្បីបញ្ជាក់អង្គហេតុតវ៉ាតប ឬអង្គហេតុតវ៉ាតបជាអាទិ៍)។[34]

[32] អ៊ីវ ប៉ូលី និងទេព បូផល ,កម្រងមេរៀន ឆ្នាំ២០២០, (ភ្នំពេញៈ កញ្ញា, ២០២១), ៨៤។

[33]សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៩, មាត្រា១០១។

[34] អ៊ីវ ប៉ូលី និងទេព បូផល ,កម្រងមេរៀន ឆ្នាំ២០២០, (ភ្នំពេញៈ កញ្ញា, ២០២១), ១៣២។

# ជំពូកទី២

# ការចាប់ផ្តើមនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

# ជំពូកទី២

# ការចាប់ផ្ដើមនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

បន្ទាប់ពីបានបកស្រាយទៅលើសញ្ញាណទូទៅនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលខាងលើរួចមក នៅចំណុចបន្តទៅនេះនឹងមានការបកស្រាយទៅលើការចាប់ផ្ដើមនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដែលមាន២ផ្នែកដូចជា៖ ការសាកល្បងផ្សះផ្សា(២.១) សកម្មភាពនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (២.២)។

## ២.១.ការសាកល្បងធ្វើការផ្សះផ្សា

ការសាកល្បងផ្សះផ្សា អាចធ្វើបានទោះបីជាបណ្ដឹងស្ថិតក្នុងដំណាក់កាលណាក៏ដោយ។ ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថាមិនសមរម្យ។[35] មានន័យថាតុលាការត្រូវធ្វើការផ្សះផ្សាជាបឋមនៅពេលធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល លើកលែងតែរឿងក្ដីដែលបានកំណត់ ឬករណីពិសេសណាមួយ។ គោលការណ៍នៃការផ្សះផ្សាជាមុនដាច់ខាត ត្រូវជំនួសដោយគោលការណ៍នៃការផ្សះផ្សា ដែលមានលក្ខណៈមិនដាច់ខាតវិញ។[36] ដោយនីតិវិធីរដ្ឋប្បវេណីមានគោលបំណងធ្វើការកំណត់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងកាតព្វកិច្ចតាមច្បាប់សារធាតុ ដែលអាចចាត់ចែងបានដោយផ្អែកលើការព្រមព្រៀងរវាងភាគី។ ដូច្នេះទោះបីជាពេលដែលនីតិវិធីបណ្ដឹងត្រូវចាប់ផ្ដើមហើយក៏ដោយ ប្រសិនបើភាគីកំណត់ថាសិទ្ធិ ឬកាតព្វកិច្ចនោះមាន ឬគ្មានអត្ថិភាពតាមរយៈការសះជា ហើយភាគីសម្រេចបញ្ចប់វិវាទនោះ គេអាចនិយាយបានថាវាជាលិទ្ធផលដែលគួរឲ្យចង់បាន។ ប៉ុន្តែមានករណីដែលវិវាទមិនអាចបញ្ចប់ទៅបានដោយសារតែការព្រមព្រៀងរបស់ភាគីពោល គឺសិទ្ធិចាត់ចែងរបស់ភាគីតាមឆន្ទៈត្រូវបានកម្រិតអាស្រ័យដោយផលប្រយោជន៍ទូទៅរបស់សង្គម ឬសណ្ដាប់ធ្នាប់សាធារណៈ ឬសកម្មភាពចាត់ចែងនោះសង្គមទទួលយកបាន ឬករណីដែលគ្មានសង្ឃឹមថាភាគីនឹងធ្វើការព្រមព្រៀង តុលាការមិនត្រូវធ្វើការផ្សា ឬមិនត្រូវផ្សះផ្សាឡើយ។

### ២.១.១. ការធ្វើសេចក្ដីថ្លែងការណ៍

ក្នុងករណីដែលការផ្សះផ្សាមិនអាចសម្រេចបាន តុលាការបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយឲ្យគូភាគីធ្វើសេចក្ដីថ្លែងការណ៍។ ការអនុវត្តន៍ជាក់ស្ដែងភាគី ឬអ្នកតំណាងដោយអាណត្តិ រៀបចំឯកសារដាក់ទៅតុលាការដើម្បីពិនិត្យលើកិច្ចនីតិវិធី និងធ្វើសេចក្ដីថ្លែងការណ៍ដោយផ្ទាល់មាត់នៅពេលជំនុំជម្រះ ។

[35] ក្រមនីតិវិធីរដ្ឋប្បវេណីនៃ ឆ្នាំ២០០៦, មាត្រា១០៤។

[36] សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្ដឹង ឆ្នាំ២០០៨, ៧៨។

### ២.១.១.១. ការធ្វើសេចក្តីថ្លែងការណ៍របស់ដើមចោទ

ការទាមទាររបស់ដើមចោទត្រូវបានបង្ហាញឲ្យឃើញនៅក្នុងលិខិតនៃពាក្យបណ្តឹងដែលបានដាក់ទៅតុលាការ ហើយតុលាការត្រូវឲ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍ផ្ទាល់មាត់នូវខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ អង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង និងអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារ។ ការធ្វើសេចក្តីថ្លែងការណ៍ផ្ទាល់មាត់ ចាំបាច់ត្រូវធ្វើនៅកាលបរិច្ឆេទ ដោយធ្វើសេចក្តីថ្លែងការណ៍សារធាតុអំពីខ្លឹមសារនៃឯកសារនានាដោយផ្ទាល់មាត់។

នៅពេលចុងចម្លើយដាក់ឯកសារចម្លើយដើម្បីឆ្លើយតបចំពោះពាក្យបណ្តឹង ដើមចោទបានដាក់ឯកសារឆ្លើយតបចំពោះឯកសារចម្លើយ។ ដើម្បីឆ្លើយតបចំពោះការអះអាង ដែលបានសរសេរនៅក្នុងឯកសារចម្លើយ ដើមចោទត្រូវដាក់ឯកសារត្រៀម ហៅថាឯកសារត្រៀមលើកទី១ របស់ដើមចោទ ឬហៅថា សេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ដើមចោទ។ នៅក្នុងឯកសារត្រៀមលើកទី១ របស់ដើមចោទត្រូវសរសេរអំពីសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាងទៀត ពោលគឺ ដើមចោទត្រូវធ្វើការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះមធ្យោបាយតទល់ឬការពារខ្លួនរបស់ចុងចម្លើយ(អង្គហេតុតវ៉ា) ដែលបានសរសេរនៅក្នុងឯកសារចម្លើយ។[37] ក្រៅពីការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះអង្គហេតុតវ៉ា ឬអង្គហេតុប្រយោលដែលបានសរសេរនៅក្នុងឯកសារចម្លើយ ដើមចោទត្រូវអះអាងអំពីអង្គហេតុតវ៉ាតប (មធ្យោបាយតទល់ ឬការពារខ្លួន) ដើម្បីឆ្លើយតបនឹងអង្គហេតុតវ៉ាដែលបានអះអាងដោយចុងចម្លើយ។ អង្គហេតុតវ៉ាតប (អង្គហេតុចម្បង) ជាអង្គហេតុដែលត្រូវនឹងលក្ខខណ្ឌគតិយុត្ត នាំឲ្យមូលហេតុដែលកើតឡើងពីអង្គហេតតវ៉ាត្រូវរារាំង រលត់ ឬទប់ស្កាត់។[38] ម៉្យាងទៀតដើមចោទ ត្រូវធ្វើការបញ្ជាក់អង្គហេតុតវ៉ាតបដោយភស្តុតាង ដើម្បីឲ្យតុលាការអាចទទួលស្គាល់អង្គហេតុនោះបាន។[39] ក្នុងករណី ពុំមានភស្តុតាងផ្ទាល់ដើម្បីបញ្ជាក់ពីអង្គហេតុតវ៉ាតបទេ ដើមចោទត្រូវអះអាងអង្គហេតុប្រយោល និងបញ្ជាក់ភស្តុតាងចំពោះអង្គហេតុនោះ ក្នុងគោលបំណងឲ្យតុលាការអាចទទួលស្គាល់អង្គហេតុផ្ទាល់បាន។

### ២.១.១.២. ការធ្វើសេចក្តីថ្លែងការណ៍របស់ចុងចោទ

ក្រោយពីដើមចោទបានធ្វើការទាមទារដូចមាននៅក្នុងពាក្យបណ្តឹង ចុងចម្លើយចាប់ផ្តើមធ្វើការឆ្លើយតបតាមរយៈការធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់។ចុងចម្លើយគម្បីដាក់ឯកសារត្រៀមលើកដំបូងទៅតុលាការ

[37] អ៊ីវ ប៉ូលី និងទេព បូផល ,កម្រងមេរៀន ឆ្នាំ២០២០, (ភ្នំពេញ៖ កញ្ញា ២០២១),១៣៣។

[38] អ៊ីវ ប៉ូលី និងទេព បូផល ,កម្រងមេរៀន ឆ្នាំ២០២០, (ភ្នំពេញ៖ កញ្ញា ២០២១), ១៣៦។

[39] អ៊ីវ ប៉ូលី និងទេព បូផល ,កម្រងមេរៀន ឆ្នាំ២០២០, (ភ្នំពេញ៖ កញ្ញា ២០២១), ១៣៦។

ដោយសរសេរអំពីការឆ្លើយតបចំពោះ ខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរទាមទារនៅក្នុងពាក្យបណ្តឹង ការទទួលស្គាល់ឬមិនទទួលស្គាល់អង្គហេតុដែលបានសរសេរនៅក្នុងពាក្យបណ្តឹង និងអង្គហេតុតវ៉ាជាអាទិ៍[40] ដែលចុងចម្លើយនឹងថ្លែងការណ៍នៅកាលបរិច្ឆេទ។ ប្រសិនបើចុងចម្លើយមិនបានដាក់ឯកសារចម្លើយទេ ការឆ្លើយតបចំពោះពាក្យបណ្តឹង ចុងចម្លើយអាចធ្វើឡើងនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង តាមរយៈសេចក្តីថ្លែងការណ៍ផ្ទាល់មាត់។

ដើម្បីការពារទៅនឹងការទាមទាររបស់ដើមចោទនៅក្នុងឯកសារត្រៀមលើកទី១ របស់ដើមចោទ ដាក់ឯកសារត្រៀមលើកទី១ របស់ចុងចម្លើយ។ ដើម្បីឆ្លើយតបចំពោះការអះអាង ដែលបានសរសេរនៅក្នុងឯកសារត្រៀមលើកទី១របស់ដើមចោទ ក្នុងការឆ្លើយតបចុងចម្លើយត្រូវដាក់ឯកសារហៅថា ឯកសារត្រៀមលើកទី១ របស់ចុងចម្លើយ។ នៅក្នុងឯកសារត្រៀមលើកទី១ របស់ចុងចម្លើយ ត្រូវសរសេរអំពីសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាងទៀតពោលគឺ ចុងចម្លើយ ត្រូវធ្វើការទទួលស្គាល់ ឬមិនទទួលស្គាល់ ចំពោះមធ្យោបាយតទល់ ឬការពារខ្លួន របស់ដើមចោទ (អង្គហេតុតវ៉ាតប) និងទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះអង្គហេតុប្រយោលដែលបានសរសេរនៅក្នុងឯកសារត្រៀមលើកទី១ របស់ដើមចោទ។[41] ក្រៅពីការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះអង្គហេតុតវ៉ាតប ឬអង្គហេតុប្រយោល ដែលបានសរសេរក្នុងឯកសារត្រៀមលើកទី១ របស់ដើមចោទ ចុងចម្លើយ ត្រូវអះអាងអង្គហេតុតវ៉ាតប (អង្គហេតុតវ៉ាតបម្តងទៀត) ដើម្បីឆ្លើយតបនឹងអង្គហេតុតវ៉ាតប។ អង្គហេតុតវ៉ាតប (អង្គហេតុចម្បង) ជាអង្គហេតុដែលត្រូវនឹងលក្ខខណ្ឌគតិយុត្ត នាំឲ្យមូលហេតុដែលកើតឡើងពីអង្គហេតុតវ៉ា ត្រូវរារាំង រលត់ ឬទប់ស្កាត់។[42] ចុងចម្លើយត្រូវធ្វើការបញ្ជាក់អង្គហេតុនេះដោយភស្តុតាង ដើម្បីឲ្យតុលាការអាចទទួលស្គាល់អង្គហេតុតវ៉ាតបបាន។ ក្នុងករណី ពុំមានភស្តុតាងដើម្បីបញ្ជាក់អង្គហេតុតវ៉ាតបទេ ចុងចម្លើយត្រូវអះអាងអង្គហេតុប្រយោល និងបញ្ជាក់ភស្តុតាងចំពោះអង្គហេតុប្រយោលនោះក្នុងគោលបំណងឲ្យតុលាការទទួលស្គាល់អង្គហេតុផ្ទាល់បាន។

### ២.១.២.ការដឹកនាំរៀបចំ និងកំណត់

#### ២.១.២.១ ការរៀបចំការអះអាងរបស់ភាគី

កម្មវត្ថុនៃបណ្តឹង គឺជាសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលដើមចោទបានអះអាងក្នុងការទាមទារតាមផ្លូវបណ្តឹង។ ប៉ុន្តែដើម្បីឲ្យតុលាការអាចធ្វើការសម្រេចសេចក្តី អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនោះបាន ត្រូវតែមានការបំភ្លឺអំពីទំនាក់ទំនងអង្គហេតុនៃរឿងដោយធ្វើការអះអាងរបស់ភាគី។

[40]អ៊ីវ ប៉ូលី និងមេធាវី ទេព បូផល ,កម្រងមេរៀន ឆ្នាំ២០២០, កញ្ញា ២០២១, ៨៤។

[41]អ៊ីវ ប៉ូលី និងមេធាវី ទេព បូផល ,កម្រងមេរៀន ឆ្នាំ២០២០, កញ្ញា ២០២១, ១៣៨។

[42]អ៊ីវ ប៉ូលី និងទេព បូផល ,កម្រងមេរៀន ឆ្នាំ២០២០, កញ្ញា ២០២១, ១៤១។

នៅក្នុងការអះអាងរបស់ភាគី ភាគីនឹងធ្វើការអះអាងនូវអង្គហេតុទាំងអស់ដោយពុំគិតពីអង្គហេតុមាន ឬគ្មានប្រយោជន៍ឡើយដូចនេះតុលាការ ត្រូវរៀបចំការអះអាងរបស់ភាគីដោយរៀបចំនូវចំណុចដែលភាគីមានទំនាស់ ឬវិវាទនឹងគ្នា និងឲ្យភាគីធ្វើការបំភ្លឺនូវចំណុចវិវាទនោះដោយដកការអះអាងអំពីអង្គហេតុដែលមិនមានប្រយោជន៍ចំពោះការសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិដែលជាកម្មវត្ថុនៃបណ្តឹង និងលុបចោលនូវអង្គហេតុទាំងឡាយណាដែលភាគីធ្វើការអះអាងដូចគ្នាចាត់ទុកថាជាអង្គហេតុពុំដែលមានវិវាទ។ នៅពេលភាគីណាម្ខាងអះអាងអំពីអត្ថិភាពនៃអង្គហេតុណាមួយ ក្រមនីតិវិធីរដ្ឋប្បវេណីបែងចែកអាកប្បកិរិយារបស់ភាគីម្ខាងទៀតជាបួនប្រភេទដូចខាងក្រោម៖

(១) ភាគីម្ខាងទៀតនោះអាចធ្វើសេចក្តីថ្លែងការណ៍បដិសេធនូវអត្ថិភាពនៃអង្គហេតុនោះ ដែលការធ្វើបែបនេះគេហៅថា ការបដិសេធ (ការមិនទទួលស្គាល់)ត្រូវធ្វើការបញ្ជាក់ដោយភស្តុតាង

(២) ភាគីនោះអាចធ្វើសេចក្តីថ្លែងការណ៍ទទួលស្គាល់នូវអត្ថិភាពនៃអង្គហេតុនេះ ដែលគេហៅថាការសារភាព ករណីនេះមិនចាំបាច់បញ្ជាក់ភស្តុតាងទេ[43]

(៣) ភាគីនោះអាចធ្វើសេចក្តីថ្លែងការណ៍ថាខ្លួនមិនបានដឹងអំពីអត្ថិភាពនៃអង្គហេតុនោះទេ ដែលការធ្វើបែបនេះគេហៅថា សេចក្តីថ្លែងការណ៍អំពីការមិនបានដឹង ត្រូវចាត់ទុកថាការតវ៉ាអំពីអង្គហេតុត្រូវបញ្ជាក់ដោយភស្តុតាង

(៤) ចុងក្រោយគេ គឺករណីដែលភាគីនោះមិនឆ្លើយអ្វីទាំងអស់ ត្រូវបានសន្មត់ថាជាការសារភាពចំពោះអង្គហេតុ។

### ២.១.២.២. ការរៀបចំចំណុចវិវាទ

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់ ពេលដែលភាគីបានដាក់មធ្យោបាយតទល់ ឬការពារខ្លួន ពេលនោះតុលាការត្រូវអនុវត្តសិទ្ធិបំភ្លឺ និងរៀបចំមធ្យោបាយតទល់ ឬការពារខ្លួននោះជាពិសេសត្រូវរៀបចំការអះអាងពីភាគីទាំងសងខាង ដើម្បីកំណត់នូវចំណុចវិវាទពិតប្រាកដនៃរឿងក្តី ហើយតុលាការត្រូវរៀបចំនូវភស្តុតាងពាក់ពន្ធ័នឹងចំណុចវិវាទដែលត្រូវធ្វើការពិនិត្យក្នុងការទាញហេតុផលផ្ទាល់មាត់។ ជាទូទៅចំណុចទាំងឡាយណាដែលភាគីសងខាងប្រកែកគ្នា(អង្គហេតុ) គេហៅថាចំណុចវិវាទ។

ចំណុចវិវាទ ជាចំណុចដែលភាគីទាំងពីរមានទំនាស់នឹងគ្នា។ តុលាការ មិនអាចសម្រេចពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទនងគតិយុត្តតាមរយៈការអះអាងរបស់ភាគីនោះទេ។ ហេតុនេះ តុលាការ ធ្វើការកំណត់នូវចំណុចវិវាទ នៃរឿងក្តីតាមរយៈការបង្គាប់ឲ្យភាគីធ្វើការបំភ្លឺអំពីអង្គហេតុផ្សេងៗ ដែលពាក់ព័ន្ធទៅនឹង

[43] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា១២៣ កថាខណ្ឌទី២។

អង្គហេតុដែលជាមូលហេតុផ្ទាល់នៃការបង្កើតសិទ្ធិ ដែលដើមចោទបានអះអាង។ ចំណុចវិវាទត្រូវបានកំណត់ និងទទួលស្គាល់រួមគ្នាដោយតុលាការ និងភាគីទាំងសងខាង។[44]

### ២.១.២.៣. ការរៀបចំភស្តុតាង

ភស្តុតាងដែលត្រូវពិនិត្យ គឺប្រែប្រួលទៅតាមអ្វីដែលជាចំណុចវិវាទ។[45] ជាគោលការណ៍ការពិនិត្យភស្តុតាងត្រូវធ្វើឡើងតាមការស្នើសុំឲ្យពិនិត្យរបស់ភាគី។[46] ចំពោះភស្តុតាងដែលអាចទទួលមកពិនិត្យនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន គឺមានតែភស្តុតាងជាឯកសារតែប៉ុណ្ណោះ។[47] ចំណែកភស្តុតាងជាសាក្សី ភាគីអាចស្នើសុំនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះបាន ប៉ុន្តែច្បាប់មិនបានអនុញ្ញាតឲ្យមានការសាកសួរសាក្សីនៅដំណាក់កាលណាឡើយ គឺត្រូវដាក់ស្នើសុំទៅក្នុងនីតិវិធីការទាញហេតុផលផ្ទាល់មាត់។

#### ក.ការស្នើសុំឲ្យពិនិត្យភស្តុតាង

ភាគីដែលស្នើសុំឲ្យពិនិត្យភស្តុតាង ត្រូវកំណត់ឲ្យបានជាក់លាក់ នូវអង្គហេតុដែលត្រូវធ្វើការបញ្ជាក់។ ភាគីដែលបានស្នើសុំឲ្យពិនិត្យភស្តុតាង គប្បីបំភ្លឺឲ្យបានច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និងទំនាក់ទំនងរវាងអង្គហេតុ និងភស្តុតាង។ ការស្នើសុំឲ្យពិនិត្យភស្តុតាង ក៏អាចធ្វើមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានដែរ។ ចំពោះការស្នើសុំឲ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវធ្វើឡើងដោយផ្តល់ឯកសារដែលសាមីភាគីមាន ឬដោយដាក់ពាក្យសុំដោយតុលាការបង្គាប់ឲ្យម្ចាស់ឯកសារផ្តល់ឯកសារនោះ។ ភាគីដែលបានស្នើសុំពិនិត្យភស្តុតាងជាឯកសារត្រូវបញ្ជាក់ថា ឯកសារនោះធ្វើឡើងដោយត្រឹមត្រូវ រីឯឯកសារឯកជនដែលសន្មត់ថាធ្វើឡើងដោយត្រឹមត្រូវ ជាឯកសារដែលមានចុះហត្ថលេខាសាមីភាគី ឬអ្នកតំណាង។

#### ខ.ការទទួលយកភស្តុតាង

តុលាការត្រូវពិនិត្យភស្តុតាងដែលភាគីបានស្នើសុំឲ្យពិនិត្យ។[48] បន្ទាប់ពីស្នើសុំពិនិត្យភស្តុតាង តុលាការនឹងសម្រេចទទួលយក ឬមិនទទួលយកនូវការស្នើសុំភស្តុតាងរបស់ភាគីតាមរយៈដីកាសម្រេច។ ការចេញដីកាសម្រេចខុសពីសាលក្រមដោយដីកាសម្រេចមិនចាំបាច់ធ្វើជាលាយលក្ខណ៍អក្សរក៏បានដែរឲ្យតែបានជូនដំណឹងដល់ភាគីតាមវិធីដែលអាចទទួលស្គាល់ថាសមរម្យ។ ករណីក្នុងការអនុវត្តជាក់ស្តែង ការចេញដីកាសម្រេចតុលាការតែងតែធ្វើឡើងដោយផ្ទាល់មាត់ ដោយជូនដំណឹងអំពីការសម្រេចនេះនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែម្តង។ ពេលជូនដំណឹងអំពីដីកាសម្រេច តុលាការនឹងបង្គាប់

---

[44] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង ឆ្នាំ២០០៨, ៨៤។

[45] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង ឆ្នាំ២០០៨, ៨៥។

[46] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា១២៤ កថាខណ្ឌទី១។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា១០៦។

[48] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១២៦ កថាខណ្ឌទី១។

ឲ្យក្រឡាបញ្ជី បញ្ជាក់ឲ្យបានច្បាស់លាស់នូវហេតុការណ៍ និងវិធីជូនដំណឹងនោះ នៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីដាក់ចូលសំណុំរឿង។

## ២.២. សកម្មភាពនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ក្នុងករណី ការផ្សះផ្សាមិនសម្រេចទេតុលាការត្រូវចាប់ផ្ដើមសកម្មភាពនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយចាប់ផ្ដើមដំណើរការនីតិវិធីទៅតាមដំណាក់ការ។

### ២.២.១. ការដាក់មធ្យោបាយតទល់ ឬការពារ

#### ២.២.១.១.អត្ថន័យ

មធ្យោបាយតទល់ គឺជាមធ្យោបាយដែលដាក់ដោយដើមចោទ (សេចក្ដីថ្លែងការណ៍របស់ដើមចោទ) ចំណែកមធ្យោបាយការពារខ្លួន គឺជាមធ្យោបាយដែលដាក់ដោយចុងចម្លើយ (សេចក្ដីថ្លែងការណ៍របស់ចុងចម្លើយ)។ មធ្យោបាយតទល់ ឬការពារខ្លួនត្រូវដាក់ឲ្យតុលាការនៅពេលណាមួយដែលសមរម្យទៅតាមដំណើរការនៃបណ្ដឹង។[49]

នៅក្នុងមធ្យោបាយតទល់  ជាដំបូងដើមចោទធ្វើសេចក្ដីថ្លែងការណ៍នូវការអះអាងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលជាការទាមទារតាមផ្លូវបណ្ដឹង។ ប៉ុន្តែដោយសារអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិជាក់លាក់ណាមួយមិនអាចទទួលស្គាល់ដោយផ្ទាល់បាន ហេតុនេះហើយតុលាការត្រូវប្រើប្រាស់នូវវិធីធ្វើសេចក្ដីសន្និដ្ឋានតាមដានតាមភាពសមហេតុផល ដើម្បីធ្វើការកំណត់នូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិនោះ។ តុលាការត្រូវវិនិច្ឆ័យថាតើសិទ្ធិនោះបានកើតឡើងឬទេ ឬសិទ្ធិនោះធ្លាប់បានកើតឡើង តែត្រូវបានរលត់ដោយហេតុត្រូវនឹងលក្ខខណ្ឌគតិយុត្តនៃការរលត់សិទ្ធិដែលឬទេ។ ការវិនិច្ឆ័យធ្វើឡើងក្នុងគោលបំណង កំណត់អត្ថិភាពនៃសិទ្ធិនាពេលបច្ចុប្បន្ន ឬនត្ថិភាពនៃសិទ្ធិនោះ។ ហេតុនេះដើម្បីឲ្យតុលាការសម្រេចថាសិទ្ធិដែលជាខ្លឹមសារទាមទាររបស់ដើមចោទមានអត្ថិភាព ដើមចោទត្រូវធ្វើការអះអាងអំពីអង្គហេតុមួយឆ្លើយតបនឹងលក្ខខណ្ឌតាមផ្លូវច្បាប់ ដើម្បីឲ្យសិទ្ធិនោះមានអានុភាពតាមផ្លូវច្បាប់។[50]

នៅក្នុងមធ្យោបាយការពារ គឺជាសេចក្ដីថ្លែងការណ៍ ដែលអះអាងតបចំពោះមូលហេតុនៃការទាមទាររបស់ដើមចោទ។ ក្នុងករណីខ្លះទោះបីជាអង្គហេតុ ដែលបានលើកឡើងដោយដើមចោទមានពិតប្រាកដមែនក៏ដោយ ប៉ុន្តែប្រសិនបើមានអង្គហេតុដែលនាំឲ្យរលត់សិទ្ធិ (នត្ថិភាពនៃសិទ្ធិ) ដូចជាការសង ការទូទាត់ ឬអាជ្ញាយុកាលនៃការរលត់សិទ្ធិត្រូវបានសម្រេចជាអាទិ៍។ ការអះអាងរបស់ចុងចម្លើយនេះ គឺជាមធ្យោបាយការពារខ្លួនរបស់ចុងចម្លើយ ដែលគេអាចហៅបានថាជាការតវ៉ា។[51]

---

[49] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា៩៣។

[50] សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្ដឹង ឆ្នាំ២០០៨, ៨០។

[51] ហ៊ី សោភា សៀវភៅស្ដីអំពី នីតិវិធីរដ្ឋប្បវេណី,២០០៧, ៦៣។

ជាទូទៅការទាមទារ របស់ដើមចោទត្រូវបង្ហាញឲ្យឃើញនៅក្នុងលិខិតនៃពាក្យបណ្តឹង។ ចំណែកឯកសារចម្លើយ ឆ្លើយតបចំពោះការទាមទាររបស់ដើមចោទ ត្រូវបានដាក់ដោយចុងចម្លើយ។ បន្ទាប់ពីបានដាក់ពាក្យសុំលើអង្គសេចក្តីនៃរឿងក្តីហើយ ដើមចោទនឹងធ្វើនូវសេចក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួនហៅថាមធ្យោបាយតទល់។ រីឯចុងចម្លើយ ក៏នឹងធ្វើសេចក្តីថ្លែងការណ៍គាំទ្រពាក្យសុំរបស់ខ្លួន ហៅថាមធ្យោបាយការពារខ្លួន។[52] សេចក្តីថ្លែងការណ៍ដែលជាមធ្យោបាយតទល់ ឬការពារខ្លួនអាចបែងចែកជាការដាក់ពាក្យសុំ និងសេចក្តីថ្លែងការណ៍ផ្សេងទៀតទៅតាមលក្ខណៈនៃសកម្មភាពរបស់ភាគី។ ការដាក់ពាក្យសុំ និងសេចក្តីថ្លែងការណ៍ផ្សេងទៀត ដែលភាគីបានធ្វើគេហៅថា «ការទាញហេតុផល»។ ពាក្យសុំ គឺជាសកម្មភាពរបស់ភាគីដែលទាមទារសុំ ឲ្យតុលាការធ្វើសកម្មភាពជាក់លាក់ណាមួយ ដូចជាការចេញសាលក្រម ក៏ដូចជាការចេញដីកាសម្រេច ការពិនិត្យភស្តុតាង និងការធ្វើសកម្មភាពចាំបាច់នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំជាអាទិ៍។ សេចក្តីថ្លែងការណ៍ សំដៅលើសកម្មភាពដែលតាមរយៈនោះភាគីធ្វើការរៀបរាប់ ឬផ្តល់នូវការយល់ឃើញ ឬមតិរបស់ខ្លួនទៅឲ្យតុលាការ។

**២.២.១.២.ពេលដែលត្រូវដាក់មធ្យោបាយតទល់ ឬការពារខ្លួន**

ភាគីត្រូវដាក់មធ្យោបាយតទល់ ឬការពារខ្លួនឲ្យតុលាការនៅពេលមួយដែលសមរម្យ ទៅតាមដំណើរការនៃបណ្តឹង។[53] ក្នុងករណីដែលមានមូលហេតុសមរម្យពិសេស ភាគីអាចដាក់មធ្យោបាយតទល់ ការពារខ្លួននៅពេលណាក៏បាន មុនពេលដែលការវិនិច្ឆ័យលើបណ្តឹងត្រូវបានបញ្ចប់ (មុនពេលដែលការទាញហេតុផលផ្ទាល់មាត់ត្រូវបានបញ្ចប់) ។ ប៉ុន្តែ ប្រសិនបើពុំមានមូលហេតុពិសេសទេភាគីត្រូវដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅពេលសមរម្យ ទៅតាមដំណាក់កាលនៃការជម្រះក្តី។ ពេលវេលាសមរម្យ សំដៅលើឱកាស ឬដំណាក់កាលនៅក្នុងនីតិវិធីដែលត្រូវបានសង្ឃឹមថា គួរដាក់មធ្យោបាយតទល់ឬការពារខ្លួន ដើម្បីដោះស្រាយវិវាទឲ្យបានលឿន និងត្រឹមត្រូវ។[54] ភាគីត្រូវដាក់មធ្យោបាយតទល់ ឬការពារខ្លួនទាំងអស់នៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ លើកលែងតែកាលៈទេសៈដែលមិនអាចដាក់បាន។ ដើម្បីឆ្លើយតបទៅនឹងការទាមទារនេះ ភាគីត្រូវធ្វើការស្រាវជ្រាវជាមុនឲ្យបានហ្មត់ចត់ អំពីទំនាក់ទំនងអង្គហេតុចំពោះសាក្សី ឬភស្តុតាងដទៃទៀត។[55] ហេតុនេះហើយ ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ជាគោលការណ៍ភាគីមិនអាចដាក់មធ្យោបាយតទល់ឬការពារខ្លួនថ្មីទៀតទេ នៅពេលធ្វើការទាញហេតុផល

[52] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងច្បាប់ក្រមនីតិវិធីរដ្ឋប្បវេណី ,២០០៨, សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង, ៨១, ភ្នំពេញ ៖ ក្រសួងយុត្តិធម៌។

[53] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ឆ្នាំ២០០៦, មាត្រា៩៣។

[54] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង ឆ្នាំ២០០៨, ៨២។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា៩២។

ដោយផ្ទាល់មាត់បានឡើយ។[56] ដូចនេះភាគីត្រូវដាក់ការអះអាងរបស់ខ្លួន ឬត្រូវឆ្លើយតបទៅនឹងការអះអាងរបស់ភាគីម្ខាងទៀត ហើយត្រូវធ្វើការស្នើសុំឲ្យពិនិត្យភស្តុតាងចំពោះអង្គហេតុដែលមានវិវាទ។ ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនដែលដាក់ទៅតុលាការយឺតយ៉ាវមិនត្រូវនឹងពេលសមរម្យដោយចេតនា ឬដោយកំហុសដ៏ធ្ងន់ធ្ងររបស់ភាគី តុលាការអាចចេញដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬការពារខ្លួននោះបានតាមពាក្យសុំរបស់ភាគីម្ខាងទៀត ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ព្រោះវាធ្វើឲ្យមានការយឺតយ៉ាវក្នុងការបញ្ចប់នីតិវិធីបណ្តឹង។ ក្នុងករណីដែលគោលគំនិត និងអត្ថន័យនៃមធ្យោបាយតទល់ ឬការពារខ្លួន ដែលភាគីបានដាក់មានភាពមិនច្បាស់លាស់ ហើយតុលាការបានទាមទារឲ្យបំភ្លឺ តែភាគីមិនផ្តល់ការបំភ្លឺចាំបាច់ ឬមិនបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់ឲ្យបំភ្លឺទេ តុលាការអាចលើកចោលនូវមធ្យោបាយតទល់ ឬការពារខ្លួននោះបាន។[57]

### ២.២.២. ការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង

ការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង គឺជាការផ្លាស់ប្តូរខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ឬអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារដែលបានសរសេរ នៅក្នុងពាក្យបណ្តឹងដោយដើមចោទ។ ក្រោយពេលដាក់ពាក្យហើយ តាមរយៈការផ្លាស់ប្តូរនេះត្រូវផ្លាស់ប្តូរសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលកម្មវត្ថុនៃបណ្តឹង ឬត្រូវផ្លាស់ប្តូរទំហំនៃការវិនិច្ឆ័យ និងចេញសាលក្រមអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តនោះ។ ដើមចោទអាចបន្ថែម ឬផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹងរហូតដល់ពេលចប់ការទាញហេតុផលផ្ទាល់មាត់បានលុះត្រាតែមិនមានការប្តូរមូលដ្ឋាននៃការទាមទារ។[58] ការបន្ថែមកម្មវត្ថុនៃបណ្តឹង គឺដើមចោទរក្សាទុកការទាមទារដើម ហើយបន្ថែមការទាមទារថ្មី។

ឧទាហរណ៍៖ ក្នុងបណ្តឹងទាមទារឲ្យចេញពីផ្ទះដោយសារមិនបង់ថ្លៃឈ្នួល ដើមចោទបន្ថែមការទាមទារប្រាក់សំណងការខូចខាតស្មើរ នឹងថ្លៃឈ្នួលរហូតដល់ពេលអ្នកជួលចេញពីផ្ទះនោះ។ ការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង គឺដើមចោទដកការទាមទារដើម ហើយដាក់ការទាមទារថ្មី។

ឧទាហរណ៍៖ ក្នុងបណ្តឹងទាមទារចេញពីផ្ទះដោយសារមិនបង់ថ្លៃឈ្នួល ប្រសិនបើមានអគ្គីភ័យឆេះផ្ទះអស់ដោយសារមានកំហុសរបស់ចុងចម្លើយ នៅពេលតុលាការកំពុងចាត់ការរឿងក្តីនេះ ដើមចោទផ្លាស់ប្តូរការទាមទាររបស់ខ្លួនទាំងស្រុង ទៅជាការទាមទារសំណងការខូចខាតដោយសារការបាត់បង់ផ្ទះ។

[56] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ , មាត្រា១០៨។

[57] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា៩៤ កថាខណ្ឌទី២។

[58] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៨៤ កថាខណ្ឌទី១ ។

ការបន្ថែម ឬការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។[59] ដោយសារតែនេះជាសារជាតុនៃ ការបន្ថែម ឬការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង គឺដូចជាការដាក់ពាក្យបណ្តឹងថ្មី។ ក្រឡាបញ្ជី ត្រូវបញ្ជូនឯកសារនេះទៅភាគីម្ខាងទៀត។[60] ប្រសិនបើការបន្ថែម ឬការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹងមានកង្វះនូវលក្ខខណ្ឌនៃការបន្ថែម ឬការផ្លាស់ប្តូរ តុលាការត្រូវចេញដីកាសម្រេចមិនយល់ព្រមនឹងការបន្ថែម ឬផ្លាស់ប្តូរបណ្តឹងតាមពាក្យសុំ ឬតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ ប្រសិនបើយល់ឃើញថាការបន្ថែម ឬការផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹងនោះស្របលក្ខខណ្ឌតុលាការត្រូវធ្វើការវិនិច្ឆ័យការទាមទារថ្មីនោះ ហើយចេញសាលក្រម។

### ២.២.៣. សកម្មភាពបណ្តឹងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចធ្វើសកម្មភាពចាំបាច់នានាដើម្បីរៀបចំការអះអាងរបស់ភាគី ក៏ដូចជាកំណត់នូវចំណុចវិវាទ និងរៀបចំភស្តុតាងពាក់ពន្ធ័ទៅនឹងចំណុចវិវាទដែលត្រូវពិនិត្យនៅពេលទាញហេតុផលដោយផ្ទាល់មាត់ ហើយសកម្មភាពនោះដែរមិនចាំបាច់ធ្វើឡើង ដោយសាធារណៈនោះទេ។[61] មុននឹងចាប់ផ្តើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវពិគ្រោះជាមួយភាគីទាំងសងខាង ត្រូវរៀបចំសេចក្តីអះអាងរបស់ភាគី និងត្រូវបំភ្លឺចំណុចវិវាទ តាមវិធីសាស្រ្តដូចតទៅ ៖

- ស្នើឲ្យភាគីដកការអះអាង អំពីអង្គហេតុដែលមិនមានប្រយោជន៍ចំពោះការសម្រេចអំពីអត្ថិភាព និងនត្ថិភាពនៃសិទ្ធិ ដែលជាកម្មវត្ថុនៃបណ្តឹងដែលភាគីអះអាងដូចគ្នា ចំពោះចំណុចសារវន្តនៃការពិនិត្យភស្តុតាង ដោយចាត់ទុកថាអង្គហេតុពុំមានវិវាទ។
- ចំពោះភស្តុតាងតុលាការ ត្រូវធានាឲ្យបាននូវការពិនិត្យដោយសមូហវិធី ដោយត្រូវពិនិត្យដោយយកចិត្តទុកដាក់លើភស្តុតាងដែលមានតម្លៃ និងសំខាន់ប៉ុណ្ណោះ។

នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចចេញដីកាសម្រេចដែលទាក់ទងទៅនឹងការស្នើសុំឲ្យពិនិត្យភស្តុតាង ឬដីកាសម្រេចផ្សេងទៀតដែលអាចសម្រេចបានក្រៅពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និងអាចពិនិត្យភស្តុតាងជាឯកសារដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាង។[62] ឧទាហរណ៍៖ ដីកាសម្រេចថាទទួលយក ឬមិនទទួលយកភស្តុតាងដែលត្រូវបានស្នើសុំឲ្យពិនិត្យ ដីកាសម្រេចឲ្យធ្វើកោសលវិច្ឆ័យ ដីកាបង្គាប់ឲ្យផ្តល់ឯកសារ ព្រមទាំងឯកសារដែលក្រមនីតិវិធីរដ្ឋប្បវេណីអនុញ្ញាតឲ្យធ្វើក្រៅពីកាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់ដូចជា៖

[59] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៨៤ កថាខណ្ឌទី២។

[60] ក្រមនីតិវិធីរដ្ឋប្បវេណី កក្កដា ឆ្នាំ២០០៦, មាត្រា ៨៤ កថាខណ្ឌទី៣។

[61]សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង ឆ្នាំ២០០៨, ៨៤។

[62] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១០៦។

សេចក្តីសម្រេចអំពីការអនុញ្ញាត ឬមិនអនុញ្ញាតឲ្យធ្វើការបន្ថែម ឬផ្លាស់ប្តូរកម្មវត្ថុនៃបណ្តឹង[63] ដីកាសម្រេចអំពីការអនុញ្ញាត ឬមិនអនុញ្ញាតឲ្យចូលរួមអន្តរាគមន៍។[64]

**២.២.៣.១. បណ្តឹងតប**

បណ្តឹងតប គឺជាបណ្តឹងដែលចុងចម្លើយបានធ្វើឡើងចំពោះដើមចោទនៅក្នុងនីតិវិធីបណ្តឹង នៅពេលបណ្តឹងដែលដើមចោទកំពុងធ្វើកំពុងតែត្រូវបានចាត់ការដើម្បីធ្វើការទាមទារថ្មីលើពាក្យបណ្តឹងដើម។[65] ចុងចម្លើយ អាចប្តឹងតបទៅតុលាការដែលកំពុងចាត់ការទៅលើបណ្តឹងដើមរហូតដល់ចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះករណីដែលការទាមទារជាកម្មវត្ថុនៃបណ្តឹងតបនោះ ស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដទៃតាមច្បាប់ ឬករណីដែលបណ្តឹងតបនោះនឹងធ្វើឲ្យមានការយឺតយ៉ាវដល់នីតិវិធី។ បណ្តឹងតបនេះ អាចធ្វើទៅបានចំពោះតែនីតិវិធីដូចគ្នាតែប៉ុណ្ណោះ មិនអាចធ្វើឆ្លងនីតិវិធីបានឡើយ។ ចំពោះការធ្វើកំណត់ហេតុបណ្តឹងតប គឺត្រូវធ្វើផ្សេងគ្នាពីបណ្តឹងដើម។

**ក. លក្ខខណ្ឌនៃបណ្តឹងតប**

១. ការទាមទារនៃបណ្តឹងតប ចាំបាច់ត្រូវតែជាការទាមទារដែលត្រូវស្នើសុំឲ្យតុលាការធ្វើការវិនិច្ឆ័យ និងចេញសាលក្រមទៅលើនីតិវិធីបណ្តឹងប្រភេទដូចគ្នា ហើយការទាមទារនៃបណ្តឹងដើមដែលចាំបាច់ត្រូវមានលក្ខខណ្ឌទូទៅនៃការរួមបញ្ចូលនូវការទាមទារ ហើយការប្តឹងតបនោះមិនត្រូវបានហាមឃាត់។[66]

២.លុះត្រាតែបណ្តឹងដើម កំពុងត្រូវបានចាត់ការហើយត្រូវស្ថិតនៅមុនពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការវិនិច្ឆ័យលើអង្គហេតុ។[67] បើទោះបីជា នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់បានបញ្ចប់ក៏ដោយ ក៏ភាគីចុងចម្លើយអាចធ្វើបណ្តឹងតបបានដែរក្នុងករណីដែលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ ហើយកំពុងចាត់ការដោយតុលាការនៃបណ្តឹងឧទ្ធរណ៍។ ប៉ុន្តែ ដើម្បីធ្វើបណ្តឹងតបនៅក្នុងការជំនុំជម្រះចាំបាច់ត្រូវមានការយល់ព្រមពីភាគីដើមចោទផងដែរ។[68]

៣. ការទាមទារនៃបណ្តឹងតប ចាំបាច់ត្រូវមានទំនាក់ទំនងនឹងការទាមទារនៃបណ្តឹងដើម ឬមានទំនាក់ទំនងនឹងមធ្យោបាយការពារខ្លួនចំពោះការទាមទារនៃបណ្តឹងដើម។[69]

---

[63] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៨៤ កថាខណ្ឌទី៤។

[64] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៨៥ កថាខណ្ឌទី១។

[65] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង ឆ្នាំ២០០៨, ១៧៥។

[66] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២២៧។

[67] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៨៦ កថាខណ្ឌទី១។

[68] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២៧៦ កថាខណ្ឌទី១។

[69] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៨៦ កថាខណ្ឌទី១។

៤. ការទាមទារនៃបណ្ដឹងតប មិនត្រូវស្ថិតក្រោមសមត្ថកិច្ចផ្ដាច់មុខនៃតុលាការផ្សេងទៀត។

៥. នីតិវិធីបណ្ដឹងមិនមានការយឺតយ៉ាវខ្លាំង ដោយសារការដាក់បណ្ដឹងតប។ ចំពោះនីតិវិធីនៃការប្ដឹងតប ត្រូវអនុវត្តតាមបញ្ញត្តិស្ដីពីបណ្ដឹងដើម។

បណ្ដឹងតប គឺជាពាក្យសុំឲ្យតុលាការវិនិច្ឆ័យ និងចេញសាលក្រមចំពោះការទាមទារថ្មីនៅពេលបណ្ដឹងកំពុងចាត់ការ ដូចជាការបន្ថែម ឬការផ្លាស់ប្ដូរការទាមទារ។ ដូចនេះហើយ លក្ខខណ្ឌនៃបណ្ដឹងតបលក្ខខណ្ឌនៃបណ្ដឹងតប គឺត្រូវកំណត់ដូចគ្នានឹងលក្ខខណ្ឌនៃការបន្ថែម ឬផ្លាស់ប្ដូររបស់ដើមចោទដែរ។

### ខ. នីតិវិធីដាក់ពាក្យបណ្ដឹងតប

ចំពោះនីតិវិធីនៃការដាក់បណ្ដឹងតប ត្រូវអនុវត្តតាមបញ្ញត្តិស្ដីពីបណ្ដឹងដើម។[70] ក្នុងករណីដែលមិនស្របនឹងលក្ខណ្ឌនៃបណ្ដឹងតប តុលាការត្រូវបំបែករឿងក្ដីនោះ ហើយចាត់ចែងបណ្ដឹងតបជាបណ្ដឹងឯករាជ្យមួយបន្ទាប់មកធ្វើការជម្រះក្ដីដាច់ពីគ្នា។ ក្នុងករណីដែលស្របលក្ខខណ្ឌនៃបណ្ដឹងតប តុលាការត្រូវធ្វើការវិនិច្ឆ័យ និងចេញសាលក្រមអំពីបណ្ដឹងដើម និងបណ្ដឹងតបដោយនីតិវិធីដូចគ្នា។ បើសិនជាតុលាការផ្សេងមានសមត្ថកិច្ចផ្ដាច់មុខតុលាការត្រូវផ្ទេរបណ្ដឹងតបនេះទៅតុលាការនោះ។

## ២.២.៣.២.បណ្ដឹងទាមទារឲ្យបញ្ជាក់ ក្នុងដំណើរការពាក់កណ្ដាលទី

### ក. អត្ថន័យនៃបណ្ដឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី

បណ្ដឹងទាមទារឲ្យបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី គឺជាបណ្ដឹងទាមទារឲ្យបញ្ជាក់ ដែលត្រូវបានដាក់ដោយដើមចោទ ឬចុងចម្លើយនៅពេលបណ្ដឹងកំពុងត្រូវចាត់ការ ដើម្បីទាមទារឲ្យតុលាការចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលផ្សេងពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃបណ្ដឹង ហើយដែលជាមូលដ្ឋាននៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃបណ្ដឹងនោះ។[71] ឧទាហរណ៍៖ ពេលដែលកំពុងតែធ្វើការវិនិច្ឆ័យបណ្ដឹងទាមទារឲ្យប្រគល់វិញនូវវត្ថុ ដែលជាកម្មសិទ្ធិរបស់ដើមចោទ ប្រសិនបើមានវិវាទថាតើដើមចោទជាកម្មសិទ្ធិករ នៃកម្មវត្ថុនោះឬទេ? ពេលនោះដើមចោទបានធ្វើបណ្ដឹងមួយទាមទារការបញ្ជាក់កម្មសិទ្ធិ ឬចុងចម្លើយបានធ្វើបណ្ដឹងទាមទារ ការបញ្ជាក់នូវអត្ថិភាព ឬនត្ថិភាពរបស់ដើមចោទ នេះគឺជាករណីនៃបណ្ដឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្ដាលទី។

ក្នុងករណីដែលការសម្រេចសេចក្ដី អាស្រ័យលើអត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងគតិយុត្ត ដែលជាចំណុចវិវាទ ក្នុងដំណើរការពាក់កណ្ដាលទីដើមចោទអាចពង្រីកការទាមទារ ឬចុងចម្លើយអាចប្ដឹងតបដើម្បីអោយតុលាការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងគតិយុត្តដែលជាចំណុចវិវាទនៅក្នុងសាលក្រម។

[70] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៨៦ កថាខណ្ឌទី២។

[71] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៨៥។

បណ្តឹងនេះ គឺជាការបន្ថែមនូវកម្មវត្ថុនៃបណ្តឹងមួយប្រភេទ ប្រសិនបើដើមចោទប្តឹង។ ប៉ុន្តែបើចុងចម្លើយប្តឹង គឺជាបណ្តឹងតបមួយប្រភេទ មួយវិញទៀតច្បាប់ក៏បានកំណត់នូវលក្ខខណ្ឌ សម្រាប់ករណីពិសេសនៃការធ្វើបណ្តឹងតប ក៏ដូចជាការបន្ថែមបណ្តឹង។

### ខ. លក្ខខណ្ឌនៃបណ្តឹងទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី

បណ្តឹងអាចធ្វើទៅបាន លុះត្រាតែក្នុងលក្ខខណ្ឌដែលបណ្តឹងកំពុងត្រូវបានចាត់ការ ក្នុងការជំនុំជម្រះលើអង្គហេតុ ហើយស្ថិតនៅមុនដំណាក់កាលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ ហើយបណ្តឹងនោះត្រូវតែជាបណ្តឹងទាមទារឲ្យបញ្ជាក់នូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃបណ្តឹង[72] ដើម្បីជាមូលដ្ឋាននៃការវិនិច្ឆ័យ ហើយការទាមទារឲ្យបញ្ជាក់នោះមិនត្រូវស្ថិតក្រោមកម្មសិទ្ធិផ្តាច់មុខរបស់តុលាការដទៃទៀត។[73]

### គ.នីតិវិធីដាក់ពាក្យបណ្តឹង និងនីតិវិធីទាមទារការបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី

នៅក្នុងការរៀបចំពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី ភាគី ឬ អ្នកតំណាងក្នុងបណ្តឹងនេះ ត្រូវរៀបចំពាក្យបណ្តឹងតាមការបញ្ជាក់អំពីសិទ្ធិរបស់ខ្លួនក្នុងការទាមទារដោយបញ្ជាក់នូវអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលផ្សេងពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលជាកម្មវត្ថុនៃបណ្តឹងដែលបានដាក់នីតិវិធីបណ្តឹងមុននៃអង្គហេតុដែលជានីតិវិធីបណ្តឹងដើម ដែលបានទាញហេតុផលដោយផ្ទាល់មាត់បានបញ្ចប់។ ភាគី និងអ្នកតំណាងត្រូវរៀបចំពាក្យបណ្តឹងរបស់ខ្លួននៅពេលដែលខ្លួនយល់ថា សិទ្ធិរបស់ភាគីត្រូវបានបាត់បង់នៅពេលកិច្ចនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងដើម្បីត្រូវបានបញ្ចប់។

ការដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី នេះត្រូវបានរៀបចំធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយក្រឡាបញ្ជីត្រូវធ្វើការបញ្ជូនលិខិតនោះទៅឲ្យភាគីម្ខាងទៀត ។ [74]ការដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទីនេះ ភាគី ឬអ្នកតំណាងត្រូវរៀបចំក្នុងពាក្យបណ្តឹងនេះដោយភ្ជាប់ភស្តុតាង ឬសាក្សីជាក់លាក់។ ខ្លឹមសារក្នុងពាក្យត្រូវសរសេបញ្ជាក់អំពីខ្លឹមសារនៃការទាមទារអង្គហេតុចំបាច់នៃមូលហេតុនៃការទាមទារ និងសេចក្តីថ្លែងការណ៍បញ្ជាក់អំពីអង្គហេតុនៃការទាមទារក្នុងបណ្តឹងដើមដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ដល់តុលាការដើម្បីបញ្ជាក់បង្ហាញអំពីមូលហេតុដែលភាគី ឬអ្នកតំណាងទាមទារឲ្យតុលាការបញ្ជាក់អំពីសិទ្ធិរបស់ខ្លួនដែលជាផ្នែកនៃបណ្តឹងដើមនោះ។ ហេតុនេះហើយ ភាគី ឬអ្នកតំណាងត្រូវពិចារណាក្នុងការរៀបចំការអះអាងរបស់ខ្លួនដែលបញ្ជាក់អំពីនូវ

[72] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៨៥ កថាខណ្ឌទី១។

[73] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៨៥ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

[74] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៨៤ កថាខណ្ឌទី ២ និងកថាខណ្ឌទី៣ និងមាត្រា ៨៥ កថាខណ្ឌទី២។

អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលផ្សេងពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ភ្ជាប់ជាមួយភស្តុតាងសាក្សី ដោយជាក់លាក់ដាក់ជូនតុលាការដើម្បីពិនិត្យ ក្នុងការកំណត់នីតិវិធីអញ្ជើញអ្នកតំណាង ឬកោះហៅភាគីក្នុងកិច្ចនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ក្នុងបណ្តឹងនេះ បើតុលាការពិនិត្យទៅលើពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី ដែលភាគី ឬអ្នកតំណាងបានដាក់មកនេះមិនមាន ឬមានភស្តុតាងសាក្សី និងមូលហេតុនៃការទាមទារបញ្ជាក់អំពីអង្គហេតុមិនច្បាស់លាស់នោះទេ តុលាការពិនិត្យពិចារណាលើការលើកបណ្តឹងនេះចោល ឬបញ្ចូលបណ្តឹងនោះក្នុងបណ្តឹងដើមដែលភាគីបានធ្វើកិច្ចនីវិធីបានបញ្ចប់។

ក្រោយពេលដែលភាគី ឬអ្នកតំណាងក្នុងបណ្តឹងបានទទួលពាក្យបណ្តឹងនេះមក តុលាការនឹងរៀបចំនីតិវិធីទាញហេតុផលលើបណ្តឹងនេះតែម្តង ដោយមិនចាំបាច់រកចាំការរៀបចំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះឡើយ ដោយភាគី ឬអ្នកតំណាងដែលបានដាក់ពាក្យបណ្តឹងទាមទារឲ្យបញ្ជាក់ក្នុងដំណើរការពាក់កណ្តាលទី បានដាក់ពាក្យបណ្តឹងភ្ជាប់ជាមួយ ខ្លឹមសារនៃការទាមទារ អង្គហេតុចំបាច់នៃមូលហេតុនៃការទាមទារ និងសេចក្តីថ្លែងការណ៍បញ្ជាក់អំពីអង្គហេតុនៃការទាមទារក្នុងបណ្តឹងដើមដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នោះហើយ។

ដូច្នេះតុលាការរៀបចំការនីវិធីទាញហេតុផលដោយផ្ទាល់មាត់តែម្តង។ នៅក្នុងកិច្ចនីតិវិធីនេះផងដែរ តុលាការពេលដែលបញ្ចប់កិច្ចនីវិធីទាញហេតុផលដោយផ្ទាល់មាត់រួច តុលាការកំណត់កាលបរិច្ឆេទដើម្បីប្រកាសសាលក្រមតែម្តង។

### ២.២.៣.៣. ដីកាសម្រេច

ដីកាសម្រេច គឺជាសេចក្តីសម្រេចរបស់តុលាការ ឬចៅក្រមដែលអាចធ្វើបានដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ខុសពីសាលក្រម។ ដីកាសម្រេចដែលធ្វើឡើងដោយចៅក្រម សំដៅទៅលើដីកាសម្រេចរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះក្នុងករណី ដែលតុលាការជំនុំជម្រះរឿងក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ[75] និងដីកាសម្រេចរបស់ចៅក្រមដែលទទួលបញ្ជា ឬចៅក្រមដែលទទួលបានការប្រគល់សិទ្ធិ។[76]ដីកាសម្រេច អាចប្រើបានសម្រាប់ធ្វើការសម្រេចសេចក្តីអំពីចំណុចបន្ទាប់បន្សំតាមផ្លូវនីតិវិធី ដែលមិនមានពាក់ព័ន្ធសិទ្ធិ ឬកាតព្វកិច្ចភាគីតាមផ្លូវច្បាប់សារធាតុ ឬប្រើសម្រាប់ធ្វើការសម្រេចសេចក្តីទៅលើចំណុច ដែលតុលាការចាំបាច់ត្រូវធ្វើការសម្រេចសេចក្តីឲ្យបានទាន់ពេលវេលា។ ឧទាហរណ៍៖ ដីកាសម្រេចផ្ទេរ និង ដីកាសម្រេចលើកចោលពាក្យសុំផ្ទេរដែលអាចប្តឹងជំទាស់បានពាក្យសុំឲ្យមានការចូលរួមជួយអន្តរាគមន៍។ ការដកហូតចៅក្រម ឬ បណ្តឹងជិតចិត្តចំពោះចៅក្រម ក្រុមប្រឹក្សាជំនុំជម្រះនៅតុលាការដែលចៅក្រមនោះស្ថិតនៅក្រោម។

---

[75] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា៨៥។

[76] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១៣៦ កថាខណ្ឌទី២។

### ក. របៀបចេញដីកាសម្រេច

ដីកាសម្រេច គឺជាសេចក្ដីសម្រេចដែលអាចធ្វើឡើងដោយលាយលក្ខណ៍អក្សរក៏បាន ឬដោយផ្ទាល់មាត់ក៏បាន។ ដីកាសម្រេចអាចចេញដោយផ្អែកលើការវិនិច្ឆ័យទៅលើឯកសារដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន។ ប្រសិនបើ ដីកាសម្រេចនោះធ្វើឡើងដោយផ្ទាល់មាត់ដីកាសម្រេចនោះត្រូវកត់ត្រានៅក្នុងកំណត់ហេតុដើម្បីទុកបញ្ជាក់នៅថ្ងៃក្រោយ។ ការចេញដីកាសម្រេចដោយលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ គឺអាស្រ័យទៅលើករណីនីមួយៗទៅតាមឆន្ទានុសិទ្ធិរបស់ចៅក្រម ក្នុងករណីមួយចំនួនច្បាប់ក៏បានតម្រូវឲ្យដីកាសម្រេចមួយចំនួនត្រូវធ្វើជាលាយលក្ខណ៍អក្សរតែម្ដង ដូចជាដីកាសម្រេចឲ្យដាស់តឿនជាដើម។[77]ក្នុងករណីដែលចៅក្រមចេញដីកាសម្រេច ដោយលាយលក្ខណ៍អក្សរចៅក្រមនោះត្រូវចុះហត្ថលេខាលើដីកាសម្រេចនោះ។[78]

ជាគោលការណ៍ ការចេញដីកាសម្រេចគឺមិនចាំបាច់ឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះទេ ប៉ុន្តែតុលាការអាចអាចកោះហៅភាគី ដែលពាក់ព័ន្ធមកសាកសួរបាននៅកាលបរិច្ឆេទ[79]ពោលគឺភាគីអាចធ្វើសេចក្ដីថ្លែងការណ៍ដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរនូវចំណុចដែលភាគីចង់ឲ្យតុលាការធ្វើការសម្រេចសេចក្ដីដោយដីកាសម្រេច។

### ខ. អានុភាពនៃដីកាសម្រេច

ដីកាសម្រេចអាចមានអានុភាពបាន លុះត្រាតែត្រូវបានជូនដំណឹងតាមវិធីដែលអាចទទួលស្គាល់ថាសមរម្យ។[80] ដីកាសម្រេច ដែលធ្វើឡើងដោយផ្ទាល់មាត់ចំពោះមុខភាគីមានអានុភាពភ្លាមៗនៅពេលដែលចៅក្រមបានសម្រេចសេចក្ដីដោយដីកាសម្រេចនោះ។ ចំពោះដីកាសម្រេចដែលធ្វើឡើង ដោយលាយលក្ខណ៍អក្សរចៅក្រមដែលចេញដីកាសម្រេចនោះ ត្រូវចុះហត្ថលេខាលើសេចក្ដីសម្រេចនោះបន្ទាប់មកក្រឡាបញ្ជីត្រូវជូនដំណឹងដល់ភាគីពាក់ព័ន្ធ ដោយវិធីដែលតុលាការយល់ឃើញថាសមរម្យ ហើយពេលជូនដំណឹងក្រឡាបញ្ជីត្រូវបញ្ជាក់អោយបានច្បាស់លាស់អំពីហេតុការណ៍ដែលបានកើតឡើងក្នុងអំឡុងពេលសម្រេចសេចក្ដីទើបដីកាសម្រេចនោះមានអានុភាពទៅតាមផ្លូវច្បាប់។ ដីកាសម្រេច ដែលទាក់ទិនទៅនឹងការដឹកនាំនីតិវិធីនៃបណ្ដឹងអាចលុបចោលនៅពេលណាក៏បាន។[81]មានន័យថា ដីកាសម្រេចនេះគឺមានគោលបំណងត្រឹមចាត់ការដឹកនាំនីតិវិធីនៃបណ្ដឹង និងចាត់ចែងចំណុចបន្ទាប់បន្សំក្នុងការវិនិច្ឆ័យបណ្ដឹងតែប៉ុណ្ណោះ។

---

[77] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា៣២៤។

[78]ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២១៣ កថាខណ្ឌទី២។

[79] ក្រមនីតិវិធីរដ្ឋប្បវេណីនៃ ឆ្នាំ២០០៦, មាត្រា ២១៤ កថាខណ្ឌទី២។

[80] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២១៣ កថាខណ្ឌទី១។

[81] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២១៥។

### គ. ការប្តឹងជំទាស់ពីដីកាសម្រេច

បណ្តឹងជំទាស់ គឺជាប្រព័ន្ធនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលឯករាជ្យ និងសង្ខេប ដែលអាចធ្វើឡើងចំពោះដីកាសម្រេច ដែលជាការសម្រេចមិនមែនជាសាលក្រម ឬសាលដីកា។[82] ដីកាសម្រេចទាំងអស់មិនសុទ្ធតែអាចប្តឹងជំទាស់បានទេ គឺលុះត្រាតែច្បាប់កំណត់ឲ្យប្តឹងជំទាស់ទើបអាចប្តឹងជំទាស់បាន។ ប្រសិនបើគ្រប់បញ្ហាទាំងអស់ដែលទាក់ទងទៅនឹងដំណើរការនីតិវិធី សុទ្ធតែដាក់ឲ្យតុលាការជាន់ខ្ពស់សម្រេចដែរនោះ វានឹងធ្វើឲ្យនីតិវិធីកាន់តែស្មុគស្មាញ និងមានការយឺតយ៉ាវ។ឧទាហរណ៍៖ ដីកាសម្រេចលើការដកហូត ឬបណ្តឹងជិតចិត្ត ដែលមិនមានមូលហេតុត្រឹមត្រូវនោះមិនអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានឡើយ។

ករណីដែលអាចប្តឹងជំទាស់បានលុះត្រាតែច្បាប់ទទួលស្គាល់ថាភាគី ឬតតិយជនបានបាត់បង់ប្រយោជន៍ ដោយសារដីកាសម្រេចដើម។ ការប្តឹងជំទាស់នេះ ត្រូវដាក់ពាក្យទៅតុលាការដើមដែលចេញដីកាសម្រេចនោះនៅក្នុងអំឡុងពេល១សប្តាហ៍ដោយគិតចាប់តាំងពីថ្ងៃដែលទទួលបានដំណឹងអំពីដីកាសម្រេចនោះ ( អំឡុងពេលមិនអាចពន្យាពេលបាន )។[83]

នៅក្នុងបណ្តឹងជំទាស់ គប្បីត្រូវសរសេរអំពីមូលហេតុច្បាស់លាស់អំពីការសុំលុបចោលឬផ្លាស់ប្តូរដីកាសម្រេចដើម ប្រសិនបើពាក្យប្តឹងជំទាស់នោះមិនបានបញ្ជាក់ពីមូលហេតុនៃការប្តឹងជំទាស់នោះទេ ក៏មិនមានការប្រែប្រួលសុពលភាពនោះដែរ។[84] ក្នុងករណីដែលពុំបានសរសេរបញ្ជាក់អំពីមូលហេតុ នៃការទាមទារម្ចាស់បណ្តឹងអាចដាក់លិខិតជាលាយលក្ខណ៍អក្សរទៅតុលាការនៃបណ្តឹងជំទាស់នោះនៅក្នុងអំឡុងពេល ២សប្តាហ៍ គិតចាប់ពីថ្ងៃដាក់ពាក្យបណ្តឹងជំទាស់នោះ មិនអាចពន្យាពេលបានឡើយ។ ដីកាសម្រេចទៅលើបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់ជាលើកទី២បានឡើយ។

នៅពេលដែលទទួលបានពាក្យបណ្តឹងជំទាស់ តុលាការដើមត្រូវផ្ញើរពាក្យបណ្តឹងជំទាស់ និងសំណុំរឿងទៅតុលាការនៃបណ្តឹងជំទាស់អោយបានឆាប់រហ័ស។ ពេលដែលទទួលបានការផ្ញើរពាក្យបណ្តឹងជំទាស់ហើយ តុលាការនៃបណ្តឹងជំទាស់ត្រូវពិនិត្យពាក្យបណ្តឹងជំទាស់ បើសិនជាពាក្យបណ្តឹងមិនមានភាពត្រឹមត្រូវតាមទម្រង់ច្បាប់តុលាការត្រូវបញ្ជូនដំណឹងឲ្យភាគីដើមបណ្តឹងជំទាស់ធ្វើការកែតម្រូវ។ បើសិនជាភាគីដើមបណ្តឹងជំទាស់នោះមិនបានកែតម្រូវទៅតាមការបង្គាប់របស់តុលាការទេ តុលាការត្រូវលើកចោលបណ្តឹងជំទាស់នោះ ដោយដីកាសម្រេច។

[82] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង ឆ្នាំ២០០៨, ២២៥។

[83] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៣០៣ កថាខណ្ឌទី១។

[84] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង ឆ្នាំ២០០៨, ២២៧, ភ្នំពេញ ៖ ក្រសួងយុត្តិធម៌។

### ២.២.៤. ការបំបែក ឬការបញ្ចូលរឿងក្តី

នៅក្នុងដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ នោះតុលាការអាចបំបែករឿងក្តីមួយទៅជារឿងក្តីផ្សេងៗ ហើយធ្វើការជម្រះរឿងក្តីទាំងនោះដោយដាច់ពីគ្នាបាន នេះហៅថា ការបំបែករឿងក្តី។[85] ឧទាហរណ៍៖ នៅក្នុងករណីតែមួយដើមចោទទាមទារច្រើនចំណុចនៅក្នុងបណ្តឹងតែមួយ[86]ដោយឲ្យចុងចម្លើយសងប្រាក់កម្ចីផង និងបង់ប្រាក់ថ្លៃលក់ទិញផង តុលាការអាចបំបែកការទាមទារឲ្យបង់ប្រាក់ថ្លៃលក់ទិញចេញពីបណ្តឹងនោះ ហើយធ្វើការជម្រះក្តីដោយឡែកបាន។

ត្រឡប់មកវិញតុលាការ ក៏អាចរួមបញ្ចូលរឿងក្តីផ្សេងៗដែលកំពុងត្រូវបានចាត់ការនៅក្នុងតុលាការតែមួយ ដោយធ្វើការជម្រះក្តីសរុបដោយនីតិវិធីតែមួយបានដែរ នេះគេហៅថា ការបញ្ចូលរឿងក្តី។[87] ឧទាហរណ៍៖ ប្រសិនបើ នៅក្នុងតុលាការមួយមានរឿងក្តីច្រើនដែលកំពុងចាត់ការ តុលាការអាចបញ្ចូលរឿងក្តីទាំងនោះមកជម្រះក្នុងពេលមួយបាន បើសិនជារឿងក្តីនោះស្ថិតនៅក្នុងនីតិវិធីតែមួយ ទោះបីជារឿងក្តីទាំងនោះមានភាគីខុសគ្នាក៏ដោយ។

## ២.៣.ការធ្វើកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានសកម្មភាពជាច្រើនដែលត្រូវបានធ្វើដោយចៅក្រម ភាគី ឬអ្នកតំណាង ហើយសកម្មភាពនេះមិនអាចបញ្ជាក់បានទេប្រសិនបើពុំបានកត់ត្រា។ តុលាការត្រូវបង្គាប់ឲ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅរាល់កាលបរិច្ឆេទនីមួយៗ។[88]

### ២.៣.១.ចំណុចដែលត្រូវសរសេរ

នៅកាលបរិច្ឆេទនីមួយៗនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មានសកម្មភាពច្រើនដែលបានកើតឡើងដោយចៅក្រម ភាគី អ្នកតំណាង ឬអ្នកជំនួយការ។ សកម្មភាពទាំងនេះអាចបញ្ជាក់បានប្រសិនបើមិនមានកត់ត្រាទុក ដូចនេះទើបមាត្រានេះកំណត់ឲ្យតុលាការបង្គាប់ឲ្យក្រឡាបញ្ជីកត់ត្រាក្នុងកំណត់ហេតុ។ នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវចំណុច៖

- សញ្ញាណរឿងក្តី
- ឈ្មោះចៅក្រម ក្រឡាបញ្ជី
- ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និងអ្នកបកប្រែដែលបានបង្ហាញខ្លួន

[85] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៩៩ កថាខណ្ឌទី១។

[86] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៧៧។

[87] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ៩៩ កថាខណ្ឌទី១។

[88] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា១០៩។

- ពេលវេលា និងទីកន្លែង។[89]

នៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវកត់ត្រានូវចំណុចសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ នូវចំណុចដូចខាងក្រោម៖

- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ និងចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ
- ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និងការស្នើសុំឲ្យពិនិត្យភស្តុតាង
- ការទទួលស្គាល់ ឬមិនទទួលស្គាស្គាល់របស់ភាគី ចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និងការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវនៃឯកសារ
- ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ និងការទទួលស្គាល់ការទាមទារ
- ចំណុចដែលតុលាការបានបង្គាប់ឲ្យកត់ត្រា និងចំណុចដែលតុលាការអនុញ្ញាតឲ្យកត់ត្រាតាមការទាមទាររបស់ភាគី
- ការសម្រេចសេចក្តីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ដោយមិនបានធ្វើជាលាយលក្ខណ៍អក្សរ។

**២.៣.២.កិច្ចការដាក់បញ្ជូន**

នៅក្នុងនីតិវិធីនៃបណ្តឹង ក្រោយពីតុលាការពិនិត្យឃើញថាបណ្តឹងមានលក្ខណៈត្រឹមត្រូវ និងបានកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរួចរាល់ហើយតុលាការត្រូវធ្វើការ កោះហៅភាគីទាំងសងខាង ដែលជាគោលការណ៍បញ្ជូនត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិ លើកលែងតែមានបញ្ញត្តិពិសេស។[90] មន្ត្រីរដ្ឋបាលទទួលបន្ទុកកិច្ចការបញ្ជូន គឺក្រឡាបញ្ជី មុខងារគឺ ការធ្វើ ឬការផ្តល់សេចក្តីបញ្ជាក់នូវឯកសារសម្រាប់ប្រើក្នុងការបញ្ជូន ហើយប្រគល់អំណាចនៃការបញ្ជូនឯកសារនោះទៅឲ្យមន្ត្រីទទួលបន្ទុកប្រត្តិបត្តិការបញ្ជូន។[91] មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនការបញ្ជូន (មន្ត្រីប៉ុស្តិ៍ប្រៃសនីយ៍ អាជ្ញាសាលា ក្រឡាបញ្ជី) ធ្វើការបញ្ជូនជាក់លាក់ចំពោះជនដែលត្រូវទទួលការធ្វើរបាយការណ៍អំពីការបញ្ជូន ហើយដាក់របាយការនោះទៅតុលាការជាដើម។[92] ឯកសារដែលត្រូវបញ្ជូន គឺជាឯកសារចម្លងទាំងអស់ដែលពាក់ព័ន្ធ លើកលែងតែក្នុងករណីដែលបានកំណត់ពិសេសដោយច្បាប់។[93]រាល់ការបញ្ជូន (ដីកាកោះ ឬលិខិតអញ្ជើញមាធាវី) ត្រូវបញ្ជូនឲ្យដល់។ ការបញ្ជូនត្រូវធ្វើទៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន។

[89] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា១១០។

[90] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា២៤៦។

[91] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង ឆ្នាំ២០០៨, ១១៨។

[92] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង ឆ្នាំ២០០៨, ១១៩, ភ្នំពេញ ៖ ក្រសួងយុត្តិធម៌។

[93] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២៤៧ កថាខណ្ឌទី២។

ប៉ុន្តែចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់វិញ អាចធ្វើទៅទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់សាមីខ្លួនបាន។[94] ប្រសិនបើជនដែលត្រូវទទួលការបញ្ជូននោះ ពុំច្បាស់លាស់ថាមានលំនៅឋាន ឬទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការ នៅព្រះរាជាណាចក្រកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅទីកន្លែងដែលបានជួបប្រទះអ្នកនោះ លើកលែងតែករណីបញ្ជូនចំពោះអ្នកដែលបានជូនដំណឹងតាម បញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា ២៥០ (ការជូនដំណឹងអំពីកន្លែងបញ្ជូនជាអាទិ៍)។

បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាដែរ ចំពោះករណីអ្នកដែលមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬស្នាក់ការ ច្បាស់លាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬអ្នកដែលបានជូនដំណឹងតាមបញ្ញត្តិនៃកថាខណ្ឌទី១ នៃមាត្រា២៥០ ដដែលនេះមិនប្រកែកទទួលការបញ្ជូន។[95] បើសិនជាភាគីនៅក្រៅប្រទេស ការបញ្ជូនដែលត្រូវធ្វើនៅបរទេស

១. ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស តុលាការត្រូវប្រគល់កិច្ចការនេះឲ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះ ឬឯកអគ្គរាជទូត ឬភារធារី ឬកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំរបស់ប្រទេសនោះឲ្យធ្វើបាន។

២. បើការបញ្ជូននៅបរទេសត្រូវធ្វើឡើង ក្នុងនីតិវិធីដែលចៅក្រមដែលទទួលបញ្ជា ឬចៅក្រមដែលទទួលការប្រគល់សិទ្ធិត្រូវធ្វើ ចៅក្រមនោះអាចប្រគល់កិច្ចការបញ្ជូននេះតាមបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះបាន។[96]

ក្នុងករណីដែលទោះបីជាបានធ្វើការស្រាវជ្រាវយ៉ាងណាក៏ដោយក៏មិនអាចដឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន ឬគ្មានវិធីបញ្ជូនណាដែលអាចធ្វើការបញ្ជូនឯកសារបាន នោះក្រមនីតិវិធីរដ្ឋប្បវេណីទទួលស្គាល់ឲ្យធ្វើការបញ្ជូនតាមការផ្សព្វផ្សាយជាសាធារណៈបាន។[97]លក្ខខណ្ឌដើម្បីធ្វើការបញ្ជូនតាមផ្សាយជាសាធារណៈ ត្រូវធ្វើដោយក្រឡាបញ្ជីអាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ តាមពាក្យសុំ(របស់ភាគី) ដោយទទួលការអនុញ្ញាតពីតុលាការ ឬបើយល់ឃើញថាចាំបាច់ដើម្បីជៀសវាងការយឺតយ៉ាវដំណើរការនីតិវិធី តុលាការអាចបង្គាប់ឲ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន ទោះបីជាគ្មានពាក្យសុំក៏ដោយ។[98] វិធីបញ្ជូនតាមការផ្សាយជាសាធារណៈ គឺការបិទប្រកាសនៅទីកន្លែងសម្រាប់បិទប្រកាសនៃតុលាការ ឬទីកន្លែងដែលតុលាការយល់ឃើញថាសមរម្យ។ លើសពីនេះ តុលាការអាចចុះនៅក្នុងរាជការ ឬក្នុងសារព័ត៌មានផ្សាយថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ។[99]

[94] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២៤៩។
[95] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២៥១។
[96] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២៥៣។
[97] ហ៊ី សោភា សៀវភៅស្តីអំពី នីតិវិធីរដ្ឋប្បវេណី, ៩៧។
[98] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២៥៥ កថាខណ្ឌទី១ និងកថាខណ្ឌទី២។
[99] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ២៥៦។

# ជំពូកទី ៣
# ការបញ្ចូលនីតិវិធីត្រៀមសម្រាប់ការទាញ
# ហេតុផល

# ជំពូកទី ៣
# ការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលនីតិវិធីត្រៀសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានបញ្ចប់ ដោយបានបញ្ចប់នូវការរៀបចំចំណុចវិវាទ និងភស្តុតាងរួចរាល់ហើយ តុលាការត្រូវធ្វើការបញ្ជាក់ពីអង្គហេតុដែលត្រូវបំភ្លឺ(៣.១) និងអានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (៣.២) បន្ទាប់មកត្រូវកំណត់កាលបរិច្ឆេទសម្រាប់ធ្វើការទាញហេតុផលដែលជានីតិវិធីបន្ទាប់។

## ៣.១. ការបញ្ជាក់អំពីអង្គហេតុដែលត្រូវបំភ្លឺ

នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ដោយបានបញ្ចប់ការរៀបចំចំណុចវិវាទនៃរឿងក្តី និងភស្តុតាងហើយនោះ តុលាការត្រូវបញ្ជាក់ជាមួយភាគីទាំងសងខាងនូវអង្គហេតុ ដែលត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅនាកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។[100] មិនមែនអង្គហេតុទាំងអស់សុទ្ធតែត្រូវបញ្ជាក់នោះទេទោះបីជាអង្គហេតុនោះជាកម្មវត្ថុនៃការបញ្ជាក់ក៏ដោយ។ ឧទាហរណ៍៖ អង្គហេតុដែលមិនមានវិវាទរវាងភាគីនឹងភាគី (អង្គហេតុដែលបានសារភាព ឬអង្គហេតុដែលចាត់ទុកថាបានសារភាព ) ឬអង្គហេតុដែលតុលាការយល់ឃើញថាមានភាពជាក់ស្តែងតុលាការមិនចាំបាច់ធ្វើការបញ្ជាក់អង្គហេតុទាំងនេះដោយភស្តុតាងទេ ហើយត្រូវយកអង្គហេតុទាំងនេះទៅធ្វើជាមូលដ្ឋាននៃការចេញសាលក្រម។[101]

### ៣.១.១. ការបញ្ជាក់របស់តុលាការ និងភាគី

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានបញ្ចប់ ដោយបានបញ្ចប់នូវការរៀបចំចំណុចវិវាទរួមទាំងភស្តុតាងរួចរាល់ តុលាការត្រូវបញ្ជាក់អំពីអង្គហេតុដែលត្រូវបំភ្លឺជាមួយភាគីសងខាងអំពីអង្គហេតុដែលត្រូវបញ្ជាក់ តាមរយៈការពិនិត្យភស្តុតាងនៅពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលជានីតិវិធីបន្ទាប់។ នៅត្រង់ចំណុចនេះ គឺសំដៅដល់តុលាការ និងភាគីទាំងសងខាងត្រូវបញ្ជាក់ថាអង្គហេតុចំណុចណាខ្លះជាចំណុចវិវាទពិតប្រាកដនៃរឿងក្តី ដែលត្រូវក្លាយជាកម្មវត្ថុនៃការពិនិត្យភស្តុតាង ហើយត្រូវមានការទទួលស្គាល់រួមគ្នារវាងភាគី និងតុលាការហើយចាំបាច់ត្រូវតែធ្វើការបញ្ជាក់ដោយខានពុំបាន ដើម្បីឲ្យការពិនិត្យភស្តុតាងដំណើរការទៅដោយសមូហវិធី និងធ្វើឲ្យដំណើរការនៃការកាត់ក្តីប្រកបដោយភាពសុចរិត តម្លាភាព និងឆាប់រហ័ស ព្រមទាំងផ្តល់ភាពយុត្តិធម៌ជូនគូរភាគី នៅពេលទាញហេតុផលដោយផ្ទាល់មាត់។[102]

---

[100] ក្រមនីតិវិធីរដ្ឋប្បវេណី កក្កដា ឆ្នាំ២០០៦, មាត្រា ១០៧។

[101] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង ឆ្នាំ២០០៨, ៩៦។

[102] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង ឆ្នាំ២០០៨, ៨៥។

#### ៣.១.២. ការមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មី

ក្រោយពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានបញ្ចប់ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីបានទៀតឡើយ។ ប្រសិនបើអនុញ្ញាតឲ្យភាគីអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីនៅក្រោយពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានទៀតនោះ ចំណុចវិវាទរួមដែលត្រូវបានតុលាការកំណត់រួចរាល់តាមរយៈការរៀបចំសេចក្ដីអះអាងរបស់ភាគី ក៏ដូចជាការបង្រួមភស្តុតាងដែលត្រូវបានពិនិត្យរួចរាល់នោះនឹងមិនមានខ្លឹមសារអ្វីឡើយ ហើយធ្វើឲ្យមានភាពយឺតយ៉ាវដល់នីតិវិធី។[103] តាមគោលការណ៍ ការដាក់មធ្យោបាយតទល់ ឬការពារខ្លួនភាគីត្រូវដាក់នៅក្នុងអំឡុងពេលសមរម្យដែលច្បាប់បានកំណត់មុនពេលដែលនីតិវិធីត្រៀមសម្រាប់ការទាគហេតុផលត្រូវបានបញ្ចប់។

### ៣.២.អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

បន្ទាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបញ្ចប់ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនបានទៀតឡើយ។[104] ក្នុងករណីដែលភាគីដាក់មធ្យោបាយតទល់ ឬការពារខ្លួនមកកាន់តុលាការទៀត តុលាការនឹងលើកចោលនូវមធ្យោបាយតទល់ ឬការពារខ្លួននោះលុះត្រាតែមានករណីលើកលែងមួយចំនួនដែលច្បាប់អនុញ្ញាត។ ឧទាហរណ៍៖ ក្នុងករណីមធ្យោបាយតទល់ ឬការពារខ្លួននោះទាក់ទងនឹងចំណុចដែលតុលាការកំពុងស្រាវជ្រាវ ហើយការដាក់មធ្យោបាយនោះមិនធ្វើឲ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្ដឹង ឬករណីដែលភាគីបានបញ្ជាក់ថាខ្លួននឹងមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួននោះមុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយគ្មានកំហុសធ្ងន់ធ្ងរ។

#### ៣.២.១. ការកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផល

បន្ទាប់ពីតុលាការបានបញ្ជាក់ពីអង្គហេតុដែលត្រូវបំភ្លឺ និងបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ហើយមក តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅភាគីទាំងសងខាងមកចូលរួមនៅកាលបរិច្ឆេទកំណត់។[105] មួយវិញទៀត ការកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវកំណត់កាលបរិច្ឆេទមួយដែលភាគីទាំងសងខាងអាចមានវត្តមានបានជាការគោរពនូវគោលការណ៍ចំពោះមុខ។[106] តុលាការ ត្រូវកំណត់កាលបរិច្ឆេទតាមពាក្យសុំរបស់ភាគី ឬតាមឆន្ទានុសិទ្ធិ។ កាលបរិច្ឆេទសម្រាប់ធ្វើការទាញហេតុផលនេះគឺ មិនអាចពន្យាពេល ឬផ្លាស់ប្ដូរបានឡើយលុះត្រាតែករណីចាំបាច់បំផុតដែលមិនអាចជៀសវាងបាន។

---

[103] សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្ដឹង ឆ្នាំ២០០៨, ៨៦។

[104] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១០៨។

[105] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១១៣។

[106] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១១៥ កថាខណ្ឌទី១។

### ៣.២.២. ករណីលើកលែង

ទោះបីជាច្បាប់បានកំណត់រួចមកហើយថាភាគីមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីនៅក្រោយពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ក៏ដោយក្តី តែនៅមានករណីលើកលែងមួយចំនួនដែលច្បាប់បានអនុញ្ញាតដូចតទៅនេះ ៖

- មធ្យោបាយ ដែលទាក់ទងនឹងចំណុចតុលាការត្រូវធ្វើការស្រាវជ្រាវ ឬកំពុងធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ។

ឧទាហរណ៍៖ ការពិនិត្យភស្តុតាងចំពោះបញ្ហាទាក់ទិននឹងសមត្ថកិច្ចសាលាជម្រះក្តី។[107]

- មធ្យោបាយ ដែលមិនធ្វើឲ្យមានភាពយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង។

ឧទាហរណ៍៖ ភាគីស្នើសុំឲ្យតុលាការពិនិត្យភស្តុតាងភ្លាមៗដែលភាគីដាក់មកតាមខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់តែម្តង។[108]

- ករណីដែល ភាគីបានធ្វើសេចក្តីបញ្ជាក់តាំងពីដំបូងថាខ្លួនមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួននៅមុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់បាន ដោយគ្មានកំហុស។

ឧទាហរណ៍៖ ក្នុងករណីដែលភាគីចង់រក្សាសុវត្ថិភាពដល់សាក្សី ឬភស្តុតាង។

### ៣.២.៣. ការមិនសុខចិត្តលើកំណត់ហេតុ

នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលក្រឡាបញ្ជីត្រូវកត់ត្រាដោយសង្ខេបអំពីសកម្មភាពនានាដែលបានកើតឡើង។ ក្នុងករណីដែលភាគី ឬអ្នកដទៃដែលពាក់ព័ន្ធមានការមិនយល់ស្របចំពោះសេចក្តីកត់ត្រានោះ ភាគីអាចប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានោះ ហើយក្រឡាបញ្ជីត្រូវកត់ត្រាការប្តឹងតវ៉ានោះនៅក្នុងកំណត់ហេតុនោះ។[109]

ការប្តឹងតវ៉ានេះ គឺជាបទបញ្ញត្តិមិនបានចែងថាត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់នោះទេ ប៉ុន្តែបើតាមការពិនិត្យមើលអត្ថន័យទាំងមូលក្នុងមាត្រា១១២ ក្រមនីតិវិធីរដ្ឋប្បវេណីគឺ ភាគី ឬជនដែលពាក់ព័ន្ធអាចធ្វើការប្តឹងតវ៉ាដោយផ្ទាល់មាត់បាន។ ប្រសិនបើក្រឡាបញ្ជីយល់ឃើញថា ការតវ៉ានេះមានភាពត្រឹមត្រូវ ឬចៅក្រមយល់ឃើញថាការតវ៉ាមានភាពត្រឹមត្រូវហើយ តុលាការបង្គាប់ឲ្យកែតម្រូវ នោះក្រឡាបញ្ជីត្រូវកែតម្រូវលើកំណត់ហេតុនោះ។ ប៉ុន្តែបើយល់ឃើញថាការតវ៉ាមានភាពមិនត្រឹត្រូវ នោះក្រឡាបញ្ជីត្រូវកត់ត្រានូវសេចក្តីតវ៉ាក្នុងកំណត់ហេតុនោះ។

---

[107] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១៦។

[108] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីភាគទី១ និតិវិធីបណ្តឹង ឆ្នាំ២០០៨, ៨៦។

[109] ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦, មាត្រា ១១២ កថាខណ្ឌទី១។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបកស្រាយបំភ្លឺទៅលើប្រធានបទស្តីអំពី «នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល» ជានីតិវិធីដ៏សំខាន់មួយក្នុងនីតិវិធីជំនុំជម្រះលើកទី១ ដែលតុលាការធ្វើការដោះស្រាយវិវាទ តាមរយៈការដាក់ពាក្យទាមទាររបស់ដើមចោទ។ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជានីតិវិធីដែលមានគោលបំណងរៀបចំការអះអាងរបស់ភាគី រៀបចំចំណុចវិវាទនៃរឿងក្តីដែលភាគីយល់មិនស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តី ដើម្បីឲ្យតុលាការធ្វើការវិនិច្ឆ័យទៅលើការទាមទាររបស់ភាគី។ នៅពេលភាគីរៀបចំពាក្យបណ្តឹងទៅកាន់តុលាការ តុលាការធ្វើការពិនិត្យលើពាក្យបណ្តឹង រួចបញ្ជូនពាក្យបណ្តឹង ហើយចាប់ផ្តើមធ្វើការកំណត់កាលបរិច្ឆេទ ដើម្បីឲ្យភាគីទាំងសងខាងមានវត្តមាន និងធ្វើការបំភ្លឺអំពីការអះអាងតទល់គ្នាចំពោះមុខតុលាការ។ បន្ទាប់ពីការទទួលពាក្យបណ្តឹង តុលាការ ត្រូវធ្វើការសាកល្បងផ្សះផ្សាជាបឋមចំពោះភាគីទាំងសងខាង ប្រសិនបើយល់ថាសមរម្យ។ បន្ទាប់មក កំណត់កាលបរិច្ឆេទធ្វើការត្រៀមទាញហេតុផលដែលភាគីអាចចូលរួមមានវត្តមានបាន និងមិនចាំបាច់ធ្វើជាសាធារណៈ ប៉ុន្តែអាចអនុញ្ញាតឲ្យអ្នកដែលយល់ថាសមរម្យចូលអង្កេតការណ៍បាន។

ចំពោះភាគី កាលណាភាគីចុងចម្លើយ ទទួលបានដីកាកោះហៅ ចុងចម្លើយត្រូវធ្វើការដាក់ឯកសារចម្លើយ ជាឯកសារដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូងសម្រាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ដើម្បីជាការឆ្លើយតបនឹងការទាមទាររបស់ដើមចោទ ដែលមានសរសេរនៅក្នុងពាក្យបណ្តឹង។ បន្ទាប់មកដើមចោទ ធ្វើការដាក់ឯកសារត្រៀមលើកទី១របស់ដើមចោទ ដែលមានសរសេរពីសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួន និងមធ្យោបាយតទល់ ឬការពារខ្លួនរបស់ភាគីម្ខាងទៀត។ ការដាក់មធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួន ជាឯកសារដែលបង្ហាញអំពីការតវ៉ាចំពោះបណ្តឹងតបដែលចុងចម្លើយបានដាក់ទៅកាន់តុលាការ និងមានសារៈសំខាន់ ដើម្បីឲ្យតុលាការ អាចរៀបចំសេចក្តីអះអាងរបស់ភាគី បំភ្លឺចំណុចវិវាទនៃរឿងក្តី និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទ។ តុលាការនឹងដំណើរការរហូតដល់តុលាការចេញសាលក្រមឆ្លើយតបជាមួយនឹងការអះអាងរបស់ភាគី និងបន្តទៅនីតិវិធីទាញហេតុផលផ្ទាល់មាត់។ ប្រសិនបើ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដំណើរការមិនច្បាស់លាស់ទេនាំឲ្យនីតិវិធីមានការយឺតយ៉ាវ តុលាការមិនអាចបន្តនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់បានទេ។ ដូចច្នេះទាមទារឲ្យតុលាការយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងគូភាគីធ្វើសកម្មភាពទៅតាមការបង្គាប់របស់តុលាការ។

ជាការពិតណាស់ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាដំណាក់ការដំបូងក្នុងនីតិវិធីបណ្តឹងដែលដឹកនាំដោយតុលាការដើម្បីបញ្ចប់វិវាទគូភាគី។ គូភាគី តែងតែធ្វើសកម្មភាពអះអាងនូវអ្វីដែលខ្លួនយល់ថាមានប្រយោជន៍ចំពោះភាគី ដោយមិនបានដឹងថាការអះអាងទាំងនោះមានប្រយោជន៍ ឬគ្មានប្រយោជន៍ចំពោះរឿងក្តីឬទេ ដែលនាំឲ្យមានផលវិបាកដល់នីតិវិធីទាញហេតុផល។ ដូច្នេះគូភាគីគួរប្រព្រឹត្តិសកម្មភាពដែលតុលាការបង្គាប់តាមដំណាក់កាល ដើម្បីឲ្យនីតិវិធីដំណើរការទៅបានរលូន មានភាពច្បាស់លាស់ និងប្រសិទ្ធិភាព ព្រោះនីតិវិធីនេះជាការសម្រួលដល់ការដល់ការជនុំជម្រះនៃ នីតិវិធីការទាញហេតុផលផ្ទាល់មាត់ ជៀសវាងមានការស្មុគស្មាញ ឬឧបសគ្គផ្សេងៗ។

សរុបសេចក្តីមក នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ដែលបានលើកឡើងយកមកបកស្រាយនៅពេលនេះថ្វីត្បិតតែការបកស្រាយមិនបានគ្រប់ជ្រុងជ្រោយ តែសង្ឃឹមថាការបកស្រាយនេះនិងអាចជាពន្លឺមួយសម្រាប់ជាជំនួយស្មារតីនៅពេលដែលជួបបញ្ហានៅក្នុងដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះជាក់ជាពុំខាន។

# អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវលើប្រធានបទ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺធ្វើឡើងដើម្បីសម្រេចឲ្យបាននូវគោលបំណងដែលច្បាប់បានកំណត់ ដែលអាចជួយសម្រួលដល់ការអនុវត្តនីតិវិធីបន្តទៀតដោយរលូន។ ប៉ុន្តែដើម្បីធានាតម្លាភាពក៏ដូចជាការបង្កើននូវការជឿទុកចិត្តពីសាធារណជនចំពោះប្រព័ន្ធតុលាការ គប្បីមានការចូលរួមលុបបំបាត់ និងដោះស្រាយនូវរាល់បញ្ហាប្រឈមដែលកើតមាឡើងមានដូចជាៈ

ការប្រើប្រាស់សិទ្ធិបំភ្លឺរបស់តុលាការ គឺជាការពិចារណាទៅលើកម្រិតយល់ដឹងរបស់ភាគី ហើយតុលាការក៏ត្រូវគោរពនូវគោលការណ៍អកម្ម ដោយមិនអនុញ្ញាតឲ្យជ្រៀតជ្រែកចូលក្នុងទំនាក់ទំនងរវាងបុគ្គលឯកជនទេ។ តុលាការស្វែងរកចំណុចកណ្តាលមួយដើម្បីប្រើប្រាស់សិទ្ធិបំភ្លឺឲ្យស្របតាមស្មារតីច្បាប់ មិនទទួលជំនោះទុកចិត្តរបស់ភាគី ជៀសវាងភាគីលើកឡើងថា តុលាការមានភាពលម្អៀង។

ការអនុវត្តនីតិវិធីរបស់តុលាការឲ្យបានត្រឹមត្រូវនៅក្នុងនីតិវិធី តុលាការត្រូវដឹកនាំចាត់ចែងនីតិវិធីឲ្យមានប្រសិទ្ធិភាព ដោយប្រើចំណេះដឹង និងបទពិសោធន៍របស់ខ្លួន។ ហើយតុលាការក៏ត្រូវបញ្ចេញអាកប្បកិរិយា និងពាក្យសម្តីឲ្យបានសមរម្យទៅកាន់គូភាគី ទាំងភាគីដើមចោទ និងភាគីចុងចម្លើយ ពីព្រោះថានៅក្នុងពេលអនុវត្តនីតិវិធីប្រសិនបើតុលាការបង្ហាញអាកប្បកិរិយាមិនសមរម្យទៅកាន់ភាគីណាមួយភាគីនោះនឹងយល់ថាតុលាការមាការលម្អៀងទៅកាន់ភាគីម្ខាងទៀត ជាពិសេសភាគីដែលយល់ថាខ្លួននឹងចាញក្តី ហើយមានចេតនាទុច្ចរិតអូសបន្លាយពេលវេលា និងយកបញ្ហានេះមកធ្វើជាកម្មវត្ថុប្តឹងមកតុលាការ។

ជាចុងក្រោយសម្រាប់ការបញ្ចប់នៃការសរសេរសារណានេះ យើងខ្ញុំសង្ឃឹមថាការលើកយកប្រធានបទ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះមកបកស្រាយ បានចូលរួមជាចំណែកមួយក្នុងការផ្សព្វផ្សាយដល់អ្នកសិក្សារៀនសូត្រជំនាន់ក្រោយៗបានទទួលចំណេះដឹងបន្ថែមទៀត។

# ឯកសារយោង


## ច្បាប់ និងបទបញ្ញត្តិផ្សេងៗ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤, កញ្ញា,១៩៩៣។

២.ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦, កក្កដា, ២០០៦។

៣.គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ២០០៩, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

៤.ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា,២០០៨, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី១ នីតិវិធីបណ្តឹង , ភ្នំពេញ ៖ ក្រសួងយុត្តិធម៌ ។

## សៀវភៅ និងឯកសារផ្សេងៗ

១. ហ៊ី សោភា,២០០៧,នីតិវិធីរដ្ឋប្បវេណី, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

២. អ៊ីវ ប៉ូលី,គ្មានកាលបរិច្ឆេទ, នីតិវិធីរដ្ឋប្បវេណី,មេរៀនសង្ខេបសាកលវិទ្យាល័យបញ្ញាសាស្ត្រ ។

៣. អ៊ីវ ប៉ូលី និង ទេព បូផល, រៀបរៀងនិងបោះពុម្ពដោយ វិភាគទានច្បាប់, កញ្ញា, ២០២១, កម្រងមេរៀន ២០២០, ភ្នំពេញ៖ ជោគជ័យ។

៤.ប៉ោ ហ៊ុយ, គ្មានកាលបរិច្ឆេទ,នីតិវិធីជំនុំជម្រះលើកទី១ ។

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹង

**ដើមចោទ**

ឈ្មោះ៖ X

អាសយដ្ឋាន៖ ផ្ទះលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមាធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ..........................................................

ការិយាល័យមេធាវី / ក្រុមហ៊ុនមេធាវី /ក្រុមហ៊ុមេធាវី ៖ ..........................................................................

លេខទូរស័ព្ទ ៖ ..........................................................................................................................

**ទីកន្លែងបញ្ជូន** ៖ ........................................................................................................................

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**
**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ**

## ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ៖

(១) បង្គាប់ឲ្យចុងចម្លើយបង់ប្រាក់ចំនួន ១៣.៥០០ (មួយម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិក និងប្រាក់ ១០% (ដប់ភាគរយ) នៃប្រាក់ចំនួន ១០.០០០ (មួយម៉ឺន)ដុល្លារអាមេរិចក្នុងទឹកប្រាក់ ១៣.៥០០ (មួយម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១២ រហូតដល់ពេលសងរួចទៅដើមចោទ។

(២) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

(៣) សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន។

## ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ

### ខ.១. ការទាមទារប្រាក់ដើម និងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចគិតចាប់ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០០៨ រហូតដល់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១២

**ខ.១.១.** ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧ ចុងចម្លើយបានព្រមព្រៀងលើកិច្ចសន្យាកម្ចីបរិភោគជាមួយដើមចោទក្នុងទឹកប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក។ កិច្ចសន្យានេះបានកំណត់កាលបរិច្ឆេទសងនៅថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០០៨។ ដើមចោទ និងចុងចម្លើយបានព្រមព្រៀងជាលិខិតលាយលក្ខណ៍អក្សរដោយមានហត្ថលេខារបស់ចុងចម្លើយ អំពីការបង់ប្រាក់ចំនួន ៥% ក្នុង ១ឆ្នាំ (ប្រាំភាគរយក្នុងមួយឆ្នាំ) និងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ចំនួន ១០% ក្នុង ១ឆ្នាំ (ដប់ភាគរយក្នុងមួយឆ្នាំ) នៃប្រាក់កម្ចីចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកខាងលើ។ (ភស្តុតាង X1)

នៅថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០០៧ ដើមចោទបានប្រគល់សាច់ប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកទៅចុងចម្លើយដោយផ្អែកតាមកិច្ចសន្យាខាងលើ។ (ភស្តុតាង X2)

ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៨ ដែលជាថ្ងៃកំណត់សងបានកន្លងផុត។

**ខ.១.២.** ទឹកប្រាក់ដែលទាមទារចំនួន ១៣.៥០០(មួយម៉ឺនបីពាន់ប្រាំរយ) ដុល្លារអាមេរិកនេះបានមកពី៖

ប្រាក់ដើម ៖ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក

ការប្រាក់  ៖ ៥០០ (ប្រាំរយ) ដុល្លារអាមេរិក (អត្រាការប្រាក់ ៥% ក្នុង ១ឆ្នាំ គិតចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៧ រហូតដល់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០០៨)

ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ៖
៤.000 (បួនពាន់) ដុល្លាអាមេរិក (ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ១0% ក្នុង១ឆ្នាំ គិតចាប់ពីថ្ងៃទី០១ ខែវិចច្ឆិកា ឆ្នាំ២០០៨ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១២)
ប្រាក់សងមួយភាគ ៖ ចំពោះប្រាក់ចំនួន ១.000 (មួយពាន់) ដុល្លារអាមេរិកដែលទទួលបាននៅថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០១២ (**ភស្តុតាង** X3) ជាដំបូងត្រូវយកមកកាត់នឹងការប្រាក់ចំនួន ៥00 (ប្រាំរយ) ដុល្លារអាមេរិក ហើយទឹកប្រាក់ដែលនៅសល់ត្រូវយកមកកាត់នឹងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចចំនួន៤.000 (បួនពាន់) ដុល្លារអាមេរិក ដែលបានកើតឡើងនៅពេលនោះ។
នាំឲ្យចំនួនទឹកប្រាក់នៃការទាមទារមានដូចខាងក្រោមនេះ ៖
**៥00 +៤.000-១.000 = ៣.៥00 ( ចំនួនទឹកប្រាក់ដែលនៅសល់នៃប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ក្រោយពីការកាត់បំណុលផ្អែកតាមការសងមួយភាគ ) ១.000 ( ប្រាក់ដើម )+ ៣.៥00= ១៣.៥00**

**ខ.២. ការទាមទារនូវប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច គិតចាប់ពីថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ២០១២ រហូតថ្ងៃសងគ្រប់**

ចុងចម្លើយមានកាតព្វកិច្ចត្រូវបងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចត្រូវបង់ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចឲ្យទៅដើមចោទចំនួន ១0% ក្នុង១ឆ្នាំ ចំពោះប្រាក់កម្ចីចំនួន ១0.000 (មួយម៉ឺន) ដុល្លារអាមេរិកខាងលើនេះគិតចាប់ពីថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០១២ រហូតដល់ថ្ងៃសងរួច។

**ហេតុនេះ ដើមចោទទាមទារឲ្យចុងចម្លើយបង់ 1 ប្រាក់ដើមចំនួន ១0.000 ( មួយម៉ឺន ) ដុល្លារអាមេរិក និង 2ចំនួនទឹកប្រាក់ដែលនៅសល់នៃប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ៣.៥00 ( បីពាន់ប្រាំរយ ) ដុល្លារអាមេរិក គិតត្រឹមថ្ងៃទី ១ ខែតុលា ឆ្នាំ២០១២ និងព្រមទាំងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចចំនួន ១0% ក្នុង ១ឆ្នាំ លើប្រាក់ដើមចំនួន ១0.000 ( មួយម៉ឺន )ដុល្លារអាមេរិកចាប់ថ្ងៃទី ១ ខែតុលា ឆ្នាំ២០១២ រហូតដល់ថ្ងៃដែលសងរួចដោយផ្អែកតាមកិច្ចសន្យានេះ។**

## គ.ប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តីនៃរឿងក្តីនេះគប្បីជាបន្ទុករបស់ចុងចម្លើយ (កថាខណ្ឌទី ១ មាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

**ឃ. ការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន**

រឿងក្តីនេះ គឺជារឿងក្តីដែលទាមទារឲ្យសងប្រាក់កម្ចី ហើយមានភស្តុតាងគ្រប់គ្រាន់ក្នុងការទទួលស្គាល់នូវការអះអាងរបស់ដើមចោទ។ ដើមចោទស្នើសុំនូវការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន (មាត្រា១៩៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**ខ. ភស្តុតាង**

**១**. លិខិតកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧ (**ភស្តុតាង** X1)

**២**. លិខិតប្រគល់ទទួលប្រាក់ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៧ (**ភស្តុតាង** X2)

**៣**. លិខិតទទួលប្រាក់សងមួយផ្នែកចុះថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០១២ (**ភស្តុតាង** X3)

សេចក្តីដូចបានកំណត់ សូម **លោកប្រធាន** សម្រេចតាមការស្នើសុំដោយក្តីអនុគ្រោះ។
សូម **លោកប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**អ្នកតំណាងដោយអាណត្តិ**

P

<u>ឯកសារភ្ជាប់</u>

១.លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២.ច្បាប់ចតចម្លងនៃភស្តុតាងនីមួយៗខាងលើ"ចំនួន ០២ ច្បាប់"

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**

លេខ: ១

## ដីកាសម្រេច

## បង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ

លោកជំទាវ ប្រធានសាលាដំបូងខេត្តតាកែវ

-បានឃើញ:មាត្រា ៦២ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៦។

-បានឃើញ:សំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី ០ របស់សាលាដំបូងខេត្តតាកែវ ។

**អត្តសញ្ញាណគូភាគី**

-ដើមចោទឈ្មោះ ភេទស្រី កើតឆ្នាំ១៩៩៣ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណ មានអាសយដ្ឋាននៅភូមិសីហា ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ។

-ចុងចម្លើយឈ្មោះ ភេទប្រុស កើតឆ្នាំ១៩៩៣ កាន់អត្តសញ្ញាណប័ណ្ណ មានអាសយដ្ឋាននៅភូមិសីហា ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ។

**កម្មវត្ថុនៃពាក្យបណ្ដឹង:** ប្ដឹងសុំឲ្យតុលាការចេញសាលក្រមសម្រេចដូចខាងក្រោម:

១.បញ្ជាក់ពីអត្ថិភាពនៃកម្មសិទ្ធិករលើដីដែលមានទំហំ ៨៥៥៧ ម² ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលចេញដោយ អាជ្ញាធរមានសមត្ថកិច្ចលេខ: PIN 116-1901250405 លិខិត ឬ ប័ណ្ណសម្គាល់អចលនទ្រព្យដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចលេខ: 047/19 ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៩ របស់ពន្ធដារសាខាខេត្តសៀមរាប ដែលមានទីតាំងស្ថិតនៅភូមិសណ្ដាយ ឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ជាកម្មសិទ្ធិរបស់ឈ្មោះ ភេទស្រី កើតថ្ងៃទី ២៥ ខែមេសា ឆ្នាំ១៩៩៣ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេ ១០០៨៨៩០៧០។

២.បង្គាប់ឱ្យមន្ត្រីជំនាញរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តសៀមរាប ចុះបញ្ជីផ្ទេរសិទ្ធិកាន់កាប់ពីឈ្មោះ ភេទប្រុស កើតថ្ងៃទី ១៣ ខែមេសា ឆ្នាំ១៩៩៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណ លើដីដែលមានទំហំ ៨៥៥៧ ម² ដែលមានលិខិតផ្ទេរកម្មសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) លេខចុះបញ្ជីប្រថាប់ត្រា 2162829922 លេខអត្តសញ្ញាណកម្មអចលនទ្រព្យ PIN 116-19012520405 លិខិត ឬ ប័ណ្ណសម្គាល់អចលនទ្រព្យដែលចេញដោយ អាជ្ញាធរមានសមត្ថកិច្ចលេខ: 047/19 ចុះថ្ងៃទី ១៨ ខែមករា ឆ្នាំ១៩៩៣ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ

៣.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

## <u>សំអាងហេតុ</u>

ដើមចោទ ពុំទាន់បានបង់ប្រាក់ដើម្បីធ្វើការកោះហៅគូភាគី និង សម្រាប់បញ្ជូនឯកសារផ្សេងៗនៅឡើយ ហេតុដូចនេះ ដើម្បីដំណើរការនីតិវិធីពាក្យបណ្តឹងតាមច្បាប់ គប្បីបង្គាប់ឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ។

## <u>ហេតុដូច្នេះសម្រេច</u>

-បង្គាប់ឲ្យដើមចោទឈ្មោះ ភេទស្រី កើតឆ្នាំ១៩៩៣ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណ មានអាសយដ្ឋាននៅភូមិសីហា ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ បង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) រៀល នៅសាលាដំបូងខេត្តតាកែវ បន្ទប់ "ក" ជាន់ផ្ទាល់ដី ឱ្យបានមុន ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០២៤ ជារៀងរាល់ម៉ោងធ្វើការ ដើម្បីតុលាការចាត់ការលើពាក្យបណ្តឹងតាមច្បាប់ ។

-ក្នុងករណីមិនបានបង់ប្រាក់តាមការកំណត់ខាងលើនេះ តុលាការនឹងលើកពាក្យបណ្តឹងនេះចោលតាមមាត្រា ៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ថ្ងៃអង្គារ ១៣ រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

តាកែវ, ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០២៤

**ចៅក្រម**

បានទទួល

ថ្ងៃទី..........ខែ.......... ឆ្នាំ២០២៤

**ស្នាមមេដៃស្តាំសាមីខ្លួន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ ... ធ.ស

## ដីកាសម្រេចបង្គាប់ឲ្យបង់ពន្ធដាក់ពាក្យបណ្តឹងតប

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ក្រមនីតិវិធីរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមាន៖

ដើមបណ្តឹងតប(ចុងចម្លើយ)៖ ក្រុមហ៊ុន មាន អាសយដ្ឋានស្ថិតនៅជាន់ទី១១ សុមិត្ត ខនដូមីនាម ផ្ទះលេខ០៧ ផ្លូវលេខ២៣៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ តំណាងដោយលោក កាន់លិខិតឆ្លងដែនលេខ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។

អ្នកតំណាងដោយអាណត្តិឲ្យដើមបណ្តឹងតប(ចុងចម្លើយ)៖ មេធាវី និងមេធាវី អាសយដ្ឋាន ក្រុមមេធាវី ខេមជីន មានការិយាល័យតាំងនៅកោះពេជ្រ អគារ ផ្លូវសុភមង្គល សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទទំនាក់ទំនងលេខ -អាសយដ្ឋានដែលត្រូវធ្វើការបញ្ជូន។

ចុងបណ្តឹងតប(ដើមចោទ)៖ ឈ្មោះ កាន់លិខិតឆ្លងដែនចិនតៃវ៉ាន់លេខ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ មានអាសយដ្ឋានជាន់ទី៤ លេខ២៧ ផ្លូវ Ji Xain តំបន់ San Chong ក្រុង Xin Bei។

អ្នកតំណាងដោយអាណត្តិឲ្យចុងបណ្តឹងតប(ដើមចោទ)៖ មេធាវី មេធាវី និងមេធាវី ។ អាសយដ្ឋាន ការិយាល័យមេធាវី ហាស្គី អេន ដាតនើរ អាសយដ្ឋានស្ថិតនៅផ្ទះលេខ២៣៣D ផ្លូវ២៧១ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-បានឃើញ ពាក្យបណ្តឹងតប ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ របស់មេធាវី និងមេធាវី ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្តឹងតប(ចុងចម្លើយ) ក្រុមហ៊ុន

## សំអាងហេតុ

-ក្រោយពីបានពិនិត្យលើសំណុំរឿង និងបណ្តឹងតប ចប់សព្វគ្រប់ ឃើញថា បណ្តឹងតបមិនទាន់បានបង់ពន្ធលើបណ្តឹងតបនៅឡើយ តាមបញ្ញត្តិមាត្រា៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-តាមពាក្យបណ្ដឹងតប ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០ របស់មេធាវី : និងមេធា. ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្ដឹងតប(ចុងចម្លើយ) ក្រុមហ៊ុន

ឃើញថាមេធាវីតំណាងដោយអាណត្តិឲ្យដើមបណ្ដឹងតប(ចុងចម្លើយ) បានប្ដឹងសុំឲ្យតុលាការចេញសាលក្រមដែលខ្លឹមសារ៖

១-សុំរំលាយកិច្ចព្រមព្រៀងទិញ-លក់លំនៅឋានលេខ B3 ជាន់ទី២៣ ជុង B នៃអគារ និងកិច្ចព្រមព្រៀងសិទ្ធិប្រើប្រាស់ចំណតរថយន្តលេខ B215 និង B252 ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ រវាងលោក ជាមួយក្រុមហ៊ុន

២-សុំរំលាយកិច្ចព្រមព្រៀងទិញ-លក់លំនៅឋានលេខB3 ជាន់ទី១៦ ជុងB នៃអគារ Sky Villa និងកិច្ចព្រមព្រៀងសិទ្ធិប្រើប្រាស់ចំណតរថយន្តលេខ B205 និង B206 ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ រវាងលោក ជាមួយក្រុមហ៊ុន

៣-សុំរំលាយកិច្ចព្រមព្រៀងទិញ-លក់លំនៅឋានលេខ B3 ជាន់ទី២០ ជុង B នៃអគារ Sky Villa និងកិច្ចព្រមព្រៀងសិទ្ធិប្រើប្រាស់ចំណតរថយន្តលេខ B311 និង B312 ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ រវាងលោក ជាមួយក្រុមហ៊ុន

៤-សុំរឹបអូសប្រាក់កក់ចំនួន ៨៤៩.១០០(ប៉ែតសិបបួនម៉ឺនប្រាំបួនពាន់មួយរយ)ដុល្លារអាមេរិក ប្រគល់ទៅឲ្យក្រុមហ៊ុន

៥-ឲ្យចុងបណ្ដឹងតបទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

## ហេតុដូច្នេះសម្រេច

-បង្គាប់ឲ្យដើមបណ្ដឹងតប ក្រុមហ៊ុន- មានអាសយដ្ឋានស្ថិតនៅជាន់ទី១១ សុមិត្ត ខនដូមីនាម ផ្ទះលេខ០៧ ផ្លូវលេខ២៣៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ តំណាងដោយលោក ភេទប្រុស មេធាវី និងមេធាវី ជាមេធាវីតំណាងដោយអាណត្តិ បង់ពន្ធដាក់ពាក្យបណ្ដឹងតាមការគណនាប្រាក់ពន្ធស្របតាមបញ្ញត្តិមាត្រា៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅអំឡុងពេល០២(ពីរ)សប្ដាហ៍ គិតពីថ្ងៃបានទទួលដំណឹងពីដីកាសម្រេចនេះ ជាកំណត់ ដើម្បីតុលាការចាត់ការរឿងក្ដីនេះតាមច្បាប់។

ថ្ងៃចន្ទ ៣កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១

ចៅក្រម

14 · 07 · 21
096 31 41 150

1.2/

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

[illegible]
បន្ទប់ "ធ" ជាន់ទី៣

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងក្តីរដ្ឋប្បវេណី

# ដីកាកោះ

យើង [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។

| | |
|---|---|
| អញ្ជើញឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ១៩៨១, ឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ១៩៨៥ និងឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ១៩៥៥ ជាភាគីសហចុងចម្លើយ ។<br>អាសយដ្ឋាន: ផ្ទះលេខ១១៧ ផ្លូវលេខ១១២C ភូមិអូរបែកក្អម សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ | |
| សញ្ញាណនៃរឿងក្តី (លេខនិងភាគី)<br>-ប្តឹងសុំសាលក្រមទាមទារប្រាក់ | សំណុំរឿងក្តីលេខ [redacted] ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ ។<br>-ដើមចោទ [redacted] ) ។<br>-សហចុងចម្លើយឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ១៩៨១, ឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ១៩៨៥ និងឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ១៩៥៥ ។ |
| កាលបរិច្ឆេទ និង ទីកន្លែងដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី.[illegible]. ខែ[illegible] ឆ្នាំ២០២៤ វេលាម៉ោង.[illegible]..........<br>បន្ទប់ "ធ" ជាន់ទី៣ សាលាដំបូងរាជធានីភ្នំពេញ (សាលាយុត្តិធម៌)។ |
| ប្រភេទដំណាក់កាលនៃនីតិវិធី<br>(សូមគូស ☐ លើលេខនៃនីតិវិធីដែលចាំបាច់) | ១.ការទាញហេតុផលដោយផ្ទាល់មាត់ ☐ ២.ការប្រកាសសាលក្រម ☐<br>៣.ការផ្សះផ្សា ☐ ៤.នីតិវិធីត្រៀម ☑ ៥.សាកសួរ ☐ |
| ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ៖ | -លិខិតផ្សេងៗ ទៀតដែលពាក់ព័ន្ធ។ |
| ទណ្ឌកម្មជាអាទិ៍ ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | ១.ចំពោះសាមីភាគី: បើពុំចូលខ្លួនទេនោះ តុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀត ជាការពិតបាន ។ (តាមមាត្រា១៩០កថាខណ្ឌទី២.២៧៣ក្រមនីតិវិធីរដ្ឋប្បវេណី) ។<br>២.ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការ ដោយគ្មានមូលហេតុត្រឹមត្រូវ *តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន)រៀល* តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |
| សូមបង្ហាញតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើ ។<br>ថ្ងៃ[illegible] ខែ[illegible] ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧<br>រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៤<br>ចៅក្រម | |

បញ្ជាក់: ក្នុងករណីដែលមានជម្ងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបាន សូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុនោះ ជូនតុលាការ ។
ពេលបង្ហាញខ្លួនសូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក ។
ទម្រង់នេះប្រើសម្រាប់ ភាគី សាក្សី អ្នកទទួលរួមអន្តរាគមន៍ក្នុងបណ្តឹង ។

# ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹងតប

**សូមគោរពជូន** : លោក.........................................ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ដើមបណ្តឹងតប** : ឈ្មោះ.............................................ភេទ............អាយុ...........ឆ្នាំ ជនជាតិខ្មែរ លំនៅផ្ទះលេខៈ.........ផ្លូវលេខ........សង្កាត់...................ខណ្ឌ.................រាជធានីភ្នំពេញ មានលោក.................................................ជាមេធាវី។

**ចុងបណ្តឹងតប** : ឈ្មោះ.............................................ភេទ............អាយុ...........ឆ្នាំ ជនជាតិខ្មែរ លំនៅផ្ទះលេខៈ.........ផ្លូវលេខ........សង្កាត់...................ខណ្ឌ.................រាជធានីភ្នំពេញ មានលោក.................................................ជាមេធាវី។

**កម្មវត្ថុ** : សុំប្តឹងតបនិងពាក្យបណ្តឹងរបស់ឈ្មោះ.............................. ចុងថ្ងៃទី .................. និងសុំសិទ្ធិគ្រប់គ្រងដីទំហំ..............ម៉ែត្រក្រឡា ស្ថិតន)ភូមិ...............................ឃុំ ............................ស្រុក...............................ខេត្ត................................។

**យោង** : សំណុំរឿងរដ្ឋប្បវេណីលេខៈ ................ ចុះថ្ងៃទី............................របស់សាលាដំបូងរាជធានីភ្នំពេញ។

## I.សាលក្រមដែលទាមទារដោយដើមបណ្តឹងតប

១-សុំទុកជាមោឃៈនូវពាក្យបណ្តឹងរបស់ឈ្មោះ.....................ចុះថ្ងៃទី.........................ចោលជាអសារបង់។

២-សុំតុលាការទុកជាត្រឹមត្រូវនូវបណ្ណ័សំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ......................ចុះថ្ងៃទី .................................ដែលមានឈ្មោះ..........................និង..........................ជាកម្មសិទ្ធិករ និង សុំសិទ្ធិគ្រប់គ្រងដីនោះជាកម្មសិទ្ធិស្របច្បាប់តទៅ។

៣-ទាមទារសោហ៊ុយខាតពេលវេលា និង សេវាមេធាវីចំនួន..........................,ជំងឺចិត្តចំនួន............ កិត្តិយសសេចក្តីថ្លៃថ្នូរចំនួន........................សរុបចំនួន.............................។

៤-ពន្ធលើកម្មវត្ថុបណ្តឹងតបជាបន្ទុករបស់ចុងបណ្តឹងតប។

## II.អង្គហេតុដែលលើកឡើងដោយដើមបណ្តឹងតប

..........................................................................................................................................

..........................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

......................................................................។

III.**<u>របៀបដាក់តស៊ូតាង</u>**

១-ពាក្យបណ្តឹងរបស់ឈ្មោះ.........................ចុះថ្ងៃទី........................................។

២-លិខិតលេខៈ.......................ចុះថ្ងៃទី................................របស់ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និង សំណង់។

៣-លិខិតបញ្ជាក់លេខៈ...................ចុះថ្ងៃទី.........................របស់សាលាឃុំ..........................។

៤-លិខិតលេខៈ................. ចុះថ្ងៃទី.....................................របសើការិយាល័យរៀបចំដែនដីនគររូបនីយកម្មនិងសំណង។

ធ្វើនៅថ្ងៃទី............ខែ............ឆ្នាំ.............

**ស្នាមមេដៃស្តាំ**

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រុមមេធាវីយុត្តិធម៌ និង សហការី
JUSTICE & ASSOCIATES
លេខៈ០១៤.../ក.ម.យ.ស/២០២៤

| |
|---|
| **ប្រធានក្រុមមេធាវី** |
| មេធាវី ស៊ុយ ឈុនហាក់ |
| Lawyer Suy Chhunhak |
| **អនុប្រធានក្រុមមេធាវី** |
| ១. មេធាវី សេង សុវណ្ណារី |
| Lawyer Seng Sovannary |
| ២. មេធាវី ស៊ុយ សុខុន |
| Lawyer Suy Sokhon |
| **សមាជិកក្រុមមេធាវី** |
| ៣. មេធាវី សេក ច័ន្ទសង្វារ |
| Lawyer Sek Chansangva |
| ៤. មេធាវី អ៊ឹម កុយ |
| Lawyer Im Koy |
| ៥. មេធាវី ឆេង ផាត់ |
| Lawyer Chheng Phat |
| ៦. មេធាវី វ៉ា វុទ្ធី |
| Lawyer Voir Vuthy |
| ៧. មេធាវី អ៊ិន សុខប៉ូ |
| Lawyer In Sokpo |
| ៨. មេធាវី ឈៀត ហុង |
| Lawyer Chheath Hong |
| ៩. មេធាវី ច័ន្ទ តារាមុនុន |
| Lawyer Chan Taramonoun |
| ១០. មេធាវី តេង បញ្ញារិទ្ធ |
| Lawyer Teng Panharith |
| ១១. មេធាវី ស៊ុយ សុវណ្ណបញ្ញា |
| Lawyer Suy Sovanpanha |
| ១២. មេធាវី អេង ចាន់ភារ៉ា |
| Lawyer Eng ChanPheara |
| ១៣. មេធាវី សេក ពៅ |
| Lawyer Sek Peov |
| ១៤. មេធាវី កែប ធា |
| Lawyer Kep Thea |
| ១៥. មេធាវី សឹង អង្គាសិល |
| Lawyer Seong Angkeasil |
| ១៦. មេធាវី ស្រ៊ុន ឈុងហាក់ |
| Lawyer Srun Chhounghak |
| ១៧. មេធាវី តឹក សិរីវិចិត្រ |
| Lawyer Tek Sereyvichet |
| ១៨. មេធាវី អ៊ុំ សុធា |
| Lawyer Oum Sothea |

# ពាក្យសុំធ្វើជាអ្នកតំណាងដោយអាណត្តិ

ខ្ញុំបាទមេធាវី អត្តលេខៈ ២៧៧៣ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យនៅ **ក្រុមមេធាវីយុត្តិធម៌ និង សហការី** ( JUSTICE & ASSOCIATES LAW GROUP ) ដែលមានទីស្នាក់ការកណ្តាលផ្ទះលេខៈ៤២០ ផ្លូវលេខៈ៣៧១ ភូមិព្រៃកគាគង់១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

លេខទូរស័ព្ទទំនាក់ទំនង៖ **០១២ ២៣៧ ២៥៩ / ០៨៨ ៨៨៨ ៩៣៣៧** ។

## សូមគោរពជូន

## ឯកឧត្តម ប្រធានសាលារាជធានីភ្នំពេញ

*សូមមេត្តាជ្រាប!*

**កម្មវត្ថុ:** សំណើសុំធ្វើជាមេធាវីតំណាងដោយអាណត្តិក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ។

**យោង:** - លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ និងឈ្មោះ ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៤ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពនិងជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៤ ឈ្មោះ និងឈ្មោះ ប្រគល់សិទ្ធិដល់ខ្ញុំបាទឱ្យធ្វើជាមេធាវីតំណាងដោយអាណត្តិក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ របស់ **សាលាដំបូងរាជធានីភ្នំពេញ** តាមនីតិវិធីច្បាប់ ។

អាស្រ័យដូចបានគោរព និង ជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និង ទទួលស្គាល់ខ្ញុំបាទតាមផ្លូវច្បាប់ចាប់ពីពេលនេះតទៅ ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ថ្ងៃ[illegible] ខែ[illegible]...... ឆ្នាំ រោង ឆស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០២៤

**ហត្ថលេខា និងត្រា**

AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី អ៊ុំ សុធា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

**អាណត្តិទាយក:** ខ្ញុំបាទឈ្មោះ កើតថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៩៤ សញ្ជាតិខ្មែរ ជនជាតិខ្មែរ **អាសយដ្ឋាន៖** ផ្ទះ: ‌ ភូមិស្រីស្នំ សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ និងនាងខ្ញុំឈ្មោះ កើតថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៩៧ សញ្ជាតិខ្មែរ ជនជាតិខ្មែរ **អាសយដ្ឋាន៖** ភូមិអង្គតានុ ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ។

**សូមប្រគល់សិទ្ធិជូន ក្រុមមេធាវីយុត្តិធម៌ និង សហការី ធ្វើសកម្មភាពទៅតាមផ្លូវច្បាប់:**

លោកមេធាវី **ពុំ សុធា** អត្តលេខ: **២៧៧៣** ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យ **ក្រុមមេធាវីយុត្តិធម៌ និង សហការី** (JUSTICE & ASSOCIATES LAW GROUP) ស្នាក់ការកណ្តាលនៅ *ផ្ទះលេខ៨៤២០ ផ្លូវ៣៧១ ក្រុមទី១១ ភូមិព្រែកតាគង់១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ* អោយធ្វើជាអ្នកតំណាងដោយអាណត្តិ ។

នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ:**៧៣៩** ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ របស់ **សាលាដំបូងរាជធានីភ្នំពេញ** តាមនីតិវិធីច្បាប់ ។

**<u>ដែលអាចធ្វើសកម្មភាពដូចខាងក្រោម៖</u>**

១. សិទ្ធិអំណាចពេញលេញក្នុងការធ្វើសកម្មភាពតំណាងឱ្យយើងខ្ញុំឈ្មោះ និងឈ្មោះ

២. ការដាក់ពាក្យបណ្តឹងតប, ចូលឆ្លើយក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី, ជូនដំណឹង,លិខិតបំភ្លឺ ។

៣. ការដាក់ពាក្យបណ្តឹង ការផ្សះផ្សា ការបោះបង់ ឬការទទួលស្គាល់ ការទាមទារ ឬការដកពាក្យខ្លួនចេញពីបណ្តឹង ដែលខ្លួនចូលរួមអន្តរាគមន៍ ឬទទួលបណ្តឹង ។

៤. ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ ឬពាក្យបណ្តឹងទាស់ដោយរួមទាំងការដកពាក្យបណ្តឹងនេះផង ។

៥. ការដកពាក្យបណ្តឹងទាស់ចំពោះសាលក្រមចុងក្រោយនៃបណ្តឹងទាមទារចំពោះទឹកប្រាក់តិច រួមទាំងការយល់ព្រមចំពោះការដកពាក្យទាស់នេះផងដែរ ។

៦. ការតែងតាំងអនុតំណាង ។

៧. រាល់សកម្មភាពរបស់មេធាវីតំណាងដោយអាណត្តិ គឺធ្វើឡើងក្នុងនាមអាណត្តិទាយក ដើម្បីផលប្រយោជន៍របស់អាណត្តិទាយក ។

**<u>បញ្ជាក់:</u>** *សោហ៊ុយចំណាយលើការបង់ពន្ធផ្សេងៗនៅក្នុងបណ្តឹងនេះ ជាបន្ទុករបស់យើងខ្ញុំជាអាណត្តិទាយក ។ ក្នុងករណីមិនបានគោរពតាមកាតព្វកិច្ចនេះ យើងខ្ញុំសុខចិត្តទទួលខុសត្រូវនូវរាល់ការបាត់បង់ផលប្រយោជន៍នានាដោយខ្លួនឯងផ្ទាល់ ។*

ថ្ងៃ.......................... ឆ្នាំរោង ឆស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែ........ ឆ្នាំ២០២៤

**អាណត្តិទាយក**

បានឃើញ និងយល់ព្រម

ធ្វើជាមេធាវីតំណាងឱ្យអាណត្តិទាយក

ខាងលើនេះពិតប្រាកដមែន ។

រាជធានីភ្នំពេញ, ថ្ងៃទី...... ខែ........ ឆ្នាំ២០២៤

**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារចម្លើយ

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ B

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖

.................................................................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖

..................................................................................

លេខទូរស័ព្ទ ៖ .......................................................

**ទីកន្លែងបញ្ជូន ៖** ការិយាល័យមេធាវី / ក្រុមមេធាវី /ក្រុមហ៊ុនមេធាវី............................................................

**សូមគោរពជូន**

**លោក J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u>** ៖ សុំដាក់**ឯកសារចម្លើយដើម្បីឆ្លើយតប**នឹងពាក្យបណ្ដឹងចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ របស់ឈ្មោះ X

**<u>យោង</u>** ៖ -មាត្រា **១០១ កថាខណ្ឌទី៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ......................ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤

## ក. ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

(**១**) ច្រានចោលការទាមទារទាំងអស់របស់ដើមចោទ។

(**២**) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

## ខ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង

**ខ.១**. ស្ដីពីអង្គហេតុ "**ខ.១.១**" ដែលត្រូវបានសរសេរនៅក្នុងពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ទាំងស្រុង។

**ខ.២**. ស្ដីពីអង្គហេតុសងប្រាក់មួយភាគ "**ខ.១.២**" ដែលត្រូវបានសរសេរនៅក្នុងពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់នូវកាតប្រគល់ប្រាក់ឲ្យទៅដើមចោទចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១២ ចំពោះអង្គហេតុក្រៅពីនេះ ចុងចម្លើយមិនទទួលស្គាល់ទេ។

នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១២ ចុងចម្លើយបានប្រគល់ប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិកឲ្យទៅដើមចោទ ប៉ុន្តែ ប្រាក់នេះ គឺជាការសងបំណុលផ្សេង ហើយមិនមែនជាការសងទៅលើសិទ្ធិលើបំណុលជាប្រាក់ដែលដើមចោទកំពុងទាមទារនៅក្នុងរឿងក្ដីនេះទេ។ ពោលគឺ នៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០១២ ចុងចម្លើយបានលក់នំធ្វើពីផ្លែឈើចំនួន ១០.០០០ កញ្ចប់ដែលសរុបទឹកប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកឲ្យទៅដើមចោទ ហើយដោយសារតែដើមចោទបាននិយាយថា នៅក្នុងចំណោមនំទាំងនោះ មានចំនួន ៥០០ កញ្ចប់ដែលខូច ហើយមិនអាចយកមកលក់បានទេ ហេតុដូច្នេះហើយ នៅថ្ងៃទី ៣១ ខែ តុលាឆ្នាំ២០១២ ចុងចម្លើយបានបង់ប្រាក់ ១.០០០ (មួយពាន់) ដុល្លារអាមេរិកឲ្យទៅដើមចោទជាថ្លៃសងការខូចខាតចំពោះទំនិញទាំងនោះ។

**ខ.៣**. ស្ដីពីអង្គហេតុ "**ខ.២**" ដែលសរសេរនៅក្នុងពាក្យបណ្ដឹង ៖ ចុងចម្លើយមានវិវាទ។

ដូចដែលបានលើកឡើងនៅខាងលើ នៅក្នុងរឿងក្តីនេះ ដោយសារតែអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានសម្រេចឡើង ដូច្នេះ ចុងចម្លើយមិនមានករណីយកិច្ចបង់ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចទេ។

## គ. អង្គហេតុតវ៉ា

### គ.១. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ចុងចម្លើយបានលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។

ពោលគឺ បើគិតចាប់ពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០០៨ ដែលជាពេលកំណត់ត្រូវសងនៃប្រាក់កម្ចីក្នុងរឿងក្តីនេះមក នាំឲ្យថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៣ ដែលជាអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានកន្លងផុត។ ចុងចម្លើយលើកឡើងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលខាងលើតាមរយៈឯកសារចម្លើយ។

### គ.២. ការទូរទាត់

នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ចុងចម្លើយបានលក់រថយន្តក្នុងតម្លៃ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក (**ភស្តុតាង** Y1) និងបានប្រគល់រថយន្ត ក (**ភស្តុតាង** Y2) ទៅឲ្យដើមចោទ ចំពោះថ្លៃលក់រថយន្តចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកនោះ ចុងចម្លើយបានដាស់តឿនឲ្យបង់ជាច្រើនលើកច្រើនសារប៉ុន្តែដើមចោទមិនបានបង់ឡើយ។

ក្នុងករណីតុលាការមិនទទួលស្គាល់អំពីការតវ៉ាស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ ចុងចម្លើយបង្ហាញឆន្ទៈទូទាត់នូវទឹកប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិកនៃសិទ្ធិលើបំណុលនៃប្រសក់ថ្លៃលក់ទិញខាងលើនេះជាមួយនឹងកាតព្វកិច្ចប្រាក់កម្ចីក្នុងចំនួនសមស្រប។

**ដូច្នេះ ចុងចម្លើយមិនមានករណីយកិច្ចបង់ប្រាក់ដើម និងប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ចដោយផ្អែកលើកិច្ចសន្យានៃរឿងក្តីនេះឲ្យដើមចោទទេ។**

## ឃ. ភស្តុតាង

១. លិខិតកិច្ចសន្យាទិញលក់រថយន្ត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៣ (**ភស្តុតាង** Y1)

២. លិខិតប្រគល់ទទួលរថយន្ត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៣(**ភស្តុតាង** Y2)

សូម **លោកចៅក្រម** សម្រេចតាមការអះអាងខាងលើ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤

**អ្នកតំណាងដោយអាណត្តិ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ឯកសារត្រៀមលើកទី១របស់ដើមចោទ

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក / លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី /ក្រុមហ៊ុនមេធាវី ៖......................................................

ការិយាល័យមេធាវី / ក្រុមមេធាវី /ក្រុមហ៊ុនមេធាវី ៖.......................................................................

លេខទូរស័ព្ទ ៖ .....................................................................................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី / ក្រុមមេធាវី /ក្រុមហ៊ុនមេធាវី ៖................................................

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់បនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោក J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u> ៖** សុំដាក់**ឯកសារត្រៀមលើកទី១ របស់ដើមចោទ** ដើម្បីឆ្លើយតបចំពោះឯកសារចម្លើយរបស់ឈ្មោះ Y ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤ របស់ឈ្មោះ X

**<u>យោង</u> ៖** -មាត្រា **១០១ កថាខណ្ឌទី៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ......................ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤

**ក. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង**

**ក.១.** អង្គហេតុដែលមានសរសេរនៅក្នុងចំណុច "**ខ.២**" នៃឯកសារចម្លើយ ៖ ដើមចោទទទួលស្គាល់ថាបាន ទិញនំផ្លែឈើ ចំនួន ១០.០០០ កញ្ចប់ ក្នុងតម្លៃ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិកពីចុងចម្លើយនៅថ្ងៃទី ៣០

ខែ កញ្ញា ឆ្នាំ ២០១២ ហើយនៅក្នុងចំណោមនំ ១០.០០០ កញ្ចប់នោះមាន ៥០០ កញ្ចប់ដែលខូច ហើយដើមចោទមិនទទួលស្គាល់ចំពោះអង្គហេតុក្រៅពីនេះ។

ចំពោះនំ ៥០០ កញ្ចប់ដែលលើកឡើងខាងលើនេះ មិនមែនថា មិនអាចលក់ចេញនោះទេ ហើយតាមការពិតដើមចោទបានលក់អស់ហើយហេតុនេះ ដើមចោទគ្រាន់តែព្រមានមិនឲ្យដាក់របស់បែបនេះទៀតពេលក្រោយ ហើយមិនបានទាមទារសំណងពីចុងចម្លើយទេ។ ដើមចោទមិនបានទទួលការសងប្រាក់ទាក់ទងនឹងរឿងនំផ្លែឈើនេះពីចុងចម្លើយនោះទេ។

**ក.២**. ការអះអាងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមានសរសេរនៅក្នុងចំណុច "**គ.១**" នៃឯកសារចម្លើយ ៖ ដើមចោទមានវិវាទ។

**ក.៣**. ការអះអាងអំពីការទូទាត់ដែលមានសរសេរនៅក្នុងចំណុច "**គ.២**" នៃឯកសារចម្លើយ ៖ ដើមចោទទទួលស្គាល់ថា ចុងចម្លើយបានលក់រថយន្តក្នុងតម្លៃ ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក មកឲ្យដើមចោទនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ហើយចុងចម្លើយបានប្រគល់រថយន្តនោះមកឲ្យដើមចោទនៅថ្ងៃដដែល ហើយដើមចោទមិនទទួលស្គាល់អង្គហេតុផ្សេងក្រៅពីនេះ។

ដើមចោទបានបង់ប្រាក់ថ្លៃទិញរថយន្តឲ្យទៅចុងចម្លើយដូចក្នុងចំណុច "**ខ.២**" នៃដែលបានសរសេរខាងក្រោម។

## ខ. អង្គហេតុស្តីពីការតវ៉ាតប

**ខ.១. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល** ( **ចំពោះការតវ៉ាអំពីការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល** )

នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដើមចោទបានទទួលប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ដែលជាការសងប្រាក់កម្ចីក្នុងរឿងក្តីនេះពីចុងចម្លើយ។ នៅក្នុងលិខិតក្រគល់ ទទួលប្រាក់ដែលដើមចោទបានសរសេរ និងចេញឲ្យចុងចម្លើយ បានសរសេរអំពីខ្លឹមសារថា បានទទួលប្រាក់ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ជាការសងប្រាក់កម្ចីនៃរឿងក្តីនេះ (**ភស្តុតាង** X3)។

ដោយសារតែចុងចម្លើយបានសងប្រាក់មួយផ្នែកនៃប្រាក់កម្ចីក្នុងរឿងក្តីនេះ ដូច្នេះ នាំឲ្យអាជ្ញាយុកាលនៃការតំលត់សិទ្ធិលើបំណុលបានផ្អាក។

**ខ.២. ការសង** ( **ចំពោះការតវ៉ាអំពីការទូទាត់** )

ដើមចោទបានបងប្រាក់ចំនួន ៧.០០០ (ប្រាំពីរពាន់) ដុល្លារអាមេរិក ជថ្លៃលក់ទិញរថយន្តឲ្យទៅចុងចម្លើយនៅអំឡុងខែធ្នូ ឆ្នាំ២០១៣។

សូម **លោកចៅក្រម** សម្រេចតាមការអះអាងខាងលើ ដោយក្ដីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ មករា ឆ្នាំ ២០១៥

**អ្នកតំណាងដោយអាណត្តិ**

P

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រុមមេធាវីយុត្តិធម៌ និង សហការី
JUSTICE & ASSOCIATES
លេខ: ០៥២ /ក.ម.យ.ស/២០២៤

ប្រធានក្រុមមេធាវី
មេធាវី ស៊ុយ ឈុនហាក់
Lawyer Suy Chhunhak
អនុប្រធានក្រុមមេធាវី
១. មេធាវី សេង សុវណ្ណារី
Lawyer Seng Sovannary
២. មេធាវី ស៊ុយ សុខុន
Lawyer Suy Sokhon
សមាជិកក្រុមមេធាវី
៣. មេធាវី សេក ច័ន្ទសង្វារ
Lawyer Sek Chansangva
៤. មេធាវី អ៊ឹម កុយ
Lawyer Im Koy
៥. មេធាវី ឆេង ផាត់
Lawyer Chheng Phat
៦. មេធាវី វ៉ា វុទ្ធី
Lawyer Voir Vuthy
៧. មេធាវី អ៊ិន សុខប៉ូ
Lawyer In Sokpo
៨. មេធាវី ឈៀត ហុង
Lawyer Chheath Hong
៩. មេធាវី ច័ន្ទ តារាមុនុន
Lawyer Chan Taramonoun
១០. មេធាវី តេង បញ្ញារិទ្ធ
Lawyer Teng Panharith
១១. មេធាវី ស៊ុយ សុវណ្ណបញ្ញា
Lawyer Suy Sovanpanha
១២. មេធាវី អេង ចាន់ភារ៉ា
Lawyer Eng ChanPheara
១៣. មេធាវី សេក ពៅ
Lawyer Sek Peov
១៤. មេធាវី កែប ធា
Lawyer Kep Thea
១៥. មេធាវី សឿង អង្គាស៊ីល
Lawyer Seong Angkeasil
១៦. មេធាវី ស្រ៊ុន ឈួងហាក់
Lawyer Srun Chhounghak
១៧. មេធាវី តឹក សិរីវិចិត្រ
Lawyer Tek Sereyvichet
១៨. មេធាវី អ៊ុំ សុធា
Lawyer Oum Sothea

## សេចក្តីថ្លែងការណ៍តប

ខ្ញុំបាទមេធាវី អត្តលេខ: **២៧៧៣** ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវី នៃ **ក្រុមមេធាវីយុត្តិធម៌ និងសហការី (JUSTICE & ASSOCIATES LAW GROUP)** ដែលមានទីតាំងការិយាល័យស្ថិតនៅ៖ ផ្ទះលេខ៤២០ ផ្លូវលេខ៣៧១ ភូមិព្រែកតាគង់១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិជូនចុងចម្លើយឈ្មោះ និង នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ។

### សូមគោរពជូន

### ឯកឧត្តម ប្រធានសាលាដំបូងរាជធានីភ្នំពេញ

*សូមមេត្តាជ្រាប!*

**កម្មវត្ថុ៖** សុំជូនសេចក្តីថ្លែងការណ៍តបលើសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិឱ្យ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ។

**យោង៖**
- ពាក្យសុំធ្វើជាអ្នកតំណាងដោយអាណត្តិលេខ: ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ។ (ឯកសារថតចម្លង)
- លិខិតអញ្ជើញ **លោកមេធាវី អ៊ុំ សុធា** ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ។ (ឯកសារថតចម្លង)

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរព និងជម្រាប **ឯកឧត្តមប្រធាន** នៃ**សាលាដំបូងរាជធានីភ្នំពេញ** មេត្តាជ្រាបនូវដំណើររឿងដូចតទៅ:

### ១. អំពីអង្គហេតុ៖

កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ កូនក្តីរបស់ខ្ញុំបាទបានទទួលដំណឹងអំពី **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** បានដាក់ពាក្យមកកាន់កូនក្តីរបស់ខ្ញុំបាទនៅសាលាដំបូងរាជធានីភ្នំពេញ ដោយមានខ្លឹមសារ ដូចខាងក្រោម ៖

ក. បង្គាប់ឱ្យសហចុងចម្លើយបង់ប្រាក់ ដែលជំពាក់មកឱ្យដើមចោទដូចខាងក្រោម ៖



ទីស្នាក់ការកណ្តាល: ផ្ទះលេខ:៤២០ ផ្លូវ៣៧១ ភូមិព្រែកតាគង់១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។
Tel: 012 73 29 29, 012 86 89 46, 012 264 333, 012 98 48 40, 012 40 45 46, 017 905 805, 093 93 71 93, 076 4444 769, 076 4444 678
E-mail: jalawfirm777@gmail.com/ Website: www.ja-lawfirm.com/ ប្រអប់សំបុត្រលេខ: 5770

១. ប្រាក់ដើមដែលនៅជំពាក់ចំនួន USD៣១១,៣៨៩.០៧ (បីរយដប់មួយពាន់បីរយប៉ែតសិបប្រាំបួនដុល្លារអាមេរិក និងសូន្យប្រាំពីរសេន) ។

២. ការប្រាក់ចំនួន 0.៨៩% (សូន្យក្បៀសប៉ែតសិបប្រាំបួនភាគរយ) ក្នុងមួយខែ លើប្រាក់ដើមដែលនៅជំពាក់ គិតពីថ្ងៃ១២ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន ។

៣. ប្រាក់ពិន័យចំនួន ៣% (បីភាគរយ) ក្នុងមួយខែ នៃប្រាក់ដែលខកខានមិនបានសងគិតចាប់ពីថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន ។

ខ. បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ (ហ៊ីប៉ូតែក) របស់ដើមចោទ ចំពោះអចលនវត្ថុរបស់សហចុងចម្លើយដូចខាងក្រោម ៖

១. អចលនវត្ថុទំហំ **២,៤៨១ ម៉ែត្រក្រឡា** ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ **២៥០៦០១១០-១៩២៣** ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តត្បូងឃ្មុំ ក្រោមកម្មសិទ្ធិករឈ្មោះ ។

២. អចលនវត្ថុទំហំ **៧០ ម៉ែត្រក្រឡា** ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ **១២០៨០២០៣-០៦០០** ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ក្រោមកម្មសិទ្ធិករឈ្មោះ ។

៣. អចលនវត្ថុទំហំ **៦៤ ម៉ែត្រក្រឡា** ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ភព ៣១៨១១ (ចIV ១៥១៤)** ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ក្រោមកម្មសិទ្ធិករឈ្មោះ ។

គ. បង្គាប់ឱ្យសហចុងចម្លើយសងការចំណាយសេវាកម្មផ្លូវច្បាប់មេធាវី ការខាតបង់ពេលវេលា និងការចំណាយផ្សេងៗលើនីតិវិធីចំនួន **USD៣៥,000.00 (សាមសិបប្រាំពាន់ដុល្លារអាមេរិក)** ។

ឃ. ប្រាក់ប្រដាក់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

ង. ប្រកាសសាលក្រមអាចអនុវត្តជាបណ្តោះអាសន្នបានត្រង់ចំណុច ក១ ។

ក្រោយពីកូនក្តីរបស់ខ្ញុំបាទ ទទួលដំណឹងអំពីបណ្តឹងរបស់ ក កូនក្តីរបស់ខ្ញុំបាទ និងខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិបានចូលនីតិវិធីត្រៀមតាមលិខិតអញ្ជើញមេធាវី ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ ។ នៅក្នុងកិច្ចនីតិវិធីមេធាវីតំណាងឱ្យ បានដាក់សេចក្តីថ្លែងការណ៍លេខៈ**៦៦៣៤** ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ក្នុងនាមខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិសហចុងចម្លើយឈ្មោះ និងឈ្មោះ សូមថ្លែងការតបទៅនឹងសេចក្តីថ្លែងការណ៍លេខៈ**៦៦៣៤** ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៤ របស់ មេធាវីតំណាងដោយអាណត្តិដើមបណ្តឹងដូចខាងក្រោម ៖



**ទីស្នាក់ការកណ្តាល: ផ្ទះលេខ:៤២០ ផ្លូវ៣៧១ ភូមិព្រៃកគាត ២១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។**
Tel: 012 73 29 29, 012 86 89 46, 012 264 333, 012 98 48 40, 012 40 45 46, 017 905 805, 093 93 71 93, 076 4444 769, 076 4444 678
E-mail: jalawfirm777@gmail.com/ Website: www.ja-lawfirm.com/ ប្រអប់សំបុត្រលេខ: 5770

**ចំណុចទី ១ ៖** ការបង្កើតកិច្ចសន្យាខ្ចីប្រាក់របស់កូនក្តីខ្ញុំបាទ គឺកូនក្តីរបស់ខ្ញុំបានសូមបដិសេធចោលលើកិច្ចសន្យាខ្ចីប្រាក់ ដោយហេតុថា ការខ្ចីប្រាក់នេះ ជាបំណុលរបស់ក្រុមហ៊ុន ) ដែលកូនក្តីរបស់ខ្ញុំបានបម្រើការងារនៅទីនោះ ហើយការខ្ចីប្រាក់នេះ បានបង្វិលបំណុលក្រុមហ៊ុន ) ឱ្យកូនក្តីខ្ញុំបាទជាបំណុលឯកជន ហើយកិច្ចសន្យាដែលដើមចោទ ធ្វើជាមួយកូនក្តីខ្ញុំបាទ ជាឯកសារចន្លោះដោយមិនបានបំពេញលក្ខខ័ណ្ឌមួយចំនួន ដោយដើមចោទជាអ្នកបំពេញតាមក្រោយ ។ ហេតុនេះហើយ ជាកិច្ចសន្យាមានវិការៈក្នុងការបង្ហាញឆន្ទៈរបស់កូនក្តីខ្ញុំបាទ ដោយការផ្តិតមេដៃរបស់កូនក្តីខ្ញុំបាទ ជាក្រដាសសមិនមានការបញ្ជាក់ខ្លឹមសារសំខាន់ក្នុងកិច្ចសន្យា ។ ការបំពេញកិច្ចកាតព្វកិច្ចនៃកិច្ចសន្យាខ្ចីប្រាក់ តាមកិច្ចសន្យាខ្ចីបរិភោគគណនីកម្ចីលេខ 1250000001124 ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ កូនក្តីរបស់ខ្ញុំបាទបានអះអាងខ្លួនមិនដែលបានបំពេញកិច្ចកាតព្វកិច្ចក្នុងការបង់ប្រាក់កម្ចីនោះឡើយ ដោយសារតែការបង្កើតកិច្ចសន្យាខ្ចីបរិភោគនេះ បានធ្វើឡើងរវាងក្រុមហ៊ុន ( ) និង ហេតុដូច្នេះ ក្រុមហ៊ុន អ៊ី ជាអ្នកបំពេញកាតព្វកិច្ចក្នុងបង់ប្រាក់កម្ចីតាមកិច្ចសន្យា ។ ក្នុងករណីនេះ សូមស្នើសុំដល់ដើមបណ្តឹងផ្តល់ភស្តុតាងលើប្រតិបត្តិការក្នុងការបំពេញកាតព្វកិច្ចកម្ចីនេះនៅក្នុងគណនេយ្យរបស់ ប៊ ស៊ី ដើម្បីជាភស្តុតាងបញ្ជាក់ ដល់ក្នុងនីតិវិធីតុលាការ ។

**ចំណុចទី២ ៖** ចំពោះការប្រគល់ទទួលប្រាក់ ផ្អែកតាម **<u>ប្រការ១ ៖ លក្ខខណ្ឌឥណទាន</u>** នៃកិច្ចសន្យាខ្ចីបរិភោគគណនីកម្ចីលេខ 1250000001124 ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ នៅក្នុងចំណុចនេះផងដែរ កូនក្តីរបស់ខ្ញុំបាទ បានអះអាងថា កូនក្តីរបស់ខ្ញុំបាទមិនបានទទួល ឬផ្ទេរប្រាក់ទៅកាន់កូនក្តីរបស់ខ្ញុំឡើយ ។ នៅក្នុងចំណុចទី២ នៃការថ្លែងការណ៍តបនេះ បើដើមបណ្តឹងមានការអះអាងអំពីការប្រគល់ ឬការផ្ទេរប្រាក់ទៅកាន់កូនក្តីរបស់ខ្ញុំបាទ សូមដើមបណ្តឹងដាក់ភស្តុតាងដើម្បីបញ្ជាក់អំពីការប្រគល់ ឬការផ្ទេរប្រាក់នេះ ។

**ចំណុចទី៣ ៖** ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកទាំង ៣ (បី) ទីតាំងខាងក្រោម ៖

១. អចលនវត្ថុទំហំ **២,៤៨១ ម៉ែត្រក្រឡា** ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ **២៥០៦០១១០-១៤២៣** ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តត្បូងឃ្មុំ ក្រោមកម្មសិទ្ធិករឈ្មោះ ។

២. អចលនវត្ថុទំហំ **៧០ ម៉ែត្រក្រឡា** ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ **១២០៨០២០៣-០៦០០** ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ក្រោមកម្មសិទ្ធិករឈ្មោះ ។

៣. អចលនវត្ថុទំហំ **៦៤ ម៉ែត្រក្រឡា** ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ **ភព៣១៨១១ (ចIV ១៥១៤)** ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ក្រោមកម្មសិទ្ធិករឈ្មោះ ។



**ទីស្នាក់ការកណ្តាល: ផ្ទះលេខ:៤២០ ផ្លូវ៣៧១ ភូមិព្រៃកគាគទី១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។**
Tel: 012 73 29 29, 012 86 89 46, 012 264 333, 012 98 48 40, 012 40 45 46, 017 905 805, 093 93 71 93, 076 4444 769, 076 4444 678
E-mail: jalawfirm777@gmail.com/ Website: www.ja-lawfirm.com/ ប្រអប់សំបុត្រលេខ: 5770

នៅក្នុងចំណុចនៃការបង្កើតកិច្ចសន្យានេះ កូនក្តីរបស់ខ្ញុំបាទបានអះអាងខ្លួនពុំបានស្គាល់អំពីកម្មសិទ្ធិករខាងលើនោះឡើយ ហើយខ្លួនមានសិទ្ធិណាមួយដើម្បីឱ្យម្ចាស់កម្មសិទ្ធិអនុញ្ញាតិដល់ខ្លួនក្នុងការបង្កើតកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនោះឡើយ ដោយកូនក្តីរបស់ខ្ញុំបាទបានអះអាងបន្ថែមថារាល់កិច្ចសន្យាដែលខ្លួនបានធ្វើឡើងគឺមិនមានការបំពេញខ្លឹមសារពេញលេញ ហើយជាការរៀបចំរវាងក្រុមហ៊ុន និង ( ខ្លួនបានត្រឹមតែផ្តិតមេដៃលើកិច្ចសន្យានោះឡើយ ។ ការបង្កើតកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនេះ ជាកិច្ចសន្យាមួយបង្កើតឡើយដោយមិនមានការផ្អែកទៅលើសិទ្ធិនៃកម្មសិទ្ធិលើអចលនវត្ថុ នៃការបង្កើតកិច្ចសន្យានោះឡើយ ។

## ២. អំពីគតិច្បាប់៖

### ១-ក្រមរដ្ឋប្បវេណី (អនុម័តនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ ) នៃព្រះរាជាណាចក្រកម្ពុជា

**យោងតាមបញ្ញត្តិ មាត្រា ៣៤៥ ៖ ការបង្ហាញឆន្ទៈដែលមានវិការៈ** នៃក្រមរដ្ឋប្បវេណី បានចែងថា៖

*អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ តាមបញ្ញត្តិនៃផ្នែកទី២ (វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា) នេះ និង ផ្នែកទី៣ (មោឃភាព និង ការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ ៖*

*ក-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើដោយការភាន់ច្រឡំ ។*

*ខ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើយដោយការឆបោក ឬ ការគម្រាមកំហែង ឬ ការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត ។*

*គ-ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពីឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ ។*

**យោងតាមបញ្ញត្តិ មាត្រា ៣៤៩ កថាខណ្ឌទី១ ៖ ការរំលោភបំពានលើស្ថានភាព** នៃក្រមរដ្ឋប្បវេណី បានចែងថា៖

*នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើប្រាស់ខ្លួនដែលមានអាទិភាពជាភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។*

**យោងតាមបញ្ញត្តិ មាត្រា ៣៥០ ៖ ការគម្រាមកំហែង** នៃក្រមរដ្ឋប្បវេណី បានចែងថា៖

*បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬ ពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។*



ទីស្នាក់ការកណ្តាល: ផ្ទះលេខ:៤២០ ផ្លូវ៣៧១ ភូមិព្រៃកគាគទី១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។
Tel: 012 73 29 29, 012 86 89 46, 012 264 333, 012 98 48 40, 012 40 45 46, 017 905 805, 093 93 71 93, 076 4444 769, 076 4444 678
E-mail: jalawfirm777@gmail.com/ Website: www.ja-lawfirm.com/ ប្រអប់សំបុត្រលេខ: 5770

**ចតាមបញ្ញត្តិ មាត្រា ៣៥២ ៖ ឋបនីយផ្លូវចិត្ត** នៃក្រមរដ្ឋប្បវេណី បានចែងថា៖

*ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរាំងនូវអនុភាពឡើយ ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ។*

## ៣. សេចក្តីសន្និដ្ឋាន៖

ផ្អែកតាមអង្គហេតុ , សេចក្តីថ្លែងការណ៍របស់កូនក្តីយើងខ្ញុំ និងអង្គច្បាប់ ខាងលើ កូនក្តីរបស់យើងខ្ញុំបាទមិនមានឆន្ទៈក្នុងការបង្កើតកិច្ចសន្យាខ្ចីបរិភោគជាមួយ ( , ជាបំណុលឯកជននោះឡើយ ដោយខាងក្រុមហ៊ុន អ្នករៀបចំឯកសារក្នុងការបង្កើតកិច្ចសន្យានេះ ហើយកូនក្តីរបស់ខ្ញុំបាទដោយយល់បំណងរបស់ក្រុមហ៊ុន( របស់ខ្លួនទទួលខុសត្រូវលើការសងនោះ ហើយការបំពេញកាតព្វកិច្ចក្នុងការសងបំណុលគឺក្រុមហ៊ុន , វាអ្នកបំពេញកាតព្វកិច្ចដោយការសង ។ ស្របតាមបញ្ញត្តមាត្រា **៣៥២ ៖** ប្រសិនបើកិច្ចសន្យាត្រូវបានបង្កើតឡើង ដោយការបង្ហាញឆន្ទៈដែលភាគីដឹងខ្លួនថាខុសឆន្ទៈពិតរបស់ខ្លួន កិច្ចសន្យានោះមិនត្រូវរាំងនូវអនុភាពឡើយ ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាងទៀតក៏ដឹងថាការបង្ហាញឆន្ទៈនោះ ខុសនឹងឆន្ទៈពិតរបស់អ្នកបង្ហាញឆន្ទៈដែរ អ្នកបង្ហាញឆន្ទៈនោះអាចបដិសេធការអនុវត្តកិច្ចសន្យាបាន ។

## ៤. សំណូមពរ៖

ដូចសេចក្តីជម្រាបជូនខាងលើ អំពីអង្គហេតុ និងអង្គច្បាប់ ខ្ញុំបាទមេធាវីតំណាងដោយអាណត្តិសូមស្នើសុំនូវសំណូមពរជូនដល់ **ឯកឧត្តមប្រធាន** មេត្តាសម្រេច៖

១. លើកចោលពាក្យបណ្តឹងចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ របស់ដើមចោទ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី** ទុកជាអសារបង់។

២. ស្នើសុំប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេចដល់កូនក្តីខ្ញុំបាទដោយក្តីអនុគ្រោះបំផុត ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ថ្ងៃ ចន្ទ ៥រោច ខែ ពិសាខ ឆ្នាំ រោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤

**ហត្ថលេខា និងត្រា**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA



ទីស្នាក់ការកណ្តាល: ផ្ទះលេខ:៤២០ ផ្លូវ៣៧១ ភូមិព្រៃកគាងទី១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។
Tel: 012 73 29 29, 012 86 89 46, 012 264 333, 012 98 48 40, 012 40 45 46, 017 905 805, 093 93 71 93, 076 4444 769, 076 4444 678
E-mail: jalawfirm777@gmail.com/ Website: www.ja-lawfirm.com/ ប្រអប់សំបុត្រលេខ: 5770

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រុមមេធាវីយុត្តិធម៌ និង សហការី
JUSTICE & ASSOCIATES
លេខ:............/ក.ម.យ.ស/២០.......

ប្រធានក្រុមមេធាវី
មេធាវី ស៊ុយ ឈុនហាក់
Lawyer Suy Chhunhak
សមាជិកក្រុមមេធាវី
១. មេធាវី សេង សុវណ្ណារី
Lawyer Seng Sovannary
២. មេធាវី ស៊ុយ សុខុន
Lawyer Suy Sokhon
៣. មេធាវី ជ័យ ឥន្ទតេរ៉ូ
Lawyer Chey Entero
៤. មេធាវី ឆេង ផាត់
Lawyer Chheng Phat
៥. មេធាវី អ៊ឹម កុយ
Lawyer Im Koy
៦. មេធាវី សេក ច័ន្ទសង្វា
Lawyer Sek Chansangva
៧. មេធាវី អ៊ឹង សុធី
Lawyer Ing Sothy
៨. មេធាវី អ៊ុក ស៊ីរឿន
Lawyer Ouk Syroeun
៩. មេធាវី ស៊ុយ វុទ្ធី
Lawyer Suy Vuthy
៩. មេធាវី វ៉ រ វុទ្ធី
Lawyer Voir Vuthy
១០. មេធាវី អ៊ិន សុខប៉ូ
Lawyer In Sokpo
១១. មេធាវី ឈៀត ហុង
Lawyer Chheath Hong
១២. មេធាវី ហួត លីហួរ
Lawyer Hout Lyhour
១៣. មេធាវី ច័ន្ទ តារាមុនុន
Lawyer Chan Taramonoun
១៤. មេធាវី តេង បញ្ញារិទ្ធ
Lawyer Teng Panharith
១៥. មេធាវី ជ្រា ឈុនលៀង
Lawyer Chrea Chhunleng
១៦. មេធាវី ស៊ុយ សុវណ្ណបញ្ញា
Lawyer Suy Sovanpanha
១៧. មេធាវី ឈន ពេជ្រអរុណរះ
Lawyer Chhon PechArunras
១៨. មេធាវី ហ៊ុច សុខសាន្ត
Lawyer Huch Soksant
១៩. មេធាវី សេក ពៅ
Lawyer Sek Peov
២០. មេធាវី អេង ចាន់ភារ៉ា
Lawyer Eng ChanPheara
២១. មេធាវី គីម វិញ្ញូរិទ្ធិ
Lawyer Kim Vinhourith
២២. មេធាវី ជឿន សុខហេង
Lawyer Choeun Sokheng
២៣. មេធាវី ភួង ប៉ោឆាយ
Lawyer Phoung Porchhay
២៤. មេធាវី កែប ធា
Lawyer Kep Thea
២៥. មេធាវី ភួង ស្រីឡែន
Lawyer Phoung Sreylen
២៦. មេធាវី សឿង អង្គារស៊ីល
Lawyer Seong Angkeasil
២៧. មេធាវី គង់ ច័ន្ទសុវណ្ណដា
Lawyer Kong Chansovanda
២៨. មេធាវី តឹក សិរីវិចិត្រ
Lawyer Tek Sereyvichet
២៩. មេធាវី ស្រេង ម៉ីម៉ី
Lawyer Sreng Meimei
៣០. មេធាវី អ៊ុំ សុធា
Lawyer Oum Sothea

# ពាក្យសុំផ្ទេរសមត្ថកិច្ចសាលាជម្រះក្តី

ខ្ញុំបាទមេធាវី **អ៊ុំ សុធា** អត្តលេខៈ **២៧៧៣** ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យនៅ **ក្រុមមេធាវីយុត្តិធម៌ និង សហការី ( JUSTICE & ASSOCIATES LAW GROUP)** ដែលមានទីស្នាក់ការកណ្តាលផ្ទះលេខៈ៤២០ ផ្លូវលេខៈ៣៧១ ភូមិព្រៃកគាគង់១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ តំណាងដោយអាណត្តិឈ្មោះ **ក** ភេទស្រី **«ចុងចម្លើយ»** នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ AAAA ចុះថ្ងៃទីA ខែកុម្ភៈ ឆ្នាំ២០២៣ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ។

លេខទូរស័ព្ទទំនាក់ទំនង៖ **០១២ ២៣៧ ២៥៩ / ០៨៨ ៨៨៨ ៩៣៣៧** ។

## សូមគោរពជូន
## ឯកឧត្តម ប្រធានសាលាដំបូងរាជធានីភ្នំពេញ

*សូមមេត្តាជ្រាប!*

**កម្មវត្ថុ:** សំណើរសុំផ្ទេរសមត្ថកិច្ចសាលាជម្រះក្តីនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ទៅកាន់សមត្ថកិច្ចសាលាជម្រះក្តី **សាលាដំបូងខេត្តកំពង់ឆ្នាំង** ។

**យោង:**
- មាត្រា៨, មាត្រា**១៤** និងមាត្រា**១៨** ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ ( ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ របស់ឈ្មោះ ។ (ឯកសារថតចម្លង)
- សៀវភៅស្នាក់នៅលេខៈ ( ប.ក្បាលទី **០៧** ទំព័រ **៥១** ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ ចេញដោយ **ប៉ុស្តិ៍ នគរបាលរដ្ឋបាលអភិវឌ្ឍន៍ អនុសេនីយ៍ឯក អ៊ិន សុភាព** ។ (ឯកសារថតចម្លង)
- សំណុំរឿងចាត់ចែងរក្សាការពារលេខៈ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ របស់ **សាលាដំបូងខេត្តកំពង់ឆ្នាំង** ។ (ឯកសារថតចម្លង)
- ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខៈ ( ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ របស់ **សាលាដំបូងខេត្តកំពង់ឆ្នាំង** ។ (ឯកសារថតចម្លង)

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំ សូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ ឈ្មោះ និងឈ្មោះ បានដាក់ពាក្យ

បណ្ដឹងទាមទារប្រាក់ដល់រូបនាងខ្ញុំនៅ **សាលាដំបូងរាជធានីភ្នំពេញ** ក្រោយមកនៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ សាលាដំបូងរាជធានីភ្នំពេញបានចេញដីកាកោះហៅនាងខ្ញុំចូលក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅក្នុង សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ។ នៅក្នុង ការដាក់ពាក្យបណ្ដឹងរបស់ឈ្មោះ និងឈ្មោះ នៅក្នុងដែនសមត្ថកិច្ច**សាលាដំបូងរាជធានីភ្នំពេញ** គឺនាងខ្ញុំមិនមានអាសយដ្ឋានស្នាក់នៅរាជធានីភ្នំពេញនោះឡើយ ដោយបច្ចុប្បន្ននាងខ្ញុំមាន អាសយដ្ឋានអចិន្ត្រៃយ៍ពិតប្រាកដនៅខេត្តកំពង់ឆ្នាំង ដោយការប្ដឹងរបស់ឈ្មោះ និងឈ្មោះ បានធ្វើឱ្យនាងខ្ញុំពិបាកក្នុងការធ្វើដំណើរ ហើយពិបាកក្នុងការចូលរួមនីតិវិធីរបស់តុលាការ បន្ថែមពីនោះ ឈ្មោះ បានដាក់សំណុំរឿងរក្សាការពារលើផ្ទះរបស់នាងខ្ញុំនៅខេត្តកំពង់ឆ្នាំងបន្ទាប់មកបានជាដាក់ ពាក្យបណ្ដឹងទាមទារប្រាក់នាងខ្ញុំនៅរាជធានីភ្នំពេញទៅវិញ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្ដមប្រធាន** មេត្តាទទួល និង សម្រេចតាមសំណើស្នើ សុំរបស់នាងខ្ញុំដោយសេចក្ដីអនុគ្រោះ ។

សូម **ឯកឧត្ដមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

ថ្ងៃពុធ ៨រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣
**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា
**KINGDOM OF CAMBODIA**
ជាតិ សាសនា ព្រះមហាក្សត្រ
**NATION RELIGION KING**

**ក្រុមមេធាវីយុត្តិធម៌ និង សហការី**
JUSTICE & ASSOCIATES
លេខ:................../ក.ម.យ.ស/២០.........


**ប្រធានក្រុមមេធាវី**
មេធាវី ស៊ុយ ឈុនហាក់
Lawyer Suy Chhunhak

**អនុប្រធានក្រុមមេធាវី**
១. មេធាវី សេង សុវណ្ណារី
Lawyer Seng Sovannary
២. មេធាវី ស៊ុយ សុខុន
Lawyer Suy Sokhon

**សមាជិកក្រុមមេធាវី**
៣. មេធាវី សេក ច័ន្ទសង្វារ
Lawyer Sek Chansangva
៤. មេធាវី អ៊ឹម កុយ
Lawyer Im Koy
៥. មេធាវី ឆេង ផាត់
Lawyer Chheng Phat
៦. មេធាវី វ៉ រ វុទ្ធី
Lawyer Voir Vuthy
៧. មេធាវី អ៊ិន សុខប៉ូ
Lawyer In Sokpo
៨. មេធាវី ឈៀត ហុង
Lawyer Chheath Hong
៩. មេធាវី ច័ន្ទ តារាមុនី
Lawyer Chan Taramonoun
១០. មេធាវី តេង បញ្ញារិទ្ធ
Lawyer Teng Panharith
១១. មេធាវី ស៊ុយ សុវណ្ណបញ្ញា
Lawyer Suy Sovanpanha
១២. មេធាវី អេង ចាន់ភារ៉ា
Lawyer Eng ChanPheara
១៣. មេធាវី សេក ពៅ
Lawyer Sek Peov
១៤. មេធាវី កែប ធា
Lawyer Kep Thea
១៥. មេធាវី សឿង អង្គារស៊ិល
Lawyer Seong Angkeasil
១៦. មេធាវី ស្រ៊ុន ឈួងហាក់
Lawyer Srun Chhounghak
១៧. មេធាវី តឹក សិរីវិចិត្រ
Lawyer Tek Sereyvichet
១៨. មេធាវី អ៊ុំ សុធា
Lawyer Oum Sothea


# ពាក្យសុំពន្យារពេលចូលរួមនីតិវិធី

ខ្ញុំបាទមេធាវី អត្តលេខ: **២៧៧៣** ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យ **ក្រុមមេធាវីយុត្តិធម៌ និង សហការី (JUSTICE & ASSOCIATES LAW GROUP )** មានទីស្នាក់ការនៅផ្ទះលេខ: ៤២០ ផ្លូវលេខ: ៣៧១ ភូមិព្រៃកគាគង់១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ទូរស័ព្ទលេខ: **០១២-០៩៨ ២៣៧ ២៥៩ / ០៨៨ ៨៨៨ ៩៣៣៧** ។

## សូមគោរពជូន

## ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ

*សូមមេត្តាជ្រាប!*

**កម្មវត្ថុ:** សំណើសុំពន្យាពេលចូលរួមនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល **នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង ០៩: ០០ នាទីព្រឹក ជាន់ទី៣ បន្ទប់«ញ»** ក្នុងសំណុំរឿងរដ្ឋប្បវេណី លេខ: ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ។

**យោង:** - មាត្រា ៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

- សំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ របស់ **សាលារាជធានីភ្នំពេញភ្នំពេញ** ។
- ពាក្យសុំធ្វើជាអ្នកតំណាងដោយអាណត្តិលេខ: របស់ លោកមេធាវី **អ៊ុំ សុធា** ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ ។
- ពាក្យស្នើសុំពិនិត្យ និង ថតចម្លងសំណុំរឿងទាំងមូលលេខ: របស់ លោកមេធាវី **អ៊ុំ សុធា** ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរព និងជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤ **សាលារាជធានីភ្នំពេញ** បានចេញ**ដីកាកោះ**កូនក្តីរបស់ខ្ញុំបាទដើម្បីឱ្យចូលរួមកិច្ចនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល **នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ០៩: ០០ នាទីព្រឹក ជាន់ទី៣ បន្ទប់«ញ»** ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ របស់ **សាលាដំបូងរាជធានីភ្នំពេញ** ។ ខ្ញុំបាទសូមស្នើសុំពន្យាពេលកិច្ចនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ខាងលើ **ដោយមូលហេតុថា៖** *កូនក្តីខ្ញុំបាទគាត់ទើបតែបាន*




**ទីស្នាក់ការកណ្តាល: ផ្ទះលេខ:៤២០ ផ្លូវ៣៧១ ភូមិព្រៃកគាគង់១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។**
Tel: 012 73 29 29, 012 86 89 46, 012 264 333, 012 98 48 40, 012 40 45 46, 017 905 805, 093 93 71 93, 076 4444 769, 076 4444 678
E-mail: jalawfirm777@gmail.com/ Website: www.ja-lawfirm.com/ ប្រអប់សំបុត្រលេខ: 5770

*ប្រគល់សិទ្ធិដល់រូបខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិ ។* ហេតុដូច្នេះ ខ្ញុំបាទសូមពន្យារពេលកិច្ចនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៅពេលក្រោយដើម្បីឱ្យខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិ សិក្សាសំណុំរឿងឱ្យបានស៊ីជម្រៅ និងរៀបចំឯកសារផ្សេងៗដែលជាផលប្រយោជន៍របស់កូនក្តីខ្ញុំបាទទៅតាមនីតិវិធីច្បាប់ ខ្ញុំបាទស្នើសុំចូលរួមកិច្ចនីតិវិធីរបស់សាលារាជធានីភ្នំពេញនៅពេលក្រោយ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេចពន្យាពេលដល់ខ្ញុំបាទជាមេធាវីតំណាងដោយអាណត្តិដល់កូនក្តីតាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះបំផុត ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ថ្ងៃចន្ទ ១៤កើត ខែចេត្រ ឆ្នាំ រោង ឆស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៤

**ហត្ថលេខា និងត្រា**



**ទីស្នាក់ការកណ្តាល: ផ្ទះលេខ:៤២០ ផ្លូវ៣៧១ ភូមិព្រែកតាគង់១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។**
Tel: 012 73 29 29, 012 86 89 46, 012 264 333, 012 98 48 40, 012 40 45 46, 017 905 805, 093 93 71 93, 076 4444 769, 076 4444 678
E-mail: jalawfirm777@gmail.com/ Website: www.ja-lawfirm.com/ ប្រអប់សំបុត្រលេខ: 5770

សាលាដំបូងខេត្តតាកែវ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## កំណត់ហេតុស្តីពីការសះជា

សញ្ញាណនៃរឿងក្តី ៖ រឿងរដ្ឋប្បវេណីលេខ: ៣៦៨ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២

កាលបរិច្ឆេទ ៖ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ៨ និង ៤០នាទីព្រឹក

ទីកន្លែង ៖ សាលាដំបូងខេត្តតាកែវ

ចៅក្រម ៖ លោកស្រី **ឌៃ រចនា** ចៅក្រមសាលាដំបូងខេត្តតាកែវ

ក្រឡាបញ្ជី ៖ លោក **ស៊ឹម សុផល** ក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

ភាគីដែលបង្ហាញខ្លួន ៖

-ដើមចោទ [redacted] មានការិយាល័យកណ្តាលស្ថិតនៅជាន់ផ្ទាល់ដី និងជាន់ទី១ នៃអាគារបីរ៍ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ តំណាងស្របច្បាប់ដោយឈ្មោះ [redacted] ភេទប្រុស ជនជាតិកូរ៉េ កើតថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៦៩ ជាអគ្គនាយកប្រតិបត្តិ ដោយមានលោក [redacted] មានអត្តលេខ៖ ២១៦២ និងលោកស្រី [redacted] មានអត្តលេខ៖ ២១២៥ ជាមេធាវីតំណាងដោយអាណត្តិ។

-សហចុងចម្លើយឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៨១ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖ [redacted] ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៤ និងឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៨៨ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ៖ [redacted] ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ មានទីលំនៅបច្ចុប្បន្ននៅភូមិចានទាប ឃុំសំរោង ស្រុកត្រាំកក់ ខេត្តតាកែវ។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ: សុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម:

១-បង្គាប់ឱ្យសហចុងចម្លើយបង់ប្រាក់ដើមចំនួន USD ៩,៤៤៧.៥០ (ប្រាំបួនពាន់បួនរយសែសិបប្រាំពីរដុល្លារអាមេរិកនិងហាសិបសេន) និងការប្រាក់ចំនួន ១.៤០% (មួយក្បៀសសែសិបភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន USD ៩,៤៤៧.៥០ (ប្រាំបួនពាន់បួនរយសែសិបប្រាំពីរដុល្លារអាមេរិកនិងហាសិបសេន) មកឱ្យដើមចោទ [redacted] ភីអិលស៊ី គិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ រហូតដល់ពេលសហចុងចម្លើយសងគ្រប់ចំនួនមកឱ្យដើមចោទ។

២-បង្គាប់ឱ្យសហចុងចម្លើយបង់ប្រាក់ពិន័យស្មើរនឹង ២៤% (ម្ភៃបួនភាគរយ) ក្នុងមួយឆ្នាំ លើទឹកប្រាក់ជំពាក់ចំនួន USD ៩,៤៤៧.៥០ (ប្រាំបួនពាន់បួនរយសែសិបប្រាំពីរអាមេរិក និងហា

CamScanner

សិបសេន) ដែលខកខានសងគិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ រហូតដល់ពេលសហចុងចម្លើយសងគ្រប់ចំនួនមកឱ្យដើមចោទ។

៣-បង្គាប់ឱ្យសហចុងចម្លើយ សងការខូចខាតពេលវេលា និងសេវាច្បាប់ចំនួន USD ១០,០០០.០០ (ដប់ពាន់ដុល្លារអាមេរិកគត់) ឱ្យដើមចោទ។

៤-សុំឱ្យតុលាការទទួលស្គាល់ម្ចាស់បំណុល ហានរក្សាភាពលើសិទ្ធិប្រាតិភោគលើទ្រព្យណានា។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

៦-សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន។

នាពេលនេះភាគីដើមចោទ និងសហចុងចម្លើយបានយល់ព្រមព្រមព្រៀងជានៅចំពោះមុខយើងដូចខាងក្រោម៖

១.សហចុងចម្លើយឈ្មោះ [redacted] ទទួលស្គាល់នូវប្រាក់ដើមដែលពួកខ្លួនជំពាក់ដើមចោទ [redacted] សរុបចំនួន USD ៥,៤៤៧.៥០ (ប្រាំបួនពាន់បួនរយសែសិបប្រាំពីរដុល្លារអាមេរិក និងហាសិបសេន)។

២.ដើមចោទ [redacted] យល់ព្រមបញ្ចុះការប្រាក់ចំនួនពាក់កណ្តាលនៃការប្រាក់ចំនួន ១.៤០% (មួយក្បៀសសែសិបភាគរយ) ដោយនៅសល់ត្រឹមចំនួន ០.៧០% (សូន្យក្បៀសចិតសិបភាគរយ) ក្នុងមួយខែលើប្រាក់ដើមចំនួន USD ៥,៤៤៧.៥០ (ប្រាំបួនពាន់បួនរយសែសិបប្រាំពីរដុល្លារអាមេរិក និងហាសិបសេន) គិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ រហូតថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ឱ្យទៅសហចុងចម្លើយឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted]។

៣.ដើមចោទ [redacted] យល់ព្រមបញ្ចុះប្រាក់ពិន័យចំនួនពាក់កណ្តាល នៃប្រាក់ពិន័យសរុបចំនួន ២៤% (ម្ភៃបួនភាគរយ) ដោយនៅសល់ត្រឹមចំនួន ១២% (ដប់ពីរភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន USD ៥,៤៤៧.៥០ (ប្រាំបួនពាន់បួនរយសែសិបប្រាំពីរអាមេរិក និងហាសិបសេន) ដែលខកខានសងគិតចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ រហូតថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ឱ្យទៅសហចុងចម្លើយឈ្មោះ [redacted] និងប្រពន្ធឈ្មោះ [redacted]។

៤.ដើមចោទ [redacted] យល់ព្រមទទួលយកសំណងជំងឺចិត្ត ការខាតបង់ពេលវេលា និងសេវាផ្លូវច្បាប់ពីសហចុងចម្លើយឈ្មោះ [redacted] និងប្រពន្ធឈ្មោះ ឡាវ សំបូរ ចំនួន USD ១,០០០.០០ (មួយពាន់ដុល្លារអាមេរិកគត់)។

៥.ក្នុងករណីដែលសហចុងចម្លើយឈ្មោះ [redacted] ពុំបានអនុវត្តតាមខ្លឹមសារនៃចំណុចទី១, ទី២, ទី៣ និងទី៤ នៅក្នុងកំណត់ហេតុស្តីពីការសះជានេះទេ នោះដើមចោទ [redacted] មានសិទ្ធិដាក់ពាក្យសុំអនុវត្តដោយបង្ខំលើប្រាក់ដើមចំនួន USD ៥,៤៤៧.៥០ (ប្រាំបួនពាន់ បួនរយសែសិបប្រាំពីរដុល្លារ អាមេរិក និងហាសិបសេន) និងការប្រាក់ ព្រមទាំងប្រាក់ពិន័យតាមច្បាប់ និងសហចុងចម្លើយត្រូវបង់សងសំណងជំងឺចិត្ត ការខាតបង់ពេលវេលា និងសេវាផ្លូវច្បាប់បន្ថែមទៀតចំនួន USD ៣,០០០.០០

ណា.

(បីពាន់ដុល្លារអាមេរិកគត់) ឱ្យទៅដើមចោទ [
ស៊ី។

<u>តាមបញ្ញត្តិមាត្រា ២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី កំណត់ក្រាសះជានៅក្នុងកំណត់ហេតុនេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ។</u>

ចៅក្រមៈ ប្រកាសបិទបញ្ចប់កំណត់ហេតុស្តីពីការសះជានាពេលនេះ។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោងដប់មួយ និងសែសិបនាទីព្រឹក នាថ្ងៃខែឆ្នាំដដែល។

បានអាននូវខ្លឹមសារទាំងស្រុងរបស់កំណត់ហេតុឱ្យភាគីស្តាប់ឆ្លើយថាត្រឹមត្រូវ និងព្រមផ្តិតមេដៃទុកជាចំណាំចំពោះមុខយើង។

ក្រឡាបញ្ជី　　　　　　　　　　ចៅក្រម

មេធាវីដើមចោទ　　　　ដើមចោទ　　　　សហចុងចម្លើយ

សាលាដំបូងរាជធានីភ្នំពេញ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

7/

## កំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

រឿងក្ដីលេខ :
សញ្ញាណរឿងក្ដី : ប្ដឹងសុំឲ្យប្រគល់ប្រាក់ថ្លៃទិញលំនៅដ្ឋាន
កាលបរិច្ឆេទ : ឆ្នាំពីរពាន់ម្ភៃ ខែកញ្ញា ថ្ងៃទីម្ភៃបី វេលាម៉ោងប្រាំបួនព្រឹក
ទីកន្លែង : សាលាដំបូងរាជធានីភ្នំពេញ បន្ទប់ - ក -
ចៅក្រម : លោក សេង លាង
ក្រឡាបញ្ជី : លោក ហាន ព្រាថ្នា
ភាគី :

-ដើមចោទឈ្មោះ កាន់លិខិតឆ្លងដែនចិនតៃវ៉ាន់លេខ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ អាសយដ្ឋានជាន់ទី៤ លេខ២៧ ផ្លូវ Ji Xaln តំបន់ San Chong ក្រុង Xin Bei។

-អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ៖ មេធាវី ប៊ុន ចាន់ហេង, មេធាវី គី សេរីវុធ និងមេធាវី វ៉ា លីតា ជាមេធាវីនៃការិយាល័យមេធាវី ហាស្គី អេន ផាតនើរ អាសយដ្ឋានផ្ទះលេខ២៣៣D ផ្លូវ២៧១ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-ចុងចម្លើយឈ្មោះ ( មានអាសយដ្ឋាននៅអគារលេខ៧ ជាន់ទី ១១ ផ្លូវលេខ២៣៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

-អ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ៖ មេធាវី រស់ មុនិន្ទៈ និងមេធាវី ស៊ឹង ហនិកា អាសយដ្ឋានក្រុមមេធាវី ខេមជីន តាំងនៅកោះពេជ្រ Diamond Twin Tower ជាន់ទី១១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

ដើមចោទបានប្ដឹងសុំឲ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

១-រំលាយកិច្ចសន្យាទិញលក់(លំនៅដ្ឋាន)យូនីតលេខ១៦B៣ និងកិច្ចសន្យាប្រើប្រាស់ចំណតរថយន្ត លេខរៀងទីB ២០៥ និងB ២០៦ នៃអគារ SKY VILLA (មានទីតាំងស្ថិតនៅលើដីលេខ១៦៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ) ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ រវាងលោក និងក្រុមហ៊ុន ( )

២-រំលាយកិច្ចសន្យាទិញលក់(លំនៅដ្ឋាន)យូនីតលេខ២០B៣ និងកិច្ចសន្យាប្រើប្រាស់ចំណតរថយន្ត លេខរៀងទីB ៣១១ និងB ៣១២ នៃអគារ SKY VILLA (មានទីតាំងស្ថិតនៅលើដីលេខ ១៦៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ) ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ រវាងលោក

៣-រំលាយកិច្ចសន្យាទិញលក់(លំនៅដ្ឋាន)យូនីតលេខ២៣B៣ និងកិច្ចសន្យាប្រើប្រាស់ចំណត

រថយន្ត លេខរៀងទីB២៥១ និងB២៥២ នៃអគារ SKY VILLA (ហាងពីកាំងស្ថិតនៅលើផ្លូវលេខ១៦៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ) ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ រវាងលោក

៤-បង្គាប់ឲ្យចុងចម្លើយប្រគល់ប្រាក់ថ្លៃទិញលំនៅដ្ឋាន និងចំណតរថយន្តទាំងអស់ខាងលើ ដែលបានទទួលពីដើមចោទសរុបចំនួន USD ៨៤៥.១០០(ប៉ែតសិបបួនម៉ឺនប្រាំពាន់មួយរយដុល្លារអាមេរិក) ត្រឡប់ឲ្យដើមចោទវិញ។

៥-បង្គាប់ឲ្យចុងចម្លើយសងប្រាក់ខូចខាតចំនួន១៥% នៃប្រាក់ថ្លៃទិញលំនៅដ្ឋាន និងប្រើប្រាស់ចំណតរថយន្តទាំងអស់សរុបស្មើនឹងចំនួន USD ៤២៨,២៥០(សែសិបពីរម៉ឺនប្រាំបីពាន់ពីររយហាសិបដុល្លារអាមេរិក)ឲ្យដើមចោទ យោងតាមប្រការ១៥.២ ក្នុងកិច្ចសន្យាទិញលក់(លំនៅដ្ឋាន) និងកិច្ចសន្យាប្រើប្រាស់ចំណតរថយន្ត ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥, ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ និងចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤។

៦-ទាមទារសោហ៊ុយមេធាវីចំនួន USD ៣០,០០០(បីម៉ឺនដុល្លារអាមេរិក) ពីចុងចម្លើយ។

៧-ស្នើសុំប្រកាសអនុវត្តបណ្តោះអាសន្នចំពោះចំណុច១ ដល់ចំណុច៦ ខាងលើ។

៨-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

២. អង្គហេតុចាំបាច់ និងអង្គហេតុជាមូលហេតុនៃការទាមទារ

មេធាវី ប៊ុន ចាន់រ៉េហង ,មេធាវី វ៉ា លីតា ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ និងមេធាវី រស់ មុន្នីរ៉ុះ , មេធាវី ស៊ីង ចាន់និកា ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ បានឯកភាពគ្នាស្នើសុំឲ្យតុលាការ លើកកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ទៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង០២ រសៀលវិញ។

តុលាការសម្រេចលើកកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ទៅថ្ងៃទី០២ ខែតុលា ឆ្នាំ ២០២០ វេលាម៉ោង០២រសៀលវិញ តាមការស្នើសុំរបស់គូភាគី។

បានអានសេចក្តីទាំងស្រុងឲ្យគូភាគី និងមេធាវីតំណាងដោយអាណត្តិស្តាប់ ហើយឆ្លើយថាត្រឹមត្រូវ និង បានចុះហត្ថលេខា ឬផ្តិតមេដៃ ជាមួយយើង។

បញ្ចប់កំណត់ហេតុវេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក នាថ្ងៃទីខែឆ្នាំដដែល។

ក្រឡាបញ្ជី

ចៅក្រម

អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ

អ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## បណ្តឹងតវ៉ាលើកំណត់ហេតុត្រៀមសម្រាប់ការទាញហេតុផល

*ខ្ញុំបាទឈ្មោះ កើតថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៩៤ សញ្ជាតិខ្មែរ ជនជាតិខ្មែរ អាសយដ្ឋាន៖ផ្ទះលេខ៣៥ ផ្លូវលេខ២៧A ភូមស្រស្ន សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ និងនាងខ្ញុំឈ្មោះ កើតថ្ងៃទី០៩ ខែសីហា ឆ្នាំ១៩៩៧ សញ្ជាតិខ្មែរ ជនជាតិខ្មែរ អាសយដ្ឋាន៖ ភូមិអង្គតានូ ឃុំលាយបូរ ស្រុកត្រាំកក ខេត្តតាកែវ ។ លេខទូរស័ព្ទ៖ ( ។*

**សូមគោរពជូន**

**ឯកឧត្តមប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

*សូមមេត្តាជ្រាប។*

**កម្មវត្ថុ:** *ស្នើសុំប្តឹងតវ៉ាចំពោះដីកាសម្រេចកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ របស់* ***សាលាដំបូងរាជធានីភ្នំពេញ*** *។*

**យោង:** *- មាត្រា* **១១២** *ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។*

*- សំណុំរឿងរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ របស់* ***សាលាដំបូងរាជធានីភ្នំពេញ*** *។*

*- ដីកាសម្រេចកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤ របស់* ***សាលាដំបូងរាជធានីភ្នំពេញ*** *។ (ឯកសារថតចម្លង)*

*- ដីកាកោះឈ្មោះ និងឈ្មោះ ចុះថ្ងៃទី.... ខែ..... ឆ្នាំ២០២៤ របស់* ***សាលាដំបូងរាជធានីភ្នំពេញ*** *។ (ឯកសារថតចម្លង)*

*តបតាមកម្មវត្ថុ និង យោងខាងលើ យើងខ្ញុំសូមគោរព និង ជម្រាបជូន* **ឯកឧត្តមប្រធាន** *មេត្តាជ្រាបថា: កាលពីថ្ងៃ២១ ខែមិថុនា ឆ្នាំ២០២៤ លោកចៅក្រម...... បានដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយអវត្តមានយើងខ្ញុំជាចុងចម្លើយ និងមេធាវីយើងខ្ញុំដែលជាអ្នកតំណាងស្របច្បាប់ ។ នៅក្នុងកិច្ចនីតិវិធីនេះផងដែរលោកចៅក្រមបានបានកំណត់អំពីចំណុចវិវាទ ដោយមិនបានកំណត់កាលបរិច្ឆេទដាក់ភស្តុតាង រហូតដល់ចេញដីកាកោះយើងខ្ញុំក្នុងការចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី..... ខែ...... ឆ្នាំ២០២៤ ជាមូលហេតុយើងខ្ញុំបាត់បង់សិទ្ធិតទល់ចំពោះមុខ និងដាក់ភស្តុតាងក្នុងការអះអាងអំពីការទាមទាររបស់ដើមចោទ ស្របតាមមាត្រា* **២** *,មាត្រា* **៣** *និងមាត្រា* **១០៨** *ក្រមនីតិវិធីរដ្ឋប្បវេណី ។*

*អាស្រ័យដូចបានជម្រាបជូនខាងលើ សូម* **ឯកឧត្តមប្រធាន** *មេត្តាជួយពិនិត្យ និង សម្រេចបើកកិច្ចនីតិវិធីត្រៀមសម្រាប់ការទាញហេតុដល់យើងខ្ញុំជាថ្មីតាមការស្នើសុំយើងខ្ញុំ ដោយសេចក្តីអនុគ្រោះជាទីបំផុត។*

*សូម* **ឯកឧត្តមប្រធាន** *មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។*

*ថ្ងៃ........................... ខែ........... ឆ្នាំ រោង ឆស័ក ព.ស ២៥៦៨*

*រាជធានីភ្នំពេញ, ថ្ងៃទី......... ខែ.............. ឆ្នាំ ២០២៤*

**ស្នាមម្រាមដៃ**

# ឧបសម្ព័ន្ធទី៣

6/

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានី...
ចូល លេខ....
ថ្ងៃទី...
ម៉ោង...

## <u>ពាក្យសុំបញ្ចូលភស្តុតាង</u>

ខ្ញុំបាទ ភេទប្រុស កើតថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៨១ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ៖ ( ) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ ដែលមានអាសយដ្ឋានស្ថិតនៅ៖ ផ្ទះលេខ១៩៧ ផ្លូវលេខ១២C ភូមិអូរបែកក្អម សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

**<u>សូមគោរពជូន</u>**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

*<u>សូមមេត្តាជ្រាប!</u>*

**<u>កម្មវត្ថុ</u>:** ស្នើសុំបញ្ចូលភស្តុតាងក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៖ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**<u>យោង</u>:** សំណុំរឿងរដ្ឋប្បវេណីលេខ៖ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ **របស់សាលាដំបូងរាជធានីភ្នំពេញ** ។

តបតាមកម្មវត្ថុ និងយោងខាងលើយើងខ្ញុំសូមជម្រាប **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ យើងខ្ញុំសូមធ្វើការដាក់ភស្តុតាងមួយចំនួនដូចខាងក្រោម៖

១. កិច្ចសន្យាការងាររវាង និងលោក ធ្វើឡើងនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨។ (**ឯកសារថតចម្លង**)

២. ប្រតិបត្តិការផ្ទេរប្រាក់ពីគណនីឈ្មោះ ទៅគណនីរបស់ ធ្វើឡើងនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២។ (**ឯកសារថតចម្លង**)

៣. ប្រតិបត្តិការផ្ទេរប្រាក់ពីគណនីឈ្មោះ ទៅគណនីរបស់ ធ្វើឡើងនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២។ (**ឯកសារថតចម្លង**)

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេចទទួលយកនូវភស្តុតាងរបស់ខ្ញុំបាទដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤

**ស្នាមមេដៃស្តាំ**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី
លេខ ១[redacted]
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

# កំណត់ហេតុស្តីពី
## នីតិវិធីត្រៀមសម្រាប់ការធាញហេតុផលលើកទី២
(មាត្រា ១១០ និងមាត្រា ១១១)

ឆ្នាំពីរពាន់ម្ភៃ ខែធ្នូ ថ្ងៃទីបួន វេលាម៉ោងដប់ប្រាំរសៀល ។

យើង ម៉ៅ ស៊ីណា ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក យស ចាសុនា ជាក្រឡាបញ្ជី។

អគ្គសញ្ញាណភាគី

ដើមចោទ ឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ១៩៦៨ ជនជាតិខ្មែរ មានអាសយដ្ឋាន [redacted] ភូមិ៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

មានលោក ស៊ិន លៀងហេង និងកញ្ញា ខេ ឈ្នា ជាមេធាវីតំណាងដោយអាណត្តិ មានការិយាល័យអគារលេខ៣៦ ជាន់ទី១០ ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

ចុងចម្លើយ ឈ្មោះ [redacted] ហៅ ទ[redacted] ភេទប្រុស កើតឆ្នាំ១៩៧៤ មានអាសយដ្ឋានផ្ទះលេខE០9 ផ្លូវលេខ៤៦៦ ក្រុមទី២១ ភូមិ៦ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

មានលោក ចេង វុទ្ធី និងលោក គង់ វីរ៉ា ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ មានការិយាល័យនៅផ្ទះលេខ៥៤ ផ្លូវលេខ៣៣៧ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

ខ្លឹមសារនៃបណ្តឹងសុំ

១.- លែងលះគ្នាជាមួយនឹងចុងចម្លើយឈ្មោះ[redacted] ភេទប្រុស កើតថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៤។

២.- កំណត់យកដើមចោទឈ្មោះ [redacted] ជាម្តាយ មានសិទ្ធិអំណាចមេបាលើកូនប្រុស ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២១ ខែ០៦ ឆ្នាំ២០១០ ដែលមានសំបុត្របញ្ជាក់កំណើតលេខ ១៥៦ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០។

៣.- បង្គាប់ឱ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ(ទ្រព្យសម្បត្តិដោយឡែក) មកឱ្យនាងខ្ញុំវិញនូវ អចលនវត្ថុទំហំ ៩២ ម៉ែត្រក្រឡា មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០១១១០៦-០១១០ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ។

៤.- បែងចែកទ្រព្យសម្បត្តិរួម ជា ០២ ចំណែកស្មើគ្នា ដូចខាងក្រោម៖

៤.១.- អចលនវត្ថុទំហំ [illegible] ម៉ែត្រក្រឡា មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៧១១២០-០៧១៦ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តត្បូងឃ្មុំ។

៤.២.- អចលនវត្ថុទំហំ ៩៩៨៣៣ ម៉ែត្រក្រឡា មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៧១១២០-០៧១៧ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តត្បូងឃ្មុំ

៤.៣.- អចលនវត្ថុមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២៥០៧១១២០-០៧១៨ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តត្បូងឃ្មុំ។

៤.៤.- អចលនវត្ថុទំហំ ៩៩២១៨ ម៉ែត្រក្រឡា មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៧១១២០-០៧១៩ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តត្បូងឃ្មុំ។

៤.៥.- អចលនវត្ថុទំហំ ៩៩៩៧១ ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៧១១២០-០៧២០ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តត្បូងឃ្មុំ។

៤.៦.- អចលនវត្ថុទំហំ ៩៩៩៥២ ម៉ែត្រក្រឡា មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៧១១២០-០៧២១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តត្បូងឃ្មុំ។

៤.៧.- អចលនវត្ថុទំហំ ៩៧៩១៥ ម៉ែត្រក្រឡា មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៧១១២០-០៧២២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តត្បូងឃ្មុំ។

៤.៨.- អចលនវត្ថុទំហំ ៩៩៩៩៨ ម៉ែត្រក្រឡា មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ២៥០៧១១២០-០៧២៣ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តត្បូងឃ្មុំ។

៤.៩.- ដីស្ថិតនៅភូមិឈូក ឃុំឈូក ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ដែលមានគំនូសបង្ហាញទ្រង់ទ្រាយដី វាស់វែងដោយលោក ញឹក ប៊ុនស្រេង និង ទទួលស្គាល់ដោយលោក ស៊ិន សំអុល មេឃុំឈូក។

៤.១០.-រថយន្តម៉ាក Lexus RX 300 ស៊េរីឆ្នាំ ២០២០ ផ្លាកលេខ R.SMEY 18។

៥.- ឱ្យដើមចោទ និង ចុងចម្លើយ ធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើទ្រព្យសម្បត្តិរួម ដូចខាងក្រោម ទៅឱ្យកូនប្រុសឈ្មោះ ភេទប្រុស កើតថ្ងៃទី២១ ខែ០៦ ឆ្នាំ២០១០៖

៥.១.- អចលនវត្ថុទំហំ ១៥៧៥ ម៉ែត្រក្រឡា ស្ថិតនៅក្នុងភូមិ គងជ័យ ឃុំព្រែកកុយ ស្រុកកងមាស ខេត្តកំពង់ចាម ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ៧១៦/១៦ ចេញដោយលោក ហេង គី មេឃុំគងជ័យ។

២

៥.២.- អចលនវត្ថុទំហំ១៥០០ ម៉ែត្រក្រឡា ស្ថិតនៅក្នុងភូមិ គងជ័យ ឃុំព្រៃកុយ ស្រុកកងមាស ខេត្តកំពង់ចាម ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ១៧២/១៣ ចេញដោយលោក ហេង គី មេឃុំគងជ័យ។

៥.៣.- អចលនវត្ថុទំហំ ៣៧៨០ ម៉ែត្រក្រឡា ស្ថិតនៅក្នុងភូមិ គងជ័យ ឃុំព្រៃកុយ ស្រុកកងមាស ខេត្តកំពង់ចាម ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី លេខ ១៧៤/១៣ ចេញដោយលោក ហេង គី មេឃុំគងជ័យ។

៥.៤.- អចលនវត្ថុទំហំ ៣០៩០ ម៉ែត្រក្រឡា ស្ថិតនៅក្នុងភូមិ គងជ័យ ឃុំព្រៃកុយ ស្រុកកងមាស ខេត្តកំពង់ចាម ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ចេញដោយលោក ហេង គី មេឃុំគងជ័យ។

៥.៥.- អចលនវត្ថុមានទំហំ ២៨,៥ ម ស្ថិតនៅក្នុងភូមិ គងជ័យ ឃុំព្រៃកុយ ស្រុកកងមាស ខេត្តកំពង់ចាម ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ២៥១/១៤ ចេញដោយលោក ហេង គី មេឃុំគងជ័យ។

៥.៦.- អចលនវត្ថុជាដីចំការស្ថិតភូមិគងជ័យ ឃុំព្រៃកុយ ស្រុកកងមាស ខេត្តកំពង់ចាម ដែលមានបង្កាន់ដៃបង់ប្រាក់លេខ ក. ៣៩៩៨៩, លេខ ក. ៥០១៩៩, ខ. ៥០០៧៧, លេខ ៣៩០០៣ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩០ ចេញដោយការិយាល័យកសិកម្ម ស្រុកកងមាស។

៥.៧.- អចលនវត្ថុជាដី ដែលមានក្បាលដីប្រវែង ៣០ ម៉ែត្រ និង ជម្រៅ ១០០ ម៉ែត្រ ស្ថិតនៅភូមិគងជ័យ ឃុំព្រៃកុយ ស្រុកកងមាស ខេត្តកំពង់ចាម។

៥.៨.- អចលនវត្ថុជាដី ដែលមានក្បាលដីប្រវែង ៤២ ម៉ែត្រ និង ជម្រៅ ៧០ ម៉ែត្រ ស្ថិតនៅភូមិគងជ័យ ឃុំព្រៃកុយ ស្រុកកងមាស ខេត្តកំពង់ចាម។

៦.- បំណុលរួមចំនួន ២០៦.៧៧០ (ម្ភៃម៉ឺនប្រាំមួយពាន់ប្រាំពីររយចិតសិប) ដុល្លារអាមេរិក ដែលជំពាក់ធនាគារកាណាឌីយ៉ា ក.អ ត្រូវទទួលបន្ទុករួមជាពីរចំណែកស្មើគ្នាតាមចំណែករៀងៗខ្លួន។

៧.- បង្គាប់ឱ្យចុងចម្លើយ បង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនប្រុសឈ្មោះ លី ហៀងស៊ីម ចំនួន ១.០០០ (មួយពាន់) ដុល្លារ ក្នុងមួយខែ រហូតដល់កូនបានដល់នីតិភាព។

៨.- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## តុលាការសាកល្បងធ្វើការផ្សះផ្សា

ដើមចោទឈ្មោះ [redacted] នៅតែរក្សាការទាមទារដូចមាននៅក្នុងពាក្យប្តឹងរបស់ខ្លួនចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២០ និងពាក្យសុំកែតម្រូវពាក្យបណ្តឹងចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ ទុកដោយដែល។

## ខ្លឹមសារនិងអង្គហេតុ ដែលដើមចោទ និងចុងចម្លើយបានអះអាង

ដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ថា នាងខ្ញុំសូមរក្សាការទាមទារដូចនៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ និងពាក្យសុំកែតម្រូវពាក្យបណ្តឹងចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ ទុកដោយដែល។

ចុងចម្លើយ បានធ្វើសេចក្តីថ្លែងការណ៍ថា៖

៣

ចំពោះចំណុចទី១ គឺខ្ញុំបាទរស់ប្រពន្ធ ការដែលដើមចោទចោទប្រកាន់ពីការបោកប្រាស់ ខ្ញុំបាទក៏ចាប់ផ្តើមមានជំលោះ ពេលចោទងើបកូនប្រុសឈ្មោះ លី ហៀងស៊ីម នៃ ប៉ុន្តែខ្ញុំបាទពុំទាមទារសោហ៊ុយចាំបាច់ដើម្បីការចិញ្ចឹមបីបាច់កូនទាំងនោះទេ ដោយសារភាគីដើមចោទរៀបការបំបួនឆាក់នៅក្នុងឆ្នាំឆ្ងាយហើយ ចំណែកខ្ញុំបាទក៏មានកូនចំនួននាក់ ដោយកូនខ្ញុំបាទចំនួននាក់រៀបអាពាហ៍ពិពាហ៍រស់ហើយ ចំណែកនាក់ទៀតនៅជាមួយប្រពន្ធដើមដែលបានលែងលះគ្នាឆ្ងាយហើយ ស្ទើរខ្ញុំបាទរស់នៅម្នាក់ឯងទេ។

ចំពោះចំណុចទី៣ ដែលភាគីខាងដើមចោទឱ្យខ្ញុំបាទចុះបញ្ជីផ្ទេរកម្មសិទ្ធិ (ទ្រព្យសម្បត្តិដោយស្វ័យ) ដែលមានទំហំ ផលិតកម្ម ពេញប្រើសហ្វល់ម្ចាស់អចលនវត្ថុលេខ ១២០១១១០៦-០១១០ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ខ្ញុំបាទមិនអាចចុះបញ្ជីប្រគល់សិទ្ធិឱ្យទៅដើមចោទវិញនោះទេ ព្រោះតាំងពីខ្ញុំបាទរៀបអាពាហ៍ពិពាហ៍ជាមួយនឹងដើមចោទ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០០៩ មកគឺដើមចោទតែងតែយកប្រាក់ពីខ្ញុំបាទជាបន្តបន្ទាប់ ប្រហែល ៣០០.០០០(សាមសិបម៉ឺន)ដុល្លារអាមេរិក។

ចំពោះចំណុចទី៤ ដែលដើមចោទសុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា ទៅលើអចលនវត្ថុចាប់តាំងពីចំណុចទី៤.១ ដល់ចំណុចទី៤.៨ គឺមិនមែនជាកម្មសិទ្ធិរបស់ខ្ញុំបាទនោះទេ ខ្ញុំបាទគ្រាន់តែជាអ្នកឈរឈ្មោះជំនួសឱ្យម្ចាស់លុយតែប៉ុណ្ណោះ ដើម្បីយកប្រាក់ចំណេញ ហើយបច្ចុប្បន្នខ្ញុំបាទបានផ្ទេរសិទ្ធិឱ្យទៅម្ចាស់លុយវិញអស់ហើយ រីឯដីស្ថិតនៅក្នុងភូមិល្អក់ ឃុំល្អក់ ស្រុកក្រគរ ខេត្តកំពង់ចាម ខ្ញុំបាទស្នើសុំឱ្យតុលាការសម្រេចតាមស្ថានភាពជាក់ស្តែងនៃការយល់ព្រមរបស់គូភាគី ចំពោះរថយន្តម៉ាក Lexus RX300 ស៊េរីឆ្នាំ២០២០ ពាក់ស្លាកលេខ RSMEY18 ខ្ញុំបាទទិញស្ថិតនៅក្នុងពេលដែលបែកលែងនៅសន្ធានជាមួយនឹងដើមចោទរួចហើយ បច្ចុប្បន្នរថយន្តនេះមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំបាទនោះ ដោយសារតែខ្ញុំបាទបានយករថយន្តនេះទៅដាក់បញ្ចាំបាត់ទៅហើយ។

ចំពោះចំណុចទី៥ ដែលភាគីដើមចោទឱ្យខ្ញុំបាទចុះបញ្ជីផ្ទេរកម្មសិទ្ធិលើទ្រព្យសម្បត្តិរួម ចាប់ពីចំណុចទី៥.១ ដល់ចំណុចទី៥.៨ បច្ចុប្បន្នខ្ញុំបាទមិនអាចផ្ទេរឱ្យបាននោះទេ ព្រោះដីនេះគឺជាដីរបស់ខ្ញុំបាទទាំងអស់ ដោយដីនេះខ្ញុំបាទទុកឱ្យកូនប្រុសរបស់ខ្ញុំបាទឈ្មោះ លី ហៀងស៊ីម នៅពេលដែលគាត់មានអនីតិភាព ជាអ្នកគ្រប់គ្រង និងនៅពេលដែលខ្ញុំបាទអស់លទ្ធភាពគ្រប់គ្រង។

ចំពោះចំណុចទី៦ បំណុលរួមខ្ញុំបាទមិនទទួលខុសត្រូវក្នុងការសងនោះទេ។

ចំពោះចំណុចទី៧ ដែលដើមចោទបង្គាប់ឱ្យខ្ញុំបាទបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនប្រុស ឈ្មោះ ចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ក្នុងមួយខែ រហូតដល់កូនពេញវ័យភាព ខ្ញុំបាទមិនទទួលខុសត្រូវទេ ព្រោះខ្ញុំបាទជាមន្ត្រីរាជការ មិនមានអាជីពខាងក្រៅនោះទេ គឺខ្ញុំបាទសុំបង់ទៅតាមលទ្ធភាព ប្រសិនបើតុលាការសម្រេចប្រគល់កូនឈ្មោះ ឱ្យមកខ្ញុំបាទ ខ្ញុំបាទពុំទាមទារសោហ៊ុយចាំបាច់ពីដើមចោទនោះដែរ។ ខ្ញុំបាទសុំឱ្យដើមចោទដាក់ទ្រព្យរួមទាំងអស់ដែលដើមចោទបានដាក់ជូនមកតុលាការ ដែលរាប់ចាប់តាំងពីរៀបអាពាហ៍ពិពាហ៍ក្នុងឆ្នាំ២០០៩មក ត្រូវដាក់ជូនមកតុលាការដើម្បីចែកជាពីរចំណែកស្មើគ្នា ព្រោះដោយសារតែទ្រព្យរួមទាំងអស់ ខ្ញុំបាទពុំមានឯកសារនៅនឹងដៃនោះទេ ព្រោះឯកសារទាំងអស់គឺនៅជាមួយនឹងដើមចោទ។ ចំពោះចំណូលថ្លៃបន្ទប់ជួលនៅតាខ្មៅ ចំនួន២៧បន្ទប់ និងផ្ទះលេខE09 នៅបឹងត្របែក ដែលមានទឹកប្រាក់សរុបប្រហែល ៣.០០០ (បីពាន់) ដុល្លារអាមេរិក ក្នុងមួយខែ សុំចែកជាពីរចំណែកស្មើគ្នា។

ដើមចោទ បានធ្វើការថ្លែងការណ៍ថា នាងខ្ញុំសុំតបនឹងសេចក្តីថ្លែងការណ៍របស់ចុងចម្លើយដូចតទៅ៖

ចំពោះចំណុចទី១ នាងខ្ញុំឯកភាព។

ចំពោះចំណុចទី២ នាងខ្ញុំរក្សាការទាមទារដុកទាំងស្រុង ដោយសារតែកូនប្រុសនេះ កំពុងតែរស់នៅ និងរៀនសូត្រ ជាមួយនឹងនាងខ្ញុំ ហើយនាងខ្ញុំក៏មានលទ្ធភាពក្នុងការចិញ្ចឹមកូន។

ចំពោះចំណុចទី៣ នាងខ្ញុំនៅតែរក្សាការទាមទារដដែល ដោយមូលហេតុថា នៅមុនពេលដែលរៀបអាពាហ៍ពិពាហ៍ជាមួយនឹងចុងចម្លើយ នាងខ្ញុំបានទិញផ្ទះលេខE09 ប្លុកE ផ្លូវលេខ៤៦៦ បណ្ដោយប្រវែង១៤,៥ម៉ែត្រ និងទទឹង ៥,៧ម៉ែត្រ ស្ថិតនៅក្នុងផ្សារបឹងត្របែក ដូចមាននៅក្នុងកិច្ចសន្យាទិញ-លក់ផ្ទះល្វែង ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ និងមានលិខិតផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦។ ក្រោយពីរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយនៅឆ្នាំ២០០៩ ដោយចុងចម្លើយជាមន្ត្រីរាជការ នៅខាងសុរិយោដីស្រាប់ ចុងចម្លើយបានល្បួង និងរៀបចំចុះបញ្ជីធ្វើជាវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដោយដាក់ថាជាទ្រព្យសម្បត្តិរួម រវាងនាងខ្ញុំ និងចុងចម្លើយ ដូចបញ្ជាក់នៅក្នុងវិញ្ញាបនបត្រលេខ ១២០១១១០៦-០១១០ ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១០។ តាមរយៈការរៀបរាប់នេះ បានបញ្ជាក់ឱ្យឃើញថា អចលនវត្ថុដែលនាងខ្ញុំទាមទារនេះគឺជាទ្រព្យសម្បត្តិដោយឡែករបស់នាងខ្ញុំ មាននៅមុនចំណងអាពាហ៍ពិពាហ៍ តាមបញ្ញត្តិនៃមាត្រា៩៧២ នៃក្រមរដ្ឋប្បវេណី។

ចំណុចទី៤ ពាក់ព័ន្ធនឹងការទាមទារទ្រព្យសម្បត្តិរួម នាងខ្ញុំនៅតែរក្សាការទាមទារទាំងអស់ដដែល ចាប់ពីចំណុច ៤.១ ដល់ចំណុច ៤.១០ ដោយមូលហេតុថា ទ្រព្យទាំងនេះគឺកើតមានចាប់តាំងពីឆ្នាំ២០០៩ (ចំណងអាពាហ៍ពិពាហ៍ចាប់ផ្ដើម) ហើយមកទល់បច្ចុប្បន្ននេះ នាងខ្ញុំ និងចុងចម្លើយ ពុំទាន់បានរំលាយចំណងអាពាហ៍ពិពាហ៍នៅឡើយទេ។ ដូច្នេះទ្រព្យសម្បត្តិទាំងអស់នេះគឺជាទ្រព្យសម្បត្តិរួម តាមបញ្ញត្តិនៃមាត្រា៩៧៣ នៃក្រមរដ្ឋប្បវេណី។ ជាមួយគ្នានេះដែរពាក់ព័ន្ធនឹងការលើកឡើងរបស់ចុងចម្លើយដែលថាទ្រព្យសម្បត្តិដែលមានបញ្ជាក់ក្នុងចំណុច ៤.១ ដល់ ៤.៨ គឺគ្រាន់តែជាការឈរឈ្មោះឱ្យអ្នកទិញ ហើយផ្ទេរទៅឱ្យម្ចាស់គេវិញ គឺនាងខ្ញុំមិនបានដឹងនោះទេ ហើយម្យ៉ាងវិញទៀត ការផ្ទេរត្រឡប់ទៅវិញ នាងខ្ញុំក៏មិនបានផ្ដិតមេដៃផ្ទេរទៅវិញដែរ។

ចំណុចទី៥ នាងខ្ញុំនៅតែរក្សាការទាមទារដុកទាំងស្រុង ហើយក្នុងករណីដែលចុងចម្លើយមិនទាន់យល់ព្រមផ្ទេរទៅឱ្យកូន នៅពេលនេះទេ នាងខ្ញុំស្នើសុំបែងចែកទ្រព្យសម្បត្តិនោះជាពីរចំណែកស្មើគ្នា ដោយមូលហេតុថាទ្រព្យសម្បត្តិទាំងនោះជាទ្រព្យសម្បត្តិរួម។

ចំណុចទី៦ បំណុលរួមគឺនាងខ្ញុំនៅតែរក្សាការទាមទារដុកទាំងស្រុង ដោយសារការបង្កើតកិច្ចសន្យាត្រូវធ្វើឡើងដោយមានការឯកភាពរវាងនាងខ្ញុំនិងចុងចម្លើយ នៅក្នុងចំណងអាពាហ៍ពិពាហ៍ ហេតុដូច្នេះវាជាបំណុលរួម រវាងនាងខ្ញុំ និងចុងចម្លើយតាមបញ្ញត្តិនៃមាត្រា៩៧៥ នៃក្រមរដ្ឋប្បវេណី។

ចំណុចទី៧ នាងខ្ញុំរក្សាការទាមទារដដែល។ ចំពោះចំណុចដែលចុងចម្លើយបានលើកឡើងឱ្យដាក់ឯកសារទ្រព្យរួមចាប់ពីឆ្នាំ២០០៩ ដល់បច្ចុប្បន្ន និងថ្លៃឈ្នួលផ្ទះនៅកោះឡៅ និងនៅបឹងត្របែក គឺមិនមាននោះទេ។

នាងខ្ញុំសុំឱ្យចុងចម្លើយ ដាក់ឯកសារលក់ដីនៅត្បូងឃ្មុំ និងការបញ្ចាំរថយន្តម៉ាក RX300 និងសំណូមពរឱ្យទាមទារចេញសាលក្រមដូចមាននៅក្នុងកម្មវត្ថុខាងលើ។

លោក ស៊ុន លៀងហេង ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានឯកភាពតាមសេចក្ដីថ្លែងការណ៍របស់កូនក្ដីដូចខាងលើ។

ចុងចម្លើយ ខ្ញុំបាទសុំបដិសេធ ចំពោះចំណុចដែលដើមចោទបានថ្លែងការណ៍ថា ខ្ញុំបាទបានធ្វើការល្បួងលោមឱ្យចុះបញ្ជីផ្ទះលេខE09 នៅបឹងត្របែក នោះ មិនពិតនោះទេ គឺកើតចេញពីការព្រមព្រៀងក្រោយពីរៀបអាពាហ៍ពិពាហ៍។

ចំពោះដីដែលនៅត្បូងឃុំចំនួន ៨ប័ណ្ណ គឺជាកម្មសិទ្ធិរបស់ខ្ញុំបាទតែម្នាក់ឯង ហើយខ្ញុំបាទបានផ្ទេរទៅឱ្យម្ចាស់លុយវិញ ខ្ញុំបាទធ្វើនេះគ្រាន់តែយកកម្រៃជើងសារតែប៉ុណ្ណោះ។

ចំពោះចំណុចទី៥ ដែលដើមចោទបានទាមទារឱ្យបែងចែកជាពីរនោះ ខ្ញុំបាទពុំព្រមនោះទេ ដោយខ្ញុំបាទសុំគ្រប់គ្រង និងប្រគល់ឱ្យកូនគ្រប់គ្រងនៅពេលដែលកូនមាននីតិភាព។ ចំពោះបំណុល ខ្ញុំបាទសុំឱ្យដើមចោទទទួលខុសត្រូវតែម្នាក់ឯងចុះ ដោយហេតុថា ទឹកប្រាក់ដែលទទួលពីការបញ្ចាំនោះ ខ្ញុំបាទពុំបានទទួលយកទឹកប្រាក់នោះមកប្រើប្រាស់នោះទេ។ ខ្ញុំបាទស្នើសុំដើមចោទផ្តល់វិក្កយបត្រថ្លៃឈ្នួលផ្ទះទាំងពីរមកតុលាការ និងសុំឱ្យតុលាការចេញសាលក្រមតាមការទាមទារ។

លោក ឆេង វុទ្ធី និងលោក គង់ វីរ៉ា ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ បានឯកភាពតាមសេចក្តីថ្លែងការណ៍របស់កូនក្តីដូចខាងលើ និងស្នើសុំឱ្យតុលាការសម្រេចតាមការទាមទារ។

តុលាការសម្រេចកំណត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី៣ នៅពេលក្រោយ។

បញ្ឈប់កំណត់ហេតុនេះ នៅវេលាម៉ោងដប់ប្រាំមួយ និងហាសិបនាទីរសៀល នាថ្ងៃខែឆ្នាំដូចខាងលើ។

អានសេចក្តីទាំងស្រុងឱ្យភាគីស្តាប់ ឆ្លើយថាត្រឹមត្រូវ ហើយបានយល់ព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃជាមួយយើង។

| ដើមចោទ | មេធាវី | ចុងចម្លើយ | មេធាវី | ក្រឡាបញ្ជី | ចៅក្រម |
|---|---|---|---|---|---|

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**
សំណុំរឿងរដ្ឋប្បវេណីលេខ៖
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤

# លិខិតអញ្ជើញ

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

អញ្ជើញមេធាវី **អត្តលេខ៖២៧៧៣** ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាអ្នកតំណាងដោយអណត្តិឱ្យ**សហចុងចម្លើយ**ឈ្មោះ និងឈ្មោះ មានការិយាល័យក្រុមមេធាវីយុត្តិធម៌ និងសហការី មានទីស្នាក់ការកណ្តាលផ្ទះលេខ៤២០ ផ្លូវលេខ៣៧១ ភូមិព្រៃកគាគង់១ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ឱ្យចូលមកកាន់ **សាលាដំបូងរាជធានីភ្នំពេញ** មានអាស័យដ្ឋាននៅ អគារសាលាយុត្តិធម្ម ផ្លូវលោកតាក្រហមក ភូមិព្រៃកលៀបសង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញនៅ **បន្ទប់ "ញ១"ជាន់ទី៣**

**នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤ វេលាម៉ោង ០៨និង០០នាទី ព្រឹក ។**

ដើម្បី៖ **ចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់** ។

ពីដំណើររឿង៖ **ប្តឹងសុំសាលក្រមទាមទារប្រាក់** ។

សូមអញ្ជើញតាមដីការកោះនេះឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៤
**ចៅក្រម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

ឋាន ព្រាថ្នា
បន្ទប់ "ឆ" ជាន់ទី៣

# ដីកាកោះ

សំណុំរឿងរដ្ឋប្បវេណី

យើង **សាយ សម្ផស្សសេរី** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។

| | |
|---|---|
| អញ្ជើញឈ្មោះ ភេទប្រុស, ឈ្មោះ ភេទស្រី និងឈ្មោះ ភេទស្រី ជា សហចុងចម្លើយ។<br>អាសយដ្ឋាន: ផ្ទះលេខ១៩៧ ផ្លូវលេខ១១២C ភូមិអូរបែកក្អម សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ | |
| សញ្ញាណនៃរឿងក្តី (លេខនិងភាគី)<br>-សុំសាលក្រមទាមទារប្រាក់ | សំណុំរឿងក្តីលេខ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ ។<br>-ដើមចោទ តំណាងដោយលោក<br>អ្នកតំណាងដោយអាណត្តិ៖ មេធាវី ស៊ុង កិរិយា, មេធាវី ឈុន ដារិទ្ធ<br>-សហចុងចម្លើយឈ្មោះ ភេទប្រុស, ឈ្មោះ ភេទស្រី និងឈ្មោះ ភេទស្រី<br>អ្នកតំណាងដោយអាណត្តិ៖ មេធាវី សាវ មិញហុង, មេធាវី សេង សុវណ្ណារី, មេធាវី តឹក សិរីវិចិត្រ និងមេធាវី អ៊ុំ សុធា។ |
| កាលបរិច្ឆេទ និង ទីកន្លែងដែលត្រូវបង្ហាញខ្លួន | ថ្ងៃទី...២៦...ខែសីហា ឆ្នាំ២០២៤ វេលាម៉ោង...០៩ព្រឹក.........។<br>នៅបន្ទប់ "ឆ" ជាន់ទី៣ សាលាដំបូងរាជធានីភ្នំពេញ (សាលាយុត្តិធម្ម)។ |
| ប្រភេទដំណាក់កាលនៃនីតិវិធី<br>(សូមគូស ☐ លើលេខនៃនីតិវិធីដែលចាំបាច់) | ១.ការទាញហេតុផលដោយផ្ទាល់មាត់ ☑ ២.ការប្រកាសសាលក្រម ☐<br>៣.ការផ្សះផ្សា ☐ ៤.នីតិវិធីត្រៀម ☐ ៥.ធ្វើសេចក្តីបញ្ជាក់ដំបូង ☐ |
| ប្រភេទនៃឯកសារដែលភ្ជាប់ជាមួយ៖ | -លិខិតផ្សេងៗ ទៀត ដែលពាក់ព័ន្ធ។ |
| ទណ្ឌកម្មជាអាទិ៍ ក្នុងករណីដែលមិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ | ១.ចំពោះសាមីភាគី: បើពុំចូលខ្លួនទេ៖ តុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀត ជាការពិតបាន។ (តាមមាត្រា១៤០ កថាខណ្ឌទី២. ២៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។<br>២.ចំពោះសាក្សី: បើមិនព្រមចូលខ្លួនមកតុលាការ ដោយគ្មានមូលហេតុត្រឹមត្រូវ *តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០(មួយលាន)រៀល* តាមមាត្រា១៣២ កថាខណ្ឌ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ |

សូមបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដូចដែលបានកំណត់ខាងលើនេះ។

ថ្ងៃពុធ ៣កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៤
**ចៅក្រម**

សាយ សម្ផស្សសេរី

បញ្ជាក់: ក្នុងករណីដែលមានជំងឺ ឬមានមូលហេតុផ្សេងទៀតដែលមិនអាចបង្ហាញខ្លួនបាន សូមដាក់ឯកសារបញ្ជាក់របស់វេជ្ជបណ្ឌិត ឬបញ្ជាក់មូលហេតុនោះ ជូនតុលាការ ។
ពេលបង្ហាញខ្លួន សូមយកដីកាកោះនេះជូនក្រឡាបញ្ជីទទួលបន្ទុក ។
ទម្រង់នេះប្រើសម្រាប់ ភាគី សាក្សី អ្នកចូលរួមអន្តរាគមន៍ក្នុងបណ្តឹង ។